


# ការវាយប្រហារ និងការគំរាមកំហែង អ្នកការពារសិទ្ធិមនុស្ស នៅកម្ពុជា ២០០៧

របាយការណ៍សង្ខេប លីកាដូ
ខែសីហា ឆ្នាំ២០០៨

លីកាដូ
សម្ព័ន្ធខ្មែរជំរុញនិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the Promotion and Defense of Human Rights
LICADHO

# ការវាយប្រហារ និងការគំរាមកំហែងចំពោះ
# អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៧

**របាយការណ៍សង្ខេប**

**ខែសីហា ឆ្នាំ២០០៨**


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំង ៦ របស់ខ្លួន ដូចខាងក្រោម:**

- **ការិយាល័យស៊ើបអង្កេត** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស និងជួយជនរងគ្រោះនានាក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់។ បុគ្គលិកដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយអោយពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែកច្បាប់ទៀតផង។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និងមន្ត្រីពន្ធនាគារនៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្ត្រ និងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណកម្ម** ជាការិយាល័យផ្តល់សេវាកម្មស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណកម្ម នឹងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណកម្ម។
- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណៈជនទូទៅ ស្ថាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា និងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រី** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណៈជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី និងធ្វើការតស៊ូមតិ ដើម្បីអោយមានការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គម។
- **ការិយាល័យឯកសារ និងធនធានព័ត៌មាន** គឺជាការិយាល័យដែលរក្សាចងក្រងសំណុំរឿងទៅក្នុងទិន្នន័យដើម្បីងាយស្រួលក្នុងការរកឯកសារ និងវិភាគអោយបានឆាប់រហ័ស។

## ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ
អាសយដ្ឋាន: អង្គការលីកាដូ ( សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស )
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤៩០១ ទូរសារ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦
អ៊ីម៉ែល: contact@licadho.org គេហទំព័រ: http://www.licadho.org/

**រូបភាពនៅលើក្របរបាយការណ៍នេះ:** ព្រះសង្ឃខ្មែរកម្ពុជាក្រោម បានប្រឈមមុខជាមួយនគរបាលបង្ក្រាបកុបកម្ម ខណៈពេលព្រះសង្ឃទាំងនោះបានធ្វើបាតុកម្មដោយសន្តិវិធី នៅខាងក្រៅស្ថានទូតវៀតណាមកាលពីខែធ្នូ ឆ្នាំ២០០៧។ ( សូមមើលទំព័រ ១៤)

របាយការណ៍នេះ បោះពុម្ពឡើងក្រោមជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុរបស់សហគមន៍អឺរ៉ុប ។ សេចក្តីអធិប្បាយនៅក្នុងរបាយការណ៍នេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គការលីកាដូ ហើយមិនអាចយកទៅប្រើប្រាស់ក្នុងរូបភាពណាមួយ ដើម្បីឆ្លុះបញ្ចាំងពីទស្សនៈរបស់សហគមន៍អឺរ៉ុបឡើយ ។

# មាតិកា

**របាយការណ៍សង្ខេប** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ក

**១. សេចក្តីផ្តើម** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ១

អ្នកការពារសិទ្ធិមនុស្ស-តើពួកគេជានរណា ? ------------------------------------ ១

កិច្ចការពារស្របច្បាប់ចំពោះអ្នកការពារសិទ្ធិមនុស្ស ---------------------------------- ២

**២. ភាពប្រវត្តិ**~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣

សិទ្ធិមនុស្ស និងការឆ្លើយតបរបស់រដ្ឋាភិបាល------------------------------------------ ៣

អ្នកការពារសិទ្ធិមនុស្ស: តើមានការរីកចម្រើនអ្វីខ្លះតាំងពីឆ្នាំ២០០៦? -------------------- ៦

**៣. ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាពីខែមករា ដល់ខែធ្នូ ឆ្នាំ២០០៧** ~ **១០**

បុគ្គលិកសិទ្ធិមនុស្ស------------------------------------------------------------ ១០

អ្នកជួយជនភៀសខ្លួន --------------------------------------------------------------១១

ព្រះសង្ឃសកម្មជនខ្មែរកម្ពុជាក្រោម ------------------------------------------------ ១៤

តំណាងសហជីពកម្មករ------------------------------------------------------------ ១៩

*ព័ត៌មានថ្មី១: មេដឹកនាំសហជីពសេរីកម្មករនៅរោងចក្រ ប្រាយស្កាយ និងសាន់តិច ------------២០*

*ករណីសិក្សា: ឃាតកម្មលោក ហ៊ី វុទ្ធី ------------------------------------------- ២២*

តំណាងសហគមន៍ក្នុងបញ្ហាទំនាស់ដីធ្លី ------------------------------------------- ២៥

*ព័ត៌មានថ្មី១: ករណី សូ សុជាតិ ទំនាស់ដីធ្លីនៅវត្តបូព៌ ខេត្ត សៀមរាប-------------------- ២៧*

*ព័ត៌មានថ្មី១: ករណី ឈា នី និង ជម្លោះដីធ្លីនៅស្រុក បវេល -------------------------- ២៨*

*ករណីសិក្សា: សហគមន៍ដីក្រហម -------------------------------------------------- ៣១*

*ករណីសិក្សា: ជម្លោះដីធ្លីនៅភូមិគងយុ --------------------------------------------៣៣*

**៤. អនុសាសន៍**~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៧

**ឧបសម្ព័ន្ធៈតារាងព្រឹត្តិការណ៍ឧប្បត្តិហេតុកើតឡើងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាពីខែមករា ដល់ខែធ្នូ ឆ្នាំ២០០៧** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៩

# របាយការណ៍សង្ខេប

កម្ពុជា គឺជាកន្លែងដ៏គ្រោះថ្នាក់បំផុត សម្រាប់អ្នកការពារសិទ្ធិមនុស្សទាំងឡាយ។ តាមការកត់ត្រារបស់សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) បង្ហាញថា នៅក្នុងឆ្នាំ២០០៧ មានករណីគំរាមកំហែង និងវាយប្រហារចំពោះអ្នកការពារសិទ្ធិមនុស្សដែលមានបំណងប្រាថ្នាការពារសិទ្ធិអ្នកដទៃដោយសន្តិវិធី ច្រើនជាងឆ្នាំមុនៗទាំងអស់។

ក្នុងឆ្នាំ២០០៧នេះ ទម្រង់នៃការគំរាមកំហែង និងការវាយប្រហារចំពោះអ្នកការពារសិទ្ធិមនុស្សដែលបានសង្កេតឃើញកើតមានកាលពីឆ្នាំមុនៗ នៅតែបន្តមានដដែល ហើយមានសភាពកាន់តែធ្ងន់ធ្ងរជាងមុនថែមទៀត។ តំណាងសហគមន៍នានាដែលបានចេញមុខដើរតួតវ៉ាក្នុងបញ្ហាទំនាស់ដីធ្លី និងផ្ទះសម្បែង បានក្លាយជាគោលដៅនៃការគំរាមកំហែង និងចោទប្រកាន់ដោយគ្មានដីកា ហើយនៅក្នុងករណីខ្លះ ឈានរហូតដល់ចាប់ឃុំ ក្នុងពន្ធនាគារថែមទៀត។ អ្នកដឹកនាំសហជីពកម្មករមួយចំនួន ត្រូវរងរបួស ចាប់ខ្លួន និងផ្តន្ទាទោស ដោយសារការធ្វើសកម្មភាពសហជីពស្របច្បាប់របស់ពួកគេ ហើយមានអ្នកដឹកនាំបែបនេះម្នាក់ ត្រូវបានគេធ្វើឃាត។ បុគ្គលិកអង្គការសិទ្ធិមនុស្សជាច្រើន នៅតែបន្តរងការគំរាមកំហែង និងរារាំងដល់ការអនុវត្តន៍ការងាររបស់ខ្លួនឥតឈប់ឈរ ចំណែកឯប្រជាពលរដ្ឋសាមញ្ញដែលបានជួយអ្នកស្វែងរកសិទ្ធិជ្រកកោនដោយស្របច្បាប់ ក៏ត្រូវបានយាយី និងចាប់ដាក់ពន្ធនាគារផងដែរ ។

## ឆ្នាំ២០០៧នេះ ជាឆ្នាំដែលបានជួបប្រទះការលេចឡើងនូវនិន្នាការរំខានពីរគឺៈ

និន្នាការទីមួយគឺ ការបន្តបំភិតបំភ័យចំពោះព្រះសង្ឃខ្មែរកម្ពុជាក្រោមនៅកម្ពុជាដែលបានធ្វើការតស៊ូមតិដើម្បីសិទ្ធិជនជាតិភាគតិចរបស់ពួកគេ និងដើម្បីឱ្យមានការបញ្ឈប់នូវការធ្វើទុក្ខបុកម្នេញដល់បងប្អូនរបស់ខ្លួនដែលជាអ្នកការពារសិទ្ធិមនុស្សដូចគ្នានៅប្រទេសវៀតណាម។ ការតាមព្យាបាទនៅកម្ពុជារួមមានការបង្ក្រាបបាតុកម្មដោយសន្តិវិធី ដោយប្រើអំពើហិង្សា ការចាប់ និងបញ្ជូនព្រះសង្ឃមួយអង្គដែលជាអ្នកជំទាស់សកម្មជាងគេ និងអាចមានការធ្វើឃាតព្រះសង្ឃមួយអង្គដែលបានចូលរួមក្នុងការតវ៉ានេះផង។

និន្នាការទីពីរគឺ ការធ្វើឱ្យខូចខាតដល់វិជ្ជាជីវៈច្បាប់សិទ្ធិមនុស្ស ជាពិសេសគឺពាក់ព័ន្ធជាមួយករណីទំនាស់ដីធ្លីដ៏ធំមួយ នៅភូមិគងយុ ខេត្តរតនគិរី ។ ក្រោយពីមានការគំរាមកំហែងចំៗមកលើមេធាវីការពារសិទ្ធិមនុស្សដែលគ្រាន់តែបំពេញតួនាទីរបស់ខ្លួន ជាតំណាងឱ្យមនុស្សគ្មានអំណាចនោះ បណ្តាលឱ្យមេធាវីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាជាច្រើននាក់ មានការភ័យខ្លាច មិនហ៊ានបន្តធ្វើសកម្មភាពស្របច្បាប់របស់ខ្លួនតទៅទៀត។

(ខ) របាយការណ៍សង្ខេបរបស់លីកាដូ

នៅកម្ពុជា អ្នកការពារសិទ្ធិមនុស្សជាច្រើនបានដឹងយ៉ាងឈឺចាប់បំផុតថា ពួកគេអាចពឹងលើច្បាប់បានតិចតួចបំផុត ឬ មិនអាចសោះតែម្តង ។ ក្នុងចំណោមករណីគំរាមកំហែង និងវាយប្រហារចំនួន ៤៧ ដែលត្រូវបានលើកឡើងដោយលីកាដូ នៅក្នុងរបាយការណ៍ស្តីពីអ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០០៦ កន្លងទៅនោះ គេសង្កេតឃើញថាគ្មានករណីព្រហ្មទណ្ឌធ្ងន់ធ្ងរណាមួយ ត្រូវបានធ្វើការស៊ើបអង្កេតដែលនាំឱ្យឈានដល់ការផ្តន្ទាទោសជនសង្ស័យណាម្នាក់ឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ក្នុងករណីជាច្រើន ពួកអ្នកការពារសិទ្ធិមនុស្សបែរជារងការផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ និងខ្លះទៀតរងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរជាទីបំផុតទៅវិញ។

របាយការណ៍សង្ខេបនេះ ផ្តល់នូវការវិភាគអំពីការគំរាមកំហែងដែលចេះតែកើតឡើងឥតឈប់ឈរចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជានៅចន្លោះខែមករា និងខែធ្នូ ឆ្នាំ២០០៧ ។ របាយការណ៍នេះក៏មានគោលបំណងធ្វើការតាមដានដល់ករណីមួយចំនួនដែលបានកត់ត្រាទុកជាឯកសារនៅក្នុងរបាយការណ៍ស្តីពី *ការវាយប្រហារនិងគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៦* ផងដែរ។ ព័ត៌មានទាំងឡាយនៅក្នុងរបាយការណ៍នេះ គឺផ្អែកលើការស៊ើបអង្កេត និងព័ត៌មានផ្សេងៗដែលចងក្រងដោយលីកាដូ ដោយមានការជួយឧបត្ថម្ភគាំទ្រពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ព្រមទាំងអង្គការសិទ្ធិមនុស្សកម្ពុជា និងអង្គការនៅតាមមូលដ្ឋានជាច្រើនថែមទៀត។

របាយការណ៍នេះពុំបានអះអាងថា ជារបាយការណ៍ទូទៅទេ ។ ចំពោះអ្នកការពារសិទ្ធិមនុស្សជាច្រើនរងការគំរាមកំហែង និងការយាយីរំខាន គឺជារឿងមួយដែលគេតែងតែជួបប្រទះជាប្រចាំនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ ហើយបញ្ហាបែបនេះជាច្រើនមិនត្រូវបានរាយការណ៍ទេ ។ លីកាដូចាត់ទុកថា វាជារឿងមួយដែលមិនអាចទទួលយកបានទាល់តែសោះ ចំពោះបទឧក្រិដ្ឋទាំងឡាយដែលក្លាយទៅជារឿងធម្មតាបែបនេះ ហើយសូមអំពាវនាវដល់អាជ្ញាធរកម្ពុជាគ្រប់លំដាប់ថ្នាក់ ចាប់ផ្តើមបង្ហាញនូវការប្តេជ្ញាចិត្តចំពោះបញ្ហាសិទ្ធិមនុស្ស ដោយការផ្តន្ទាទោសជនទាំងឡាយដែលបានធ្វើការវាយប្រហារចំពោះអ្នកការពារសិទ្ធិមនុស្សក្នុងរយៈពេលកន្លងមក។

□□□

# ១. សេចក្តីផ្តើម

## អ្នកការពារសិទ្ធិមនុស្ស-តើពួកគេជានរណា ?

អ្នកការពារសិទ្ធិមនុស្ស គឺជាមនុស្ស (ជារូបវន្តបុគ្គល ឬ រួមជាមួយអ្នកដទៃទៀត) ធ្វើសកម្មភាព ដើម្បីលើកស្ទួយ ឬ ការពារសិទ្ធិមនុស្សជាមូលដ្ឋានតាមវិធីអហិង្សា ។ អ្នកការពារសិទ្ធិមនុស្សអាចជាសមាជិករបស់អង្គការសិទ្ធិមនុស្សជាតិ ឬ អន្តរជាតិ ឬ អាចធ្វើការជាលក្ខណៈមិនផ្លូវការ ដើម្បីសហគមន៍របស់ពួកគេ។ ជាទូទៅ ពួកគេជាបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល អ្នកតំណាងសហជីពកម្មករ អ្នកដឹកនាំសហគមន៍ អ្នកសារព័ត៌មាន គ្រូបង្រៀន ឬ សិស្ស និស្សិត ប៉ុន្តែអាចជានរណាក៏បានដែរ ដោយមិនគិតដល់វិជ្ជាជីវៈជាប្រចាំរបស់ពួកគេទេ ។ បច្ចុប្បន្ននេះ នៅកម្ពុជាសកម្មជនសិទ្ធិមនុស្សនៅតាមសហគមន៍មានការកើនឡើង ហើយអង្គការទាំងនោះកំពុងបំពេញតួនាទីជាចំបងៗក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ។

ដើម្បីកំណត់ថា តើករណីមួយអាចជាអំពើគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្សម្នាក់ ឬ យ៉ាងណានោះ អង្គការលីកាដូយល់ឃើញថា ជាការសំខាន់ត្រូវកំណត់ថា តើជនរងគ្រោះបានធ្វើសកម្មភាពដែលការពារ ឬ លើកស្ទួយសិទ្ធិមនុស្ស ដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងត្រូវបានធានាដោយច្បាប់អន្តរជាតិនានា ដូចជាកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែរឬទេ? សកម្មភាពដូចពោលខាងលើនេះ គួរធ្វើឡើងទាំងស្រុង ឬ ផ្នែកខ្លះ តំណាងឱ្យអ្នកដទៃ ហើយត្រូវបង្ហាញឱ្យឃើញនូវទំនាក់ទំនងច្បាស់លាស់ រវាងសកម្មភាពដែលបានអនុវត្តដើម្បីការពារសិទ្ធិមនុស្ស ទៅនឹងការទទួលរងការគំរាមកំហែង ការយាយី ឬ ការបំភិតបំភ័យដែលបានទទួលរងគ្រោះ។

សូមកត់សម្គាល់ថា អ្នកនយោបាយក៏អាចធ្វើសកម្មភាពជាអ្នកការពារសិទ្ធិមនុស្សដូចអ្នកដទៃដែរ ប៉ុន្តែអាជ្ញាធរគ្រប់គ្រងប្រទេសដែលមានប្រវត្តិសិទ្ធិមនុស្សមិនល្អ ដូចជាប្រទេសកម្ពុជា តែងតែព្យាយាមបង្ខូចកេរ្តិ៍ឈ្មោះអង្គការសិទ្ធិមនុស្សអព្យាក្រិត្យ ដោយការចោទប្រកាន់អង្គការសិទ្ធិមនុស្សទាំងនោះ ពីការជាប់ពាក់ព័ន្ធជាមួយគណបក្សជំទាស់ ។ ដើម្បីចៀសវាងការចោទប្រកាន់ពីភាពលំអៀង និងដើម្បីកំណត់ពីកិច្ចការពារផ្សេងៗ ចំពោះអ្នកនយោបាយក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ការគំរាមកំហែងដែលកើតមានចំពោះអ្នកនយោបាយ មិនត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍សង្ខេបនេះទេ ។

# កិច្ចការពារស្របច្បាប់ចំពោះអ្នកការពារសិទ្ធិមនុស្ស

នៅកម្ពុជា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ បានផ្តល់ជាមូលដ្ឋានច្បាប់សំរាប់ការពារអ្នកការពារសិទ្ធិមនុស្ស រួមបញ្ចូលទាំងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ការជួបប្រជុំគ្នា និងការបញ្ចេញមតិជាដើម ។ នៅឆ្នាំ១៩៩២ រដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនានា មានដូចជាកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ បទបញ្ញត្តិនៃកតិកាសញ្ញាទាំងពីរ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សទាំងនេះ ត្រូវបានបញ្ចូលនៅក្នុងច្បាប់ជាតិនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ។

នៅឆ្នាំ១៩៩៨ ក្នុងឱកាសខួបលើកទី ៥0 នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តទទួលយកជាឯកច្ឆន្ទនូវសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័នសង្គមដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលមានការទទួលស្គាល់ជាសកល ។[១] សេចក្តីប្រកាសនេះបានក្លាយជា " សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស " ។

សេចក្តីប្រកាសមានចែងអំពីសិទ្ធិ និងកិច្ចការពារចំពោះអ្នកការពារសិទ្ធិមនុស្ស ដែលត្រូវតែគាំទ្រដោយប្រទេសជាសមាជិកអង្គការសហប្រជាជាតិដូចជា សិទ្ធិស្វែងរកព័ត៌មាន ទទួល និងរក្សាទុកព័ត៌មានទាក់ទងនឹងសិទ្ធិមនុស្ស ឬ ការរិះគន់មិនគោរពបទដ្ឋានសិទ្ធិមនុស្សរបស់រដ្ឋាភិបាលជាដើម ។ តំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្សបានធ្វើការកត់សម្គាល់ថា សេចក្តីប្រកាសនេះផ្អែកតាមគោលការណ៍ជាកាតព្វកិច្ចផ្លូវច្បាប់ និងជាសិទ្ធិដែលមានកំណត់រួចនៅក្នុងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ ហើយដោយសារ "សេចក្តីប្រកាសនេះ ត្រូវបានអនុម័តទទួលយកជាឯកច្ឆន្ទដោយមហាសន្និបាតអង្គការសហប្រជាជាតិ ដូច្នេះសេចក្តីប្រកាសនេះតំណាងឱ្យការប្តេជ្ញាចិត្តដ៏មុតមាំសំរាប់ប្រទេសនានា ក្នុងការអនុវត្តន៍សេចក្តីប្រកាសនេះ[២] "។

□□□

[១] អង្គការសហប្រជាជាតិឯកសារយោង: A/RES/53/144. ផ្សព្វផ្សាយថ្ងៃទី៨ ខែមិនា ឆ្នាំ១៩៩៩។

[២] ចំពោះព័ត៌មានបន្ថែមនិងអត្ថបទរបស់សេចក្តីប្រកាសសូមមើលគេហទំព័រខាងក្រោម: http://www2.ohchr.org/english/issues/defenders/declaration.htm

# ២. ភាលប្រវត្តិ

## សិទ្ធិមនុស្ស និងការឆ្លើយតបរបស់រដ្ឋាភិបាល

សេចក្តីសន្និដ្ឋាននៅក្នុងទស្សនកិច្ចផ្លូវការលើកទី៤ របស់តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា កាលពីខែធ្នូ ឆ្នាំ២០០៧ កន្លងទៅ បានធ្វើការវាយតម្លៃយ៉ាងហ្មត់ចត់អំពីការលូតលាស់ខាងវិស័យសិទ្ធិមនុស្សរបស់រដ្ឋាភិបាល ។ នៅក្នុងការវាយតម្លៃរបស់លោក យ៉ាស់ ហ្គាយ សិទ្ធិមនុស្សកំពុងត្រូវបានជាន់ឈ្លី ហើយអាចវាយតម្លៃកម្ពុជាបានយ៉ាងសាមញ្ញថាជា "ប្រទេសដែលគ្មាននីតិរដ្ឋ "។ លោកបានមានប្រសាសន៍ថា "ស្ថាប័ននានាដែលទទួលបន្ទុកការអនុវត្តន៍នីតិរដ្ឋ គឺមានភាពទន់ខ្សោយ ហើយចំណុះឱ្យរដ្ឋាភិបាល" ហើយប្រជាពលរដ្ឋមានការភ័យខ្លាចស្ថាប័នតុលាការ ដោយចាត់ទុកថាជា " កន្លែងអយុត្តិធម៌ "។[៣]



លោក យ៉ាស់ ហ្គាយ នៅក្នុងសន្និសីទសារព័ត៌មានមួយនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៧

ការវាយតម្លៃរបស់លោក យ៉ាស់ ហ្គាយ មិនមែនធ្វើឡើងខុសគេតែម្នាក់ឯងទេ។ ក្រសួងការបរទេសសហរដ្ឋអាមេរិកក៏បានធ្វើសេចក្តីសន្និដ្ឋានដែរថា កំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋាភិបាលកម្ពុជា គឺស្ថិតនៅក្នុងលំដាប់ទាបបំផុតក្នុងឆ្នាំ ២០០៧ គ្មានចំណាត់ការអ្វីសោះ ពេលដែល "កម្លាំងសន្តិសុខបានសម្លាប់មនុស្សក្រៅច្បាប់ ហើយបណ្តោលឱ្យរួចខ្លួនដោយនិទ្ទណ្ឌភាព" ហើយបន្ថែមថា រដ្ឋាភិបាលមានឆន្ទៈនយោបាយតិចតួចបំផុត ដើម្បីដោះស្រាយការបរាជ័យរបស់អាជ្ញាធររដ្ឋាភិបាលក្នុងការប្រកាន់ខ្ជាប់នីតិរដ្ឋ" ។[៤]

អង្គការឃ្លាំមើលសិទ្ធិមនុស្សក៏បានសង្កេតឃើញស្រដៀងគ្នាដែរថា ១០ ឆ្នាំ ក្រោយពីរដ្ឋប្រហារឆ្នាំ១៩៩៧ និទ្ទណ្ឌភាពចំពោះការរំលោភសិទ្ធិមនុស្សនៅកម្ពុជានៅតែជាបញ្ហាដដែល។ "ស្ថាប័នតុលាការនៅតែបន្តអនុវត្តក្រោមបញ្ជារបស់អង្គនីតិប្រតិបត្តិ ហើយគ្មានខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាអំពើពុករលួយដែលសាយភាយទូទៅ ឬ ការរាលដាលនៃការលួចកេងបន្លំធនធានធម្មជាតិសោះឡើយ" ។[៥]

---

[៣] ហ្វីហ្គាល់ គីន និង ឆាយ ចាន់នីដា: *បេសកជនបានស្តីបន្ទោសរដ្ឋាភិបាលនៅទិវាសិទ្ធិមនុស្សអន្តរជាតិ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៧ ។

[៤] របាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តន៍សិទ្ធិមនុស្សឆ្នាំ២០០៧ ក្រសួងការបរទេសសហរដ្ឋអាមេរិកថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨

[៥] របាយការណ៍ពិភពលោករបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សឆ្នាំ២០០៨ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ។

(៤) របាយការណ៍សង្ខេបរបស់លីកាដូ

ការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជាចំពោះការរិះគន់នេះ ត្រូវបានច្រានចោល ។ រដ្ឋាភិបាលចូលចិត្តវាយប្រហារមកលើអង្គការមិនមែនរដ្ឋាភិបាល ឬ បុគ្គលណាដែលហ៊ានបញ្ចេញមតិជំទាស់ ជាជាងដោះស្រាយបញ្ហាដែលលើកឡើងដោយអ្នកការពារសិទ្ធិមនុស្សនានា។ ចំពោះអ្នកសង្កេតការណ៍ដែលស្គាល់កម្ពុជាច្បាស់ វោហារសាស្ត្រដ៏ប៉ិនប្រសប់បែបនេះ គេអាចទាយទុកជាមុនបាន ហើយគួរឱ្យហួសចិត្តយ៉ាងខ្លាំង។ ឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍រួមរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានលើកឡើងពីការព្រួយបារម្ភអំពីការរំលោភសិទ្ធិមនុស្សជាច្រើន ដែលបានចងក្រងជាឯកសារយ៉ាងត្រឹមត្រូវ អ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័ក្រ បានអះអាងថា ក្រុមអង្គការសិទ្ធិមនុស្សបានបំផ្លើសស្ថានភាពហួសពីការពិត។ គាត់បានមានប្រសាសន៍ថា" យើងមានចំណុចល្អ ១០.០០០ ដង តែពួកគេមិនបានលើកឡើងទេ ។ ប៉ុន្តែចំណុចអាក្រក់តែមួយ ពួកគេបើកកកាយឡើង " ដោយមានប្រសាសន៍ម្តងហើយម្តងទៀតថា ការរិះគន់រដ្ឋាភិបាល "គឺជាមុខរបររបស់ពួកគេ .... ប្រសិនបើពួកគេមិននិយាយអាក្រក់ នោះពួកគេគ្មានប្រាក់បៀវត្សរ៍ទេ" ។[៦]

អ្នកការពារសិទ្ធិមនុស្សអន្តរជាតិក៏ដូចជាអ្នកការពារសិទ្ធិមនុស្សជាតិដែរ សុទ្ធតែត្រូវបានរដ្ឋាភិបាលប្រព្រឹត្តចំពោះបែបនេះដូចៗគ្នា ។ កាលពីខែមករា ក្រោយពីមានចេញផ្សាយរបាយណ៍ជាប់ៗគ្នាស្តីពីស្ថានភាពរោងចក្រដោយអង្គការពលកម្មអន្តរជាតិ សម្តេចនាយករដ្ឋមន្ត្រីបានលើកឡើងថា បុគ្គលិកអង្គការពលកម្មអន្តរជាតិមួយចំនួន អាចជម្រិតទារប្រាក់ពីរោងចក្រនានា ជាថ្នូរនឹងការធ្វើរបាយការណ៍ផ្គាប់ចិត្ត។[៧] កាលពីខែមិនា ក្រោយពីអង្គការផ្តួចផ្តើមយុត្តិធម៌សង្គមដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិករាយការណ៍អំពីអំពើពុករលួយ និងការគ្រប់គ្រងមិនត្រឹមត្រូវនៅសាលាក្តីខ្មែរក្រហម ឯកឧត្តម ខៀវ កញ្ញារីទ្ធិ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានមានប្រសាសន៍ថា រដ្ឋាភិបាលកំពុងពិចារណាក្នុងការបណ្តេញអង្គការនេះចេញពីប្រទេស។[៨]

---

[៦] ខ្ញូក្លា ជីលីសុន និង យន់ សាមាន អង្គការមិនមែនរដ្ឋាភិបាល: *អង្គការសហប្រជាជាតិគួរគាំទ្រសិទ្ធិមនុស្សនៅកម្ពុជា* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃ ទី៣០ ខែឧសភា ឆ្នាំ២០០៧។

[៧] អេរិក វ៉ាសុន និង យន់ សាមាន: *អង្គការពលកម្មអន្តរជាតិបានស្វែងរកការពន្យល់ ក្រោយពីសម្តេចនាយករដ្ឋមន្ត្រីបានចោទសួរអំពីរបាយការណ៍* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៨ ។

[៨] អេរិកា ឃីណេត និង យន់ សាមាន: *រដ្ឋាភិបាលកំពុងដំណើរការដេញអង្គការផ្តួចផ្តើមយុត្តិធម៌សង្គមចេញពីប្រទេស* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៨ ខែមិនា ឆ្នាំ២០០៧។




របាយការណ៍អង្គការគ្លូបល វិតណេស ដែលត្រូវបានហាមប្រាមមិនឱ្យផ្សព្វផ្សាយ

កាលពីខែមិថុនា អង្គការឃ្លាំមើលបរិស្ថានអន្តរជាតិឈ្មោះ គ្លូបល វិតណេស បានចេញផ្សាយរបាយការណ៍រិះគន់មួយយ៉ាងធ្ងន់ធ្ងរ ដោយបានភ្ជាប់មន្ត្រីរដ្ឋាភិបាល សមាជិកគ្រួសារ និងបក្សពួករបស់ពួកគេមួយចំនួនទៅនឹងសកម្មភាពឧក្រិដ្ឋ ពាក់ព័ន្ធនឹងការបំផ្លិចបំផ្លាញធនធានធម្មជាតិនៅកម្ពុជា។ រដ្ឋាភិបាលបានឆ្លើយតប ដោយការហាមប្រាមមិនឱ្យចេញផ្សាយរបាយការណ៍នោះជាសាធារណៈ ស្របពេលគ្នានោះក៏មានលេចឮនូវសេចក្តីរាយការណ៍នានា អំពីការបំភិតបំភ័យដ៏ធ្ងន់ធ្ងរដល់មនុស្សទាំងឡាយដែលពាក់ព័ន្ធក្នុងការចែកផ្សាយរបាយការណ៍នោះ ហើយមន្ត្រីរដ្ឋាភិបាលម្នាក់ហ៊ានដល់ចេញការគំរាមដល់អាយុជីវិតជាសាធារណៈ មកលើបុគ្គលិកអង្គការគ្លូបល វិតណេស ទៀតផង។[៩] ក្នុងខែកក្កដា នៅពេលដែលនាយក អង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំនៅអាស៊ីធ្វើសិក្ខាសាលាមួយនៅ រាជធានីភ្នំពេញ ដើម្បីប្រារព្ធខួបលើកទី១០នៃរដ្ឋប្រហារខែកក្កដា ឆ្នាំ១៩៩៧ ឯកឧត្តម ខៀវ កញ្ញារីទ្ធ បានចោទ ប្រកាន់គាត់ថា បានធ្វើការបម្រើឱ្យពួកខ្មែរក្រហម។[១០]

ប៉ុន្តែ ពេញមួយឆ្នាំ២០០៧ ការបរិយាយដ៏គ្រោតគ្រាតបំផុត ត្រូវបានបម្រុងទុកសម្រាប់ស្ថានទូតមន៍លោក តំណាងពិសេសអង្គការសហប្រជាជាតិ យ៉ាស់ ហ្គាយ។ លោក ហ្គាយ ត្រូវបានធ្លាក់ចូលទៅក្នុងការរិះគន់យ៉ាងគ្រោតគ្រាតបំផុតពីសំណាក់រដ្ឋាភិបាល ពេលដែលគាត់រិះគន់ចំពោះដំណើរការធ្វើវិមជ្ឈការអំណាចនៅកម្ពុជាភ្លាមៗក្រោយពីត្រូវបានតែងតាំងនៅក្នុងឆ្នាំ២០០៦ ហើយពេលនោះសម្តេចនាយករដ្ឋមន្ត្រីបានឆ្លើយតបដោយការពិពណ៌នាអំពីគាត់ថា "ល្ងើយ " និងជា "អ្នកទេសចររយៈពេលវែង" ដែល "មកដោយគ្មានដឹងអ្វីបន្តិចទាល់តែសោះ"។[១១] នៅខែមិថុនា ឆ្នាំ២០០៧ជាថ្មីម្តងទៀត សម្តេចនាយករដ្ឋមន្ត្រីបានបដិសេធមិនព្រមជួបលោក យ៉ាស់ ហ្គាយ ហើយក្រោយមកបានមានប្រសាសន៍ជាសាធារណៈថា "ប្រសិនបើអ្នកឯងបន្តស្នាក់នៅកម្ពុជា ១.០០០ ឆ្នាំទៀត ហើយប្រសិនបើខ្ញុំមានអាយុរស់នៅដល់ ១.០០០ ឆ្នាំដែរនោះ ក៏ខ្ញុំនៅតែមិនជួបអ្នកឯងដែរ... ភាសាខ្មែរយើងនិយាយថា ឆ្កែចេះតែព្រុស មនុស្សចេះតែដើរ ។ ខ្ញុំមិនចង់ប្រៀបធៀបគាត់ (ជាមួយឆ្កែ )ទេ ប៉ុន្តែគាត់បាន

[៩] ខ្ញូក្លា ជីលីសុន និង យន់ សាមានៈ *ការហាមឃាត់របាយការណ៍បង្ខូចកេរ្តិ៍ឈ្មោះរបស់អង្គការ គ្លូបល វិតណេស ផ្តើមការស៊ើបអង្កេត*។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៧។

[១០] ប្រេត អាដាម : *នាយករដ្ឋមន្ត្រីបានកាន់អំណាចយ៉ាងណែនក្នុងដៃ*—វិទ្យុអាស៊ីសេរីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៧។

[១១] ឈឹម សុភ័ក្រ និង អេរិក វ៉ាសុន : *នាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា បេសកជនអង្គការសហប្រជាជាតិគួរតែដកចេញ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៦។

ចោទប្រកាន់ខ្ញុំ"។[១២] នៅខែធ្នូ សម្តេចនាយករដ្ឋមន្ត្រីបានអះអាងថា លោក យ៉ាស់ ហ្គាយ មិនសមមកនិយាយពីសិទ្ធិមនុស្សនៅកម្ពុជាទេ ពីព្រោះនៅប្រទេសកេនយ៉ារបស់គាត់ បញ្ហាសិទ្ធិមនុស្សនេះ"អាក្រក់ជាងយើងមួយរយដងទៅទៀត"។ ខណៈនោះដែរ ឯកឧត្តម ខៀវ កញ្ញារីទ្ធិ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានអះអាងថា លោក យ៉ាស់ ហ្គាយ នៅទីនេះគឺជា "តំណាងរបស់គណបក្សជំទាស់ មិនមែនតំណាងរបស់អង្គការសហប្រជាជាតិទេ"។[១៣] នៅបំណាច់ឆ្នាំដដែល សម្តេចនាយករដ្ឋមន្ត្រីបានប្រកាសថា បានធ្វើពាក្យបណ្តឹងផ្លូវការទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ អំពីលោក យ៉ាស់ ហ្គាយ ដោយបានមានប្រសាសន៍ថា នរណាគាំទ្ររបាយការណ៍ចុងក្រោយរបស់តំណាងពិសេសអង្គការសហប្រជាជាតិនោះ គឺជា "មនុស្សថោកទាបបំផុត"។[១៤]

លោក យ៉ាស់ ហ្គាយ បានមានប្រសាសន៍ជាច្រើនលើកថា ការសង្ឃឹមរបស់គាត់ គឺបញ្ចុះបញ្ចូលរដ្ឋាភិបាលឱ្យធ្វើការចរចារ ដោយទទួលស្គាល់ថា បើគ្មានកិច្ចសហការពីរដ្ឋាភិបាលទេ ការរីកចម្រើនខាងវិស័យសិទ្ធិមនុស្សគឺអាចមានកម្រិតតិចតួចជាទីបំផុតនៅកម្ពុជា។ អង្គការជាតិមួយចំនួនក៏បានទទួលស្គាល់ផងដែរថា សិទ្ធិមនុស្សមានឱកាសរីកចម្រើនឈានទៅមុខ ប្រសិនបើរដ្ឋាភិបាលគោរពតួនាទីរបស់អ្នកការពារសិទ្ធិមនុស្ស ទទួលស្គាល់សុពលភាពនៃរបាយការណ៍របស់ពួកគេ ហើយធ្វើការសហការគ្នា ដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរនានាដែលបានលើកឡើង។ ប៉ុន្តែ ថ្ងៃនោះវាហាក់ដូចជានៅមានគំលាតឆ្ងាយនៅឡើយ។

## អ្នកការពារសិទ្ធិមនុស្ស: តើមានការរីកចម្រើនអ្វីខ្លះតាំងពីឆ្នាំ២០០៦?

នៅខែធ្នូឆ្នាំ២០០៦ លីកាដូ បានចេញផ្សាយនូវរបាយការណ៍មួយស្តីពី *ការវាយប្រហារ និងគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៦*។ របាយការណ៍នោះបានរៀបរាប់យ៉ាងលំអិតអំពីករណីគំរូចំនួន ៤៧ ដែលជាករណីរារាំង បំភិតបំភ័យ បង្ករបួសស្នាម ឬ ការផ្តន្ទាទោសអ្នកការពារសិទ្ធិមនុស្សក្នុងកំឡុងពេលពីខែមករា ដល់ខែតុលា ឆ្នាំ២០០៦ ហើយបានផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីចាត់វិធានការ។ ប៉ុន្តែគួរឱ្យសោកស្តាយផងដែរ គ្មានអនុសាសន៍ណាមួយត្រូវទទួលយកសំរាប់ការចាត់វិធានការទាល់តែសោះ។

---

[១២] យន់ សាមាន និង ជេម វេល: *នាយកមន្ត្រីបានមាក់ងាយបេសកជនពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សម្តងហើយម្តងទៀត* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៧។

[១៣] យន់ សាមាន និង ហ្វីហ្គាល់ គីន: *នាយករដ្ឋមន្ត្រីបានប្រមាថមើលងាយបេសកជនអង្គការសហប្រជាជាតិ ការពារភូមា* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧។

[១៤] *កម្ពុជាបានដាក់ពាក្យបណ្តឹងទៅលោក ចាន គីមូន អំពីបេសកជនសិទ្ធិមនុស្ស*— ទីភ្នាក់ងារព័ត៌មាន អាអេហ្វប៉េថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៧។

**របាយការណ៍នោះបានធ្វើអនុសាសន៍ថា រដ្ឋាភិបាលគួរចាត់វិធានការដូចខាងក្រោម:**

- **អនុវត្តតាមពាក្យសន្យារបស់ខ្លួនក្នុងការលុបបទបរិហារកេរ្តិ៍ ចេញពីបទល្មើសព្រហ្មទណ្ឌ ហើយគួរលុបបទផ្សាយព័ត៌មានមិនពិត ចេញពីបទល្មើសព្រហ្មទណ្ឌផងដែរ ។**

  *បច្ចុប្បន្ននេះ ទោះបីជាគ្មានការផ្តន្ទាទោសដាក់ពន្ធនាគារចំពោះបទបរិហារកេរ្តិ៍ក៏ដោយ ក៏វានៅតែជាបទល្មើសព្រហ្មទណ្ឌដដែល ។ នៅក្នុងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីបំផុតដែលទទួលបានជាសាធារណៈ បរិហារកេរ្តិ៍នៅតែជាបទល្មើសព្រហ្មទណ្ឌ ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារភ្ជាប់មកជាមួយផង ។[១៥] សម្តេចនាយករដ្ឋមន្ត្រី បានលើកឡើងនៅក្នុងសន្ទរកថាមួយក្នុងខែសីហា ឆ្នាំ២០០៧ ថា បទបរិហារកេរ្តិ៍ត្រូវបានក្រុមប្រឹក្សារដ្ឋមន្ត្រីលុបចេញពីក្រមព្រហ្មទណ្ឌហើយ ប៉ុន្តែការលើកឡើងនេះមិនទាន់ច្បាស់ថា តើគាត់សំដៅទៅលើការលុបចេញនូវទោសដាក់ពន្ធនាគារ ហើយក៏នៅមិនទាន់មានសេចក្តីព្រាងថ្មីណាមួយចេញផ្សាយនៅឡើយដែរ ។[១៦] យោងតាមច្បាប់បច្ចុប្បន្ននេះ ការផ្សាយព័ត៌មានមិនពិតនៅតែជាបទល្មើសព្រហ្មទណ្ឌដដែល ។*

- **ផ្អាករាល់ការប៉ុនប៉ងនានាក្នុងការអនុម័តសេចក្តីស្នើ** *ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ឬច្បាប់ណាមួយដែលស្រដៀងច្បាប់ស្តីពី "អង្គការមិនមែនរដ្ឋាភិបាល" នេះ* **រហូតដល់ពេលណាមានការធានានូវឯករាជ្យភាព និងសមត្ថភាពរបស់តុលាការនៅកម្ពុជា ។**

  *ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនេះត្រូវបានទុកចោលមួយរយៈ ប៉ុន្តែគេនៅមិនបានដឹងថា បានព្រាងដល់ណាហើយក្នុងឆ្នាំ២០០៧ នេះ ។*

- **តម្រូវឱ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ឈប់បង្កឧបសគ្គដល់ការធ្វើសកម្មភាពស្របច្បាប់របស់អង្គការសិទ្ធិមនុស្សនានា ។**

  *ករណីជាច្រើនត្រូវបានកត់ត្រានៅក្នុងឆ្នាំ២០០៧ ដែលអាជ្ញាធរកម្ពុជាបានរារាំងសកម្មជនអង្គការសិទ្ធិមនុស្សនានា ជាពិសេសសកម្មភាពឃ្លាំមើលការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋានដោយហិង្សា និងការធ្វើវេទិកាសាធារណៈ ។ សូម្បីតែលោក យ៉ាស់ ហ្គាយ ដែលជាតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ក៏បានក្លាយជាជនរងគ្រោះនៃការរារាំងនេះដែរ ។ ចំពោះព័ត៌មានលំអិតសូមអាន ទំព័រទី ១១ និងឧបសម្ព័ន្ធ ។*

- **ត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញាឆ្នាំ១៩៥១ ស្តីពីជនភៀសខ្លួន និងឈប់គំរាមកំហែង យាយីរំខាន និងបំភិតបំភ័យដល់ប្រជាពលរដ្ឋណាដែលជួយដល់អ្នកស្វែងរកសិទ្ធិជ្រកកោន ។**

  *រដ្ឋាភិបាលបានបន្តការមិនគោរពកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញាស្តីពីជនភៀសខ្លួន ដោយឥតលាក់លៀមនៅក្នុងឆ្នាំ២០០៧នេះ ។ បញ្ហានេះ វាបានរារាំងយ៉ាងខ្លាំងដល់ការងាររបស់ឧត្តមស្នងការសហប្រជាជាតិទទួល*

---

[១៥] ក្រសួងយុត្តិធម៌: *គម្រោងក្រមព្រហ្មទណ្ឌថ្មី* បុងនីញ៉ើ និងសហការី ឆ្នាំ២០០៥ ។

[១៦] *នាយករដ្ឋមន្ត្រីបានអំពាវនាវដល់អ្នកសារព័ត៌មាន កុំឱ្យសរសេរអត្ថបទជេរគ្នា ប៉ុន្តែសុំឱ្យសរសេររិះគន់ក្នុងន័យស្ថាបនា* កាសែតចក្រវាលថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ បកប្រែនៅក្នុងកញ្ចក់សង្គម វ៉ុល ១១ លេខ ៥២០ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៧ ។

*បន្ទុកជនភៀសខ្លួនក្នុងការជួបអ្នកស្វែងរកសិទ្ធិជ្រកកោន ដោយបានចាប់ខ្លួនពលរដ្ឋកម្ពុជាដែលបានព្យាយាមជួយពួកអ្នកភៀសខ្លួនទាំងនោះ និងបានចូលរួមក្នុងការបញ្ជូនពួកគេទៅប្រទេសមួយដែលអាចប្រឈមមុខនឹងការផ្តន្ទាទោស និងទារុណកម្ម ។ ចំពោះព័ត៌មានលំអិត សូមអានទំព័រ ១៣ និងឧបសម្ព័ន្ធ ។*

- **ធានាឱ្យមានការអនុវត្តន៍នូវគោលការណ៍មិនរើសអើងនៅក្នុងច្បាប់ការងារ ហើយក៏ត្រូវធានាផងដែរដល់តំណាងសហជីពទាំងអស់កុំឱ្យមានការបញ្ឈប់ពីការងារ ឬ ត្រូវរងការយាយីរំខានដោយសារតែសកម្មភាពសហជីពនានាឡើយ ។**

  *សកម្មជនសហជីពជាច្រើននៅតែជាជនរងគ្រោះនៃអំពើយាយីរំខាន ដូចជា ការរំលោភបំពាន និងការគំរាមផ្ដែកច្បាប់ជាបន្តបន្ទាប់ឥតឈប់ឈរនៅឆ្នាំ២០០៧ ចំណែកឯជនរងគ្រោះដែលត្រូវបានរងទុក្ខស្រដៀងគ្នានេះក្នុងឆ្នាំ២០០៦ បានមានឈ្មោះនៅក្នុងបញ្ជីខ្មៅ ហើយមិនអាចរកការងារធ្វើបានទេ ។ ចំពោះព័ត៌មានលំអិត សូមអានទំព័រ ២១ និង ឧបសម្ព័ន្ធ ។*

- **ទាមទារឱ្យច្បាប់ទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងដីធ្លី និងធនធានធម្មជាតិត្រូវបានអនុវត្តក្នុងភាពយុត្តិធម៌ត្រឹមត្រូវខ្ជាប់ខ្ជួនដោយស្ថាប័នតុលាការកម្ពុជា ហើយត្រូវធានាដល់ភាគីនានានៅក្នុងទំនាស់ដីធ្លី និងធនធានធម្មជាតិ មិនត្រូវបានចោទប្រកាន់ពីបទរំលោភលើទ្រព្យសម្បត្តិ ខណៈពេលដែលទំនាស់នៅមិនទាន់បានដោះស្រាយនៅឡើយ ។**

  *ស្ថាប័នតុលាការកម្ពុជានៅតែបន្តភាពលំអៀងយ៉ាងខ្លាំង ហើយមិនបានប្រតិបត្តិតាមបទដ្ឋានអប្បរមាយុត្តិធម៌ចំពោះការវិនិច្ឆ័យទោសដោយយុត្តិធម៌នៅក្នុងករណីដីធ្លីជាច្រើនក្នុងឆ្នាំ២០០៧ ។ តុលាការក៏នៅតែបន្តចោទប្រកាន់តំណាងសហគមន៍ពីបទរំលោភលើទ្រព្យសម្បត្តិ ក្នុងករណីដែលកម្មសិទ្ធិលើទ្រព្យសម្បត្តិនោះ មិនទាន់បានធ្វើស្របច្បាប់ត្រឹមត្រូវនៅឡើយ ។ ចំពោះព័ត៌មានលំអិតសូមអានទំព័រ ២៧ និង ឧបសម្ព័ន្ធ ។*

- **តម្រូវឱ្យបើកសវនាការ ឬ លើកលែងការចោទប្រកាន់ក្នុងកំឡុងពេល ៦ ខែ បន្ទាប់ពីការចាប់ជនសង្ស័យយោងតាមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងយកចិត្តទុកដាក់ពិសេសចំពោះការរំលោភលើនីតិវិធីនេះក្នុងករណីពាក់ព័ន្ធជាមួយសកម្មជនកម្មករ និងសិទ្ធិដីធ្លី ។**

  *អ្នកការពារសិទ្ធិមនុស្សនៅតែបន្តជាប់ពន្ធនាគាររង់ចាំការកាត់ទោសអស់រយៈពេលជាង ៦ ខែ មុននឹងត្រូវបានបើកសវនាការ ។ លើសពីនេះទៅទៀត នៅក្នុងឆ្នាំ២០០៧ ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័ត ដែលបានបន្ថែមរយៈពេលឃុំខ្លួនបណ្ដោះអាសន្នអាចបន្តដល់ ១៨ ខែ ចំពោះបទល្មើសព្រហ្មទណ្ឌ ។*[១៧] *ចំពោះអ្នកដែលត្រូវបានដោះលែងឱ្យនៅក្រៅឃុំក្នុងឆ្នាំ២០០៦ ការចោទប្រកាន់នៅតែបន្តចោទមកលើពួកគេដដែលយ៉ាងពិត*

---

[១៧] ច្បាប់ថ្មីនៅរក្សាគោលការណ៍ថា ពិរុទ្ធជន (ជាប់ចោទបទព្រហ្មទណ្ឌ) ត្រូវតែបើសវនាការក្នុងរយៈពេល ៦ ខែ ប៉ុន្តែច្បាប់នេះបានអនុញ្ញាតឱ្យចៅក្រមស៊ើបអង្កេតអាចបន្តរយៈពេលឃុំខ្លួនបណ្ដោះអាសន្ននេះបានពីរដង រហូតដល់ ១៨ ខែ ក្នុងស្ថានភាពខ្លះ។ ច្បាប់នីតិវិធីព្រហ្មទណ្ឌ ខែមិថុនា ឆ្នាំ២០០៧ មាត្រា ២០៨។

*ប្រាកដ។ មានករណីតែមួយគត់ដែលអង្គការលីកាដូបានដឹងថា សកម្មជនបានក្លាយជាគោលដៅចោទប្រកាន់ដោយគ្មានភស្តុតាងនៅក្នុងឆ្នាំ២០០៦ ហើយត្រូវបានលើកលែងការចោទប្រកាន់វិញ ដោយការដោះលែងនោះត្រូវបានធ្វើឡើងជិតមួយឆ្នាំក្រោយពីធ្វើការចាប់ខ្លួន។[១៨] លើសពីនេះទៀត អង្គការលីកាដូបានផ្តល់អនុសាសន៍ថា អាជ្ញាធរកម្ពុជាត្រូវចាត់វិធានការជាជំហ៊ានៗដើម្បីស៊ើបអង្កេត និងផ្តន្ទាទោសជនល្មើសទាំងឡាយណាដែលបានប្រព្រឹត្តអំពើហិង្សា និងបំភិតបំភ័យមកលើអ្នកការពារសិទ្ធិមនុស្ស។*

- **មិនមានករណីណាមួយពីឆ្នាំ២០០៦ ដែលបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្តមកលើអ្នកការពារសិទ្ធិមនុស្សត្រូវបានស៊ើបអង្កេតឱ្យបានហ្មត់ចត់ ហើយនាំជនល្មើសមកផ្តន្ទាទោសឡើយ។ ផ្ទុយទៅវិញ អ្នកការពារសិទ្ធិមនុស្សជាច្រើន ដែលត្រូវបានចោទប្រកាន់ដោយអយុត្តិធម៌នៅឆ្នាំ២០០៦ ត្រូវបានបន្តរងការផ្តន្ទាទោសយ៉ាងអយុត្តិធម៌នៅក្នុង ឆ្នាំ២០០៧។**

□□□

[១៨] ការចោទប្រកាន់ពីបទរំលោភលើទ្រព្យសម្បត្តិ ដែលចោទតំណាងសហគមន៍ ៦ នាក់ នៅក្នុងករណីទំនាស់ដីធ្លីនៅខេត្តបន្ទាយមានជ័យ-ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៦ ត្រូវបានលើកលែងការចោទប្រកាន់ជាផ្លូវការដោយតុលាការខេត្តបន្ទាយមានជ័យនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧។ សម្រាប់ព័ត៌មានលំអិតអំពីករណីនេះ សូមអានរបាយការណ៍លីកាដូ: *ការវាយប្រហារ និងគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៦* ទំ.២៩ ។

# ៣. ការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០០៧

## បុគ្គលិកសិទ្ធិមនុស្ស

បុគ្គលិករបស់អង្គការសិទ្ធិមនុស្សកម្ពុជា នៅតែជាជនរងគ្រោះដោយសារការគំរាមកំហែង ការបំភិតបំភ័យ និងការរារាំងក្នុងសកម្មភាពការងាររបស់ពួកគេ។

នៅខែមិនា អ្នកឃ្លាំមើលសិទ្ធិមនុស្សមកពីអង្គការសិទ្ធិមនុស្សជាតិ អាដហុក និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាត្រូវបាននគរបាលឃាត់ខ្លួនដើម្បីសួរចម្លើយ ខណៈដែលបុគ្គលិកទាំងនោះ កំពុងឃ្លាំមើលអាជ្ញាធរបណ្តេញប្រជាពលរដ្ឋជាង ១០០ គ្រួសារចេញពីលើដីនៅក្បែរតំបន់ប្រាសាទអង្គរ ខេត្តសៀមរាប។ នគរបាលបានដោះលែងបុគ្គលិកទាំងនោះមួយម៉ោងក្រោយ បន្ទាប់ពីពួកគេត្រូវបានសួរចម្លើយដោយមន្ត្រីអាជ្ញាធរអប្សារា។

ខែឧសភា បុគ្គលិកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ឈ្មោះ ឈឹម សាវុធ ត្រូវបានចោទប្រកាន់ដោយអភិបាលក្រុងព្រះសីហនុ សាយ ហាក់ ពីបទញុះញង់អ្នកភូមិឱ្យបំបែកខ្លួនចេញពីការគ្រប់គ្រងរបស់រដ្ឋាភិបាល។ ការចោទប្រកាន់នោះ គឺមានការជាប់ពាក់ព័ន្ធជាមួយនឹងភូមិស្ពានឆេះ ខណ្ឌមិត្តភាព ដែលជាទីតាំងរងការបណ្តេញចេញដោយបង្ខំ និងរងអំពើហិង្សាយ៉ាងខ្លាំងកាលពីថ្ងៃទី២០ ខែមេសា។ មុនពេលបណ្តេញចេញ លោក សាវុធ បានជួយប្រជាពលរដ្ឋក្នុងការរៀបចំធ្វើសំណើ ដើម្បីឱ្យរដ្ឋាភិបាលទទួលស្គាល់សហគមន៍ពួកគេជាផ្លូវការ។ ឯកឧត្តម សាយ ហាក់ បានអះអាងថា លោកបានផ្តល់ភស្តុតាងបទល្មើសព្រហ្មទណ្ឌទៅតុលាការក្រុង ហើយពីរបីថ្ងៃក្រោយមក លោក សាវុធ បានចាកចេញពីទីក្រុងនោះ ក្រោយពីមានពាក្យចចាមអារ៉ាមថា អាជ្ញាធរបម្រុងចាប់ខ្លួនលោក។ មួយរយៈពេលខ្លីក្រោយមក មេធាវីអង្គការដែលតំណាងឱ្យប្រជាពលរដ្ឋដែលត្រូវបណ្តេញចេញ និងចាប់ខ្លួននៅស្ពានឆេះនោះ ត្រូវជនមិនស្គាល់មុខទូរស័ព្ទមកគំរាមដល់អាយុជីវិត ដោយព្រមានលោកថា ឱ្យឈប់ការពាររឿងនេះតទៅទៀត។

លោក ឈឹម សាវុធ បានប្រឈមមុខនឹងការយាយីរំខានជាថ្មីម្តងទៀតនៅខែកក្កដា ពេលដែលគាត់បំពេញការងារនៅខេត្តតាកែវ អាជ្ញាធរបានចាប់ឃុំខ្លួនលោកដោយខុសច្បាប់ ខណៈពេលដែលលោកកំពុងរៀបចំវេទិកាសាធារណៈ ដើម្បីពិភាក្សាអំពីការបាត់ខ្លួនព្រះសង្ឃខ្មែរកម្ពុជាក្រោម ព្រះនាម ទឹម សាខន (សូមអានទំព័រ ១៦)។ អាជ្ញាធរក៏បានហាមប្រាម និងអុកឡុកដល់គម្រោងធ្វើវេទិកាសាធារណៈជាច្រើនទៀតផងដែរ ដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានត្រៀមរៀបចំធ្វើនៅក្នុងឆ្នាំ២០០៧ ហើយមានពេលខ្លះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាក៏បានចោទ

ប្រកាន់អាជ្ញាធរឃុំមួយនៅខេត្តស្វាយរៀងថា បានបញ្ជាឱ្យមានការ កត់ត្រាទុកនូវការហៅទូរស័ព្ទចេញទាំងអស់ តាមទូរស័ព្ទសាធារណៈ នៅក្នុងឃុំ ដើម្បីទប់ស្កាត់អ្នកភូមិ កុំឱ្យប្តឹងអំពីការគំរាមកំហែងមកលើពួកគេ នៅក្នុងវេទិកាពិភាក្សាអំពីបញ្ហាទំនាស់ដីធ្លី ។ កាលពី ឆ្នាំ២០០៦ លោក សារ៉ុច ក៏ធ្លាប់ទទួលរងការគំរាមកំហែងដែរ ពេលនោះលោកជាបុគ្គលិកម្នាក់ ក្នុងចំណោមបុគ្គលិកសិទ្ធិមនុស្ស ៤ នាក់ ដែលត្រូវបានចាប់ឃុំខ្លួន និងបំភិតបំភ័យ ខណៈដែលពួកលោក ឃ្លាំមើលករណីទំនាស់ដីធ្លីមួយកន្លែងនៅខេត្តកំពត ។ (សូមមើលទំព័រ ទី ២៥)



ផ្ទាំងរូបភាពត្រូវបានដាក់តាំងបង្ហាញនៅខាងក្រៅ កន្លែងប្រជុំជាមួយម្ចាស់ជំនួយ នៅថ្ងៃទី១៩ ខែមិថុនា

បុគ្គលិកសិទ្ធិមនុស្សអន្តរជាតិក៏បានប្រឈមមុខការរារាំងផងដែរ ។ នៅថ្ងៃទី១៩ ខែមិថុនា ជនបរទេស ៨ នាក់ ត្រូវបាននគរបាលចាប់ឃុំខ្លួនអស់រយៈពេលជាង ៩ ម៉ោង ក្រោយពីអ្នកទាំងអស់នោះបានធ្វើបាតុកម្មនៅខាងក្រៅ កន្លែងប្រជុំរបស់ក្រុមប្រទេសអ្នកផ្តល់ជំនួយ នៅក្នុងទីស្នាក់ការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ ជនបរទេសទាំង ៨ នាក់ បានតវ៉ាប្រឆាំងនឹងការបន្តឃុំខ្លួន ប៊ន សំណាង និង សុខ សំអឿន ដែលបុរសពីរនាក់នេះ ត្រូវបានផ្តន្ទាទោសដោយបំពាន ពីបទសម្លាប់លោក ជា វិជ្ជា មេដឹកនាំសហជីពសេរីកម្មករកម្ពុជា ។

សូម្បីតែតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក៏បានប្រឈមមុខការរារាំង និងការបំភិតបំភ័យ ក្នុងខណៈចុះស៊ើបអង្កេតការរំលោភសិទ្ធិមនុស្សដែរ ។ នៅថ្ងៃទី៣ ខែធ្នូ លោក យ៉ាស់ ហ្គាយ បានប្រឈមមុខជាមួយមនុស្សមួយក្រុមដែលទំនងជានគរបាល និងទាហានស្រវឹងស្រា ខណៈដែលលោក បានចាកចេញពីកន្លែងប្រជុំមួយជាមួយប្រជាពលរដ្ឋនៅភូមិគងយុ ខេត្តរតនគីរី ។ (សូមអានទំព័រ ៣៤ ចំពោះព័ត៌មាន លំអិតអំពីទំនាស់ដីធ្លីនៅភូមិនេះ) ។ ទោះបីជាលោក យ៉ាស់ ហ្គាយ មានគោលការណ៍អាចធ្វើដំណើរទៅបានគ្រប់ទីកន្លែងដោយសេរីនៅទូទាំងប្រទេសក៏ដោយ ក៏លោកអភិបាលរងស្រុកអូរយ៉ាដាវ ឈ្មោះ អួន គិត និយាយថា លោកមិន ត្រូវមកជួបប្រជាពលរដ្ឋដោយគ្មានការអនុញ្ញាតទេ ។

## អ្នកជួយជនភៀសខ្លួន

ដោយគ្មានសញ្ញាអំពីការបញ្ឈប់ការធ្វើទុក្ខបុកម្នេញលើជនជាតិភាគតិចនៅតំបន់ខ្ពង់រាបភាគកណ្តាលប្រទេស វៀតណាម ការហូរចូលនូវអ្នកស្វែងរកការជ្រកកោនជនជាតិម៉ុងតាញ៉ាកនៅកម្ពុជា បន្តកើតមានក្នុងឆ្នាំ២០០៧ ហើយ

ជាមួយគ្នានេះ ការបន្តរាំង ការយាយីរំខាន និងរហូតដល់ការផ្តន្ទាទោសមនុស្សណាដែលទៅជួយពួកអ្នកភៀសខ្លួនទាំងនោះផង ។

ដូចឆ្នាំមុនៗដែរ រដ្ឋាភិបាលកម្ពុជាបានរៀបចំជាប្រព័ន្ធ ដើម្បីរារាំងការងាររបស់ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដែលមានគោលបំណងដើម្បីទៅជួបពួកអ្នកស្វែងរកសិទ្ធិជ្រកកោនទាំងនោះ។ ដោយគ្មានការិយាល័យនៅខេត្តតាមតំបន់ព្រំដែន រតនគិរី និងមណ្ឌលគិរី ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនត្រូវដាក់ពាក្យសុំការអនុញ្ញាតពីរដ្ឋាភិបាលដើម្បីធ្វើដំណើរទៅខេត្តទាំងនោះ នៅពេលដែលទទួលបានរបាយការណ៍ថា មានពួកអ្នកស្វែងរកសិទ្ធិជ្រកកោនមកពីប្រទេសវៀតណាម។ ដោយគ្មានមូលហេតុណាមួយដើម្បីឱ្យរដ្ឋាភិបាលធ្វើជាលេសក្នុងការមិនផ្តល់ការអនុញ្ញាត រដ្ឋាភិបាលតែងតែព្យាយាមធ្វើការពន្យារការអនុញ្ញាតនោះរហូតរាប់សប្តាហ៍ ឬ ពេលខ្លះរហូតដល់រាប់ខែ ដែលជាការផ្តល់ឱកាសយ៉ាងច្រើនលើសលុបដល់អាជ្ញាធរមូលដ្ឋានក្នុងការតាមរកនិងបញ្ជូនពួកអ្នកស្វែងរកសិទ្ធិជ្រកកោនដែលកំពុងលាក់ខ្លួននៅក្នុងព្រៃនោះ។

នៅក្នុងព្រឹត្តិការណ៍នានា ក្នុងឆ្នាំ២០០៧ បានបង្ហាញយ៉ាងច្បាស់អំពីលំនាំនៃការបង្កឧបសគ្គនេះ និងផលវិបាករបស់ករណីទាំងនេះ។ នៅថ្ងៃទី១៩ ខែមិនា ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានធ្វើសំណើជាផ្លូវការមួយទៅខេត្តរតនគិរី ដើម្បីជួបអ្នកស្វែងរកសិទ្ធិជ្រកកោនជនជាតិ ម៉ុងតាញ៉ា ដែលត្រូវបានរាយការណ៍ថា បានឆ្លងកាត់ព្រំដែនមកពីប្រទេសវៀតណាមនៅថ្ងៃទី១៥ ខែមិនា ។[១៩] នៅថ្ងៃទី២២ ខែមិនា គេបានទទួលរបាយការណ៍ថា ពួកម៉ុងតាញ៉ា ១០ នាក់ទៀតបានមកដល់ខេត្តរតនគិរីដែរ ។[២០]

ពេលនោះ អង្គការមិនមែនរដ្ឋាភិបាលជាតិបានរាយការណ៍ថា នៅថ្ងៃទី២៣ ខែមិនា ពួកម៉ុងតាញ៉ា ១០ នាក់នៃក្រុមដំបូងត្រូវបាននគរបាលចាប់ខ្លួន ហើយត្រូវបានបញ្ជូនទៅប្រទេសវៀតណាមវិញ ក្រោយពីបានធ្វើដំណើរមកដល់ក្រុងបានលុង ទីរួមខេត្តរតនគិរី ក្នុងគោលបំណងដើម្បីទាក់ទងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន។[២១] ដំបូង អាជ្ញាធរបានបដិសេធចំពោះការបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញដោយខុសច្បាប់នោះ ប៉ុន្តែក្រោយមក មន្ត្រីជាន់ខ្ពស់ខេត្តម្នាក់សុំមិនបញ្ចេញឈ្មោះបានបញ្ជាក់ថា រឿងនេះពិតជាបែបនោះមែន ។[២២]

---

[១៩] ថេត សម្បត្តិ និង ខូក្លា ជីលីសុន : *ជនជាតិ ម៉ុងតាញ៉ា ១០ នាក់ បានស្វែងរកសិទ្ធិជ្រកកោននៅរតនគិរី* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៧។

[២០] ថេត សម្បត្តិ: *ជនជាតិ ម៉ុងតាញ៉ា ១០ នាក់ទៀត មកពីប្រទេសវៀតណាម បានលាក់ខ្លួនក្នុងខេត្តរតនគិរី* កាសែតឌឹ ឃែមបូឌាដេលីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០៧។

[២១] ថេត សម្បត្តិ និង សូស៊ី ឃីម : *អង្គការមិនមែនរដ្ឋាភិបាលបានចោទប្រកាន់ថា ជនជាតិម៉ុងតាញ៉ា ១០ នាក់ ត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៧ ។

[២២] ថេត សម្បត្តិ និង មីសែល វ៉ាឆុន : *ពួកម៉ុងតាញ៉ាលាក់ខ្លួន កាន់តែមានការអស់សង្ឃឹមខ្លាំងនៅក្នុងព្រៃ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៧ ។

នៅថ្ងៃទី៣១ ខែមិនា ពួកម៉ុងតាញ៉ាស្វែងរកសិទ្ធិជ្រកកោន ១៥ នាក់ទៀតបានមកដល់ខេត្ត ប៉ុន្តែលិខិតអនុញ្ញាតរបស់រដ្ឋាភិបាលនៅមិនទាន់ធ្លាក់មកដល់នៅឡើយ ។ មន្ត្រីអង្គការមិនមែនរដ្ឋាភិបាលម្នាក់បានរាយការណ៍ថា ពួកអ្នកលាក់ខ្លួនក្នុងព្រៃកំពុងជួបប្រទះបញ្ហាខ្វះស្បៀងអាហារ ហើយខ្លះកើតជម្ងឺគ្រុនចាញ់ ។ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានបញ្ជាក់ថាខ្លួនបានទៅសួររដ្ឋាភិបាល "រាល់ថ្ងៃ" អំពីលិខិតអនុញ្ញាតនោះ ។[២៣]

នៅថ្ងៃទី១៣ ខែមេសា យោងតាមរបាយការណ៍របស់អង្គការសិទ្ធិមនុស្សនៅក្នុងខេត្តមួយបានរាយការណ៍ថា មានពួកម៉ុងតាញ៉ា ៥ នាក់ទៀតត្រូវបានចាប់ខ្លួន និងបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញ ។ ទីបំផុត រដ្ឋាភិបាលបានចេញលិខិតអនុញ្ញាតធ្វើដំណើរមួយច្បាប់ឱ្យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅថ្ងៃទី១៣ ខែមេសា ហើយបេសកកម្មបានចេញដំណើរនៅថ្ងៃទី១៨ ។ នៅថ្ងៃនោះដែរ កងកម្លាំងនគរបាល និងយោធាប្រដាប់ដោយអាវុធបានឡោមព័ទ្ធចម្ការរបស់ជនជាតិដើមភាគតិចមួយកន្លែងនៅស្រុកអណ្តូងមាស ខេត្តរតនគីរី ហើយទាមទារឱ្យគេប្រាប់ពីកន្លែងលាក់ខ្លួនរបស់ពួកអ្នកស្វែងរកសិទ្ធិជ្រកកោនទាំងនោះ ។[២៤]

នៅថ្ងៃទី២០ ខែមេសា ជាងមួយខែក្រោយពីការសុំលិខិតលើកទីមួយ — បុគ្គលិកឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានទៅដល់ស្រុកអណ្តូងមាស ហើយនៅទីនោះពួកគេបានជួបពួកម៉ុងតាញ៉ា ១៨ នាក់ ហើយនាំពួកនោះមកដាក់ក្រោមកិច្ចការពាររបស់ខ្លួន ។ ខណៈពេលរដ្ឋាភិបាលបានភូតកុហកទាំងស្រុងនោះ យ៉ាងហោចណាស់មានពួកអ្នកស្វែងរកសិទ្ធិជ្រកកោន ១៥ នាក់ ត្រូវចាប់បានបញ្ជូនត្រឡប់ទៅវិញ ហើយសុខភាពរបស់អ្នកនៅសល់ជួបបញ្ហាយ៉ាងធ្ងន់ធ្ងរ ។[២៥]

ក្រោយមកស្រាប់តែលេចឮថា នគរបាលបានចាប់ខ្លួនជនជាតិកម្ពុជា ដែលជាជនជាតិភាគតិចចារ៉ាយ ៣ នាក់ ដែលបាននាំពួកស្វែងរកសិទ្ធិជ្រកកោន ១៨ នាក់ទៅជួបឧត្តមស្នងការអង្គការសហប្រជាជាតិ ។ បុរសទាំង ៣ នាក់នោះត្រូវបានឃុំខ្លួនបណ្តោះអាសន្នរង់ចាំការវិនិច្ឆ័យទោសដោយតុលាការខេត្តរតនគីរី ។ នៅទីនោះ ចៅក្រម ឈ្មោះ អាន សំណាង បានបដិសេធមិនព្រមដោះលែងបុរសទាំង ៣ ឱ្យនៅក្រៅឃុំទេ លុះត្រាតែជនសង្ស័យទី ៤ ចូលមកសារភាពនៅតុលាការ ទើបគាត់ព្រមដោះលែង ដូច្នេះមានន័យថា តុលាការបានប្រើប្រាស់បុរសទាំង ៣ នាក់នេះជាចំណាប់ខ្មាំង ។ បុរសទាំង ៣ នាក់ នោះ ត្រូវបានចោទពីបទនាំជនអន្តោប្រវេសន៍ចូលស្រុកខុសច្បាប់ ទោះបីជាមានមនុស្សជាច្រើនអះអាងថា បុរសទាំង ៣ នាក់នោះ គ្រាន់តែជួយពួកអ្នកស្វែងរកសិទ្ធិជ្រកកោននៅក្នុងទឹកដីកម្ពុជាប៉ុណ្ណោះ ដូចជាជួយទិញស្បៀងអាហារ និងសម្ភារៈផ្សេងៗសម្រាប់ក្រុមនោះ ខណៈដែលពួកគេលាក់ខ្លួនទាំងនោះរង់ចាំឧត្តមស្នងការអង្គការ

---

[២៣] ថេត សម្បត្តិ: *ពួកម៉ុងតាញ៉ា ១៥ នាក់ទៀត ស្វែងរកសិទ្ធិជ្រកកោននៅខេត្តរតនគីរី* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៧ ។

[២៤] យន់ សាមាន: *បុគ្គលិកសិទ្ធិមនុស្សបាននិយាយថា នគរបាលកំពុងស្វែងរកពួកម៉ុងតាញ៉ា* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៨ ។

[២៥] ថេត សម្បត្តិ: *អង្គការសហប្រជាជាតិបានដាក់ពួកម៉ុងតាញ៉ាដែលស្វែងរកសិទ្ធិជ្រកកោន ១៨ នាក់ ស្ថិតនៅក្រោមកិច្ចការពាររបស់ខ្លួន* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ ។

សហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនមកជួយ។[២៦] ក្រោយមកបុរសទាំង ៣ នាក់ នោះ ត្រូវបានដោះលែងនៅថ្ងៃទី ១៦ ខែកញ្ញា ក្រោយពីបានជាប់ឃុំជិត ៥ ខែ នៅក្នុងពន្ធនាគារខេត្តរតនគិរី។[២៧]

## ព្រះសង្ឃសកម្មជនខ្មែរកម្ពុជាក្រោម

ការតវ៉ាដោយសន្តិវិធី ដែលធ្វើឡើងបន្តបន្ទាប់គ្នាដោយព្រះសង្ឃខ្មែរកម្ពុជាក្រោម ត្រូវប្រឈមមុខនឹងកំណើននៃអំពើហិង្សា ដែលប្រព្រឹត្តពីសំណាក់អាជ្ញាធរកម្ពុជានៅឆ្នាំ២០០៧។ ខណៈដែលការទាមទារមានសន្ទុះខ្លាំងក្លា ព្រះសង្ឃសកម្មជនមួយអង្គបានប្រឈមមុខនឹងអំពើហិង្សារហូតដល់សុគតនៅក្នុងស្ថានភាពគួរឱ្យសង្ស័យមួយ ហើយព្រះសង្ឃមួយអង្គទៀត ត្រូវបានចាប់ខ្លួនបញ្ជូនទៅប្រទេសវៀតណាមដោយខុសច្បាប់ ព្រមទាំងត្រូវជាប់ពន្ធនាគារពីបទល្មើសខាងនយោបាយ។

សកម្មជនខ្មែរក្រោមបានធ្វើការតស៊ូយ៉ាងយូរអង្វែង ដោយសមាជិកខ្មែរភាគតិចនៅតំបន់ភាគខាងត្បូងនៃប្រទេសវៀតណាមហៅថាខ្មែរកម្ពុជាក្រោម ដែលត្រូវទទួលរងការរើសអើងក្រោមការរៀបចំជាប្រព័ន្ធពីសំណាក់អាជ្ញាធរវៀតណាម ។ បញ្ហានេះបានចាប់ផ្តើមខ្លាំងនៅដើមឆ្នាំ២០០៧ នៅពេលដែលសកម្មជនព្រះសង្ឃជាច្រើនអង្គត្រូវបានចាប់ផ្សឹក និងឃុំខ្លួន ក្រោយពីមានការតវ៉ាដោយសន្តិវិធីដើម្បីសិទ្ធិសាសនា និងសិទ្ធិផ្សេងៗទៀត។ សកម្មជននានាបានចាប់ផ្តើមលួចឆ្លងដែនចូលមកប្រទេសកម្ពុជាដើម្បីគេចខ្លួនពីការបង្ក្រាប ហើយភ្លាមៗនោះព្រំដែនក៏ត្រូវបានបិទឈប់ឱ្យខ្មែរកម្ពុជាក្រោមរស់នៅប្រទេសវៀតណាមឆ្លងកាត់ចូលមកទៀត។

នៅថ្ងៃទី២៧ ខែកុម្ភៈ ព្រះសង្ឃមួយក្រុមមានសមាជិក ៥២ អង្គ បានធ្វើបាតុកម្មនៅជិតស្ថានទូតប្រទេសវៀតណាមនៅទីក្រុងភ្នំពេញ ដើម្បីគាំទ្របងប្អូនជាសង្ឃនៅប្រទេសវៀតណាម។ ព្រះសង្ឃទាំងនោះបានប្រឈមមុខជាមួយកម្លាំងនគរបាល និងនគរបាលអន្តរាគមន៍ជាង ១៥០ នាក់ ដែលបំពាក់ដោយអាវុធ ខែល ឧស្ម័នបង្ហូរទឹកភ្នែក ដំបងឆក់ និងកាំភ្លើង។ អាជ្ញាធរបានចាប់បង្ខំព្រះសង្ឃទាំងនោះចូលរថយន្តក្រុងមួយ ដើម្បីដឹកយកទៅដោះស្បង់ ចីពរ ប៉ុន្តែពួកបុគ្គលិកសិទ្ធិមនុស្សបានចូលអន្តរាគមន៍រារាំងមិនឱ្យធ្វើបែបនោះបាន។ ការតវ៉ានោះប្រព្រឹត្តទៅដោយមិនមានអំពើហិង្សាទេ ប៉ុន្តែពួកអ្នកសង្កេតការណ៍មានការតក់ស្លុតយ៉ាងខ្លាំងចំពោះការប្រើប្រាស់កម្លាំងដ៏លើសលប់ ដើម្បីទប់ទល់ប្រឆាំងនឹងក្រុមព្រះសង្ឃព្រះពុទ្ធសាសនាដែលធ្វើការទាមទារដោយសន្តិវិធីនេះ។

---

[២៦] យន់ សាមាន: *អង្គការសហប្រជាជាតិបានទាមទារឱ្យតុលាការខេត្តរតនគិរី ចាត់វិធានការលើករណីជួញដូរមនុស្ស* កាសែត ឌឹ ឃែមបូដេលីថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៧។

[២៧] ព័ត៌មាននេះទទួលពីអង្គការអាដហុក ក្នុងខែកុម្ភៈ ឆ្នាំ២០០៨។

ក្រោយមកនៅថ្ងៃដដែលនោះ ព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយអង្គព្រះនាម អ៊ាង សុខធឿន ដែលបានចូលរួមក្នុងការតវ៉ា ត្រូវបានគេលួចធ្វើគតនៅក្នុងបរិវេណវត្តមួយក្នុងស្រុកអង្គស្នួល ខេត្តកណ្ដាល ដោយពិនិត្យឃើញមានស្នាមអារ ៣ កន្លែងនៅលើករបស់ព្រះសង្ឃនោះ។ ភ្លាមៗ នោះ អាជ្ញាធរមូលដ្ឋានបានប្រកាសថា ព្រះសង្ឃអង្គនោះបានធ្វើអត្តឃាត ហើយសពព្រះសង្ឃនោះត្រូវបានយកទៅបញ្ចុះ រយៈពេល ២៤ ម៉ោងក្រោយ ដោយមិនទាន់បានធ្វើកោសល្យវិច្ច័យអ្វីឡើយ។ ព្រះសង្ឃ សុខ ធឿន ទើបតែនិមន្តពីខេត្តទ្រាំងនៅភាគខាងត្បូងនៃប្រទេសវៀតណាម ហើយជាមនុស្សជិតស្និទ្ធជាមួយលោក យឿន ស៊ីន ប្រធានសមាគមព្រះសង្ឃព្រះពុទ្ធសាសនាខ្មែរកម្ពុជាក្រោម ។ សមាគមខ្មែរកម្ពុជាក្រោមមួយក្រុមដែលមានសមាជិកព្រះសង្ឃចំនួន ៦ អង្គការ បានដាក់ពាក្យបណ្ដឹងទៅតុលាការខេត្ត ដើម្បីស្នើសុំឱ្យអាជ្ញាធរគាស់ព្រះសព ដើម្បីធ្វើកោសល្យវិច្ច័យ និងធ្វើការស៊ើបអង្កេតឱ្យបានត្រឹមត្រូវ ។ តុលាការមិនបានផ្ដល់ការអនុញ្ញាត ហើយអាជ្ញាធរក៏មិនបានធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់ក្នុងករណីសុគតនេះដែរ។

> *"អាត្មាគ្រាន់តែសុំពួកគេថា កុំឱ្យរំលោភលើសិទ្ធិព្រះសង្ឃខ្មែរកម្ពុជាក្រោម ស្រាប់តែមានអ្នកណាចោលដុំថ្មមួយដុំចំព្រះកេសអាត្មា"*
>
> ព្រះសង្ឃខ្មែរកម្ពុជាក្រោមព្រះនាម លឹម យុទ្ធ

ដោយសារតែបញ្ហានេះមិនអាចស្ងប់ស្ងាត់បាន ហើយចេះតែមានការវិវត្តន៍ទៅមុខ ការតវ៉ានៅភ្នំពេញក៏ចេះតែកើនឡើងថែមទៀត។ នៅថ្ងៃទី២០ ខែមេសា ព្រះសង្ឃខ្មែរកម្ពុជាក្រោមប្រហែល ៥០ អង្គ បានប៉ុនប៉ងនាំយកលិខិតទៅប្រគល់ជូនស្ថានទូតប្រទេសវៀតណាម ដើម្បីតវ៉ាចំពោះការផ្សឹក ឬ បាត់ខ្លួនព្រះសង្ឃនៅប្រទេសវៀតណាម។ ក្រោយពីនគរបាលបានបិទផ្លូវមិនឱ្យចូលទៅជិតស្ថានទូតប្រទេសវៀតណាម ព្រះសង្ឃទាំងនោះបាននាំគ្នានិមន្តតាមដងវិថីនានាក្នុងរាជធានីភ្នំពេញ ហើយក៏ត្រូវបានព្រះសង្ឃ និងជនស៊ីវិលមួយក្រុមមិនស្គាល់អត្តសញ្ញាណចេញពីវត្តឧណ្ណាលោមបានមករារាំងផ្លូវ។ ជម្លោះរវាងព្រះសង្ឃទាំងពីរក្រុមនេះ បានកើតឡើងបណ្ដាលឱ្យព្រះសង្ឃមួយចំនួនរងរបួស។ ព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយអង្គព្រះនាម លឹម យុទ្ធ បានរងរបួសផ្នែកខាងលើភ្នែក ហើយបានមានសង្ឃដីកាប្រាប់សារព័ត៌មានថា "អាត្មាគ្រាន់តែសុំពួកគេថា កុំឱ្យរំលោភលើសិទ្ធិព្រះសង្ឃខ្មែរកម្ពុជាក្រោម ស្រាប់តែមាននរណាម្នាក់ចោលដុំថ្មមួយដុំត្រូវចំព្រះកេសអាត្មា"។ [២៨] ក្រោយមកនៅក្នុងថ្ងៃនោះដែរ ព្រះសង្ឃមួយអង្គដែលបានចូលរួមក្នុងការតវ៉ានោះដែរ ត្រូវបានមនុស្សមិនស្គាល់អត្តសញ្ញាណ ៦ នាក់ ព្រួតគ្នាវាយ ក្រោយពីត្រឡប់មកដល់វត្តវិញនៅទីក្រុងភ្នំពេញ។[២៩]

នៅថ្ងៃទី៨ ខែមិថុនា សម្ដេចពោធិវង្ស នួន ង៉ែត មេគណៈសង្ឃរាជធានីភ្នំពេញ បានចេញសេចក្ដីណែនាំមួយជាមួយរដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា ឃុន ហាំង បញ្ញត្តិហាមព្រះសង្ឃទូទាំងប្រទេសមិនឱ្យចូលរួមក្នុងការ

---

[២៨] កាយ គីមសុងៈ *ព្រះសង្ឃទីក្រុងភ្នំពេញ និងព្រះសង្ឃខ្មែរកម្ពុជាក្រោមបានវាយប្រហារគ្នាក្នុងពេលនិមន្តតវ៉ា* កាសែត ឌឹ ឃែមបូឌាដេលី ថ្ងៃទី២១-២២ ខែមេសា ឆ្នាំ២០០៧។

[២៩] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ។

ទាមទារតវ៉ាដោយសន្តិវិធីណាមួយឡើយ ដែលអាចបណ្តាលឱ្យ "ខូចសណ្តាប់ធ្នាប់សាធារណៈ"។ សម្តេចពោធិវង្ស នួន ង៉ែត បានមានសង្ឃដីកាថា ព្រះសង្ឃអង្គណាចូលរួមក្នុងការតវ៉ា "ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដោយអង្គឯង "។ សម្តេច ហេង សំរិន ប្រធានរដ្ឋសភាជាតិ និងជាប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា បានមានប្រសាសន៍នៅក្នុងសេចក្តីប្រកាសដែលមិនទាន់បានចេញផ្សាយរហូតដល់ចុងខែនោះថា "ដើម្បីរក្សាស្ថេរភាពសង្គម "។[៣០] សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ លោក សឹន សូប៊ែរ បានមានប្រសាសន៍ថា ការហាមឃាត់ព្រះសង្ឃមិនឱ្យធ្វើបាតុកម្មដោយសន្តិវិធី គឺជាការរំលោភលើរដ្ឋធម្មនុញ្ញ។[៣១]


ព្រះសង្ឃ ទឹម សាខន

នៅថ្ងៃទី៣០ ខែមិថុនា ព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយអង្គព្រះនាម ទឹម សាខន ដែលជាសកម្មជនលេចធ្លោជាងគេ ក្នុងការទាមទារសិទ្ធិខ្មែរកម្ពុជាក្រោម គង់នៅវត្តភ្នំដិន ខាងជើងនៃខេត្តតាកែវ បានបាត់ខ្លួនភ្លាមៗ ក្រោយពីត្រូវបានមនុស្សមួយក្រុមចាប់ផ្សឹក ក្រោមបញ្ជារបស់ព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស ។ នៅក្នុងសេចក្តីថ្លែងការណ៍ ព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស មានសង្ឃដីកាថា ព្រះសង្ឃ ទឹម សាខន បាន រំលោភលើវិន័យសង្ឃ ហើយបានធ្វើឱ្យមានការបែកបាក់សាមគ្គីជាតិ និងអន្តរជាតិ ជាពិសេសរវាងប្រទេសទាំងពីរកម្ពុជា និងវៀតណាម "។[៣២] នៅថ្ងៃនោះដែរ អ្នកភូមិបាន រាយការណ៍ថា គេឃើញមន្ត្រីសន្តិសុខកម្ពុជាបានដឹកព្រះសង្ឃ ទឹម សាន តាមរថយន្តមួយគ្រឿងយកទៅឆ្ងាយ។ ក្រោយមក គ្មានអ្នកណាដឹងថា គេនាំលោកទៅណាទេ រហូតដល់ថ្ងៃទី២ ខែសីហា ទើបស្ថានទូតប្រទេសវៀតណាមប្រចាំកម្ពុជាបានប្រកាសថា ព្រះសង្ឃ ទឹម សាខន ត្រូវបានឃុំឃាំងនៅវៀតណាម "រង់ចាំការកាត់ទោសតាមច្បាប់ស្តីពីការបំផ្លិចបំផ្លាញសាមគ្គីភាពខាងនយោបាយ"។ លោក ខៀវ សុភ័ក្រ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានមានប្រសាសន៍យ៉ាងចម្លែកថា ព្រះសង្ឃ ទឹម សាខន បានស្នើឱ្យគេបញ្ជូនខ្លួនទៅប្រទេសវៀតណាម ក្នុងពេលនោះដែរសារព័ត៌មានវៀតណាមបានផ្សាយថា ព្រះសង្ឃ ទឹម សាខន ត្រូវបានចាប់ខ្លួនខណៈពេលព្យាយាមឆ្លងចូលប្រទេសវៀតណាមដោយខុសច្បាប់។[៣៣] នៅថ្ងៃទី៨ ខែវិច្ឆិកា តុលាការខេត្តអាងយ៉ាងនៅប្រទេសវៀតណាមបានផ្តន្ទាទោសលោកដាក់ពន្ធនាគារមួយឆ្នាំ និងសាកល្បង ១៤ ឆ្នាំ។[៣៤]

[៣០] ឆាយ ចានីដា: *ក្រសួង និងព្រះសង្ឃរាជ្យបានអំពាវនាវដល់ព្រះសង្ឃកុំឱ្យនិមន្តតវ៉ា* កាសែត ឌឹ ឃែមបូឌាដេលី ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧។

[៣១] សម រឹទ្ធិ និង ឆាល ម៉ាក់ដឺមីដ : *ហាមមិនឱ្យព្រះសង្ឃតវ៉ា ត្រូវបានហៅថា "ពុំមែនអ្នកកាន់ព្រះសាសនាទេ"* កាសែត ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧។

[៣២] យន់ សាមាន: *ព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស បានបញ្ជាឱ្យផ្សឹកព្រះសង្ឃខ្មែរកម្ពុជាក្រោម* កាសែត ឌឹ ឃែមបូឌាដេលី ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៧។

[៣៣] យន់ សាមាន: *ព្រះសង្ឃដែលបាត់ខ្លួន កំពុងប្រឈមមុខការកាត់ទោសនៅវៀតណាម* កាសែត ឌឹ ឃែមបូឌាដេលី ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៧។

[៣៤] គុជ ណារិនេះ: *ព្រះសង្ឃខ្មែរកម្ពុជាក្រោមត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារមួយឆ្នាំពីបទប្រឆាំងវៀតណាម* កាសែត ឌឹ ឃែមបូឌាដេលី ថ្ងៃទី១០-១១ ខែវិច្ឆិកា ឆ្នាំ២០០៧។

មិនអស់ចិត្តចំពោះការបញ្ជូនខ្លួនព្រះសង្ឃ ទឹម សាខន ទៅប្រទេសវៀតណាមដោយខុសច្បាប់ អាជ្ញាធរកម្ពុជាក៏បានបង្ខូចឈ្មោះលោក ដោយការបង្ក្រាបលើការពិភាក្សាករណីនេះ និងឆាឆៅរំខានទូវរាល់ការលើកឡើងស្តីពីការគាំទ្រចំពោះបុព្វហេតុរបស់លោក។ នៅខែកក្កដា សកម្មជនសិទ្ធិមនុស្សម្នាក់ត្រូវបានឃុំខ្លួន ហើយឧបករណ៍ផ្ទាល់ខ្លួនគាត់ត្រូវបានរឹបអូសនៅល្ងាចថ្ងៃមួយ មុនការបើកវេទិកាសាធារណៈនៅខេត្តតាកែវ ដើម្បីពិភាក្សាអំពីការបាត់ខ្លួននេះ។ នៅខែកញ្ញា សម្តេចនាយករដ្ឋមន្ត្រីបានឆ្លើយតបលិខិតរបស់អតីតព្រះមហាក្សត្រ នរោត្តម សីហនុ ចំពោះករណីព្រះសង្ឃ ទឹម សាខន ដោយបានចោទប្រកាន់ព្រះសង្ឃអំពីសកម្មភាពខុសច្បាប់ ដូចជាការវាយប្រហារព្រះសង្ឃដូចគ្នាដោយពូថៅ ព្រមទាំងការចោទប្រកាន់ជាសាធារណៈពីបទល្មើសពាក់ព័ន្ធស្រីញី និងមើលវីដេអូអាសគ្រាមនៅក្នុងបន្ទប់។[៣៥] នៅខែវិច្ឆិកា អង្គការសិទ្ធិមនុស្សមួយចំនួនបានធ្វើបុណ្យដើម្បីសម្តែងការគោរពព្រះសង្ឃ ទឹម សាខន ក៏ត្រូវបានមន្ត្រីអាជ្ញាធរស្រុកអុកឡុករំខានការជួបជុំធ្វើពិធីបុណ្យនោះ។[៣៦]



នគរបាលវាយព្រះសង្ឃនៅខាងក្រៅស្ថានទូតប្រទេសវៀតណាមនាថ្ងៃទី១៧ ខែធ្នូ

នៅថ្ងៃទី១៧ ខែធ្នូ ព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយក្រុមដែលមានគ្នា ៤៨ អង្គ បានព្យាយាមយកលិខិតតវ៉ាមួយច្បាប់ទៅជូនស្ថានទូតប្រទេសវៀតណាម ដើម្បីទាមទារឱ្យមានការដោះលែងព្រះសង្ឃ ទឹម សាខន និងព្រះសង្ឃផ្សេងៗទៀតដែលត្រូវបានឃុំឃាំងនៅប្រទេសវៀតណាម។ ពេលដែលព្រះសង្ឃទាំងនោះទៅជិតដល់ស្ថានទូត កម្លាំងនគរបាលមួយក្រុមធំដែលបំពាក់ដោយដំបងឆក់ និងកាំភ្លើង ចូលវាយបំបែកហ្វូងព្រះសង្ឃ។ ពេលដែលព្រះសង្ឃរត់ត្រឡប់ក្រោយនគរបាលបន្តដេញតាមព្រះសង្ឃទាំងនោះ ចម្ងាយពីរបីផ្លូវ ហើយវាយ និងទាត់ធាក់ព្រះសង្ឃទាំងនោះ។ ព្រះសង្ឃពីរអង្គបានរងរបួសយ៉ាងធ្ងន់ធ្ងរ មួយអង្គសន្លប់ដោយ ការវាយចំព្រះកេសដោយដំបងឆក់។[៣៧] ស្នងការនគរបាលរាជធានីភ្នំពេញ លោក ទូច ណារ៉ុថ បានមានប្រសាសន៍ថា នគរបាល "គ្រាន់តែធ្វើអ្វីដើម្បីធានាសន្តិសុខដល់ស្ថានទូតប្រទេសវៀតណាមតែប៉ុណ្ណោះ"។[៣៨]

---

[៣៥] លិខិតរបស់នាយករដ្ឋមន្ត្រីចុះថ្ងៃទី២ ខែកញ្ញា ផ្ញើថ្វាយសម្តេច នរោត្តម សីហនុ។ សូមអានច្បាប់ដើម និងសេចក្តីបកប្រែដែលមាននៅក្នុងគេហទំព័រ: http://www.khmer.net/?q=node/1076

[៣៦] អាជ្ញាធរមូលដ្ឋានបានបង្អាក់ពិធីបុណ្យសាសនានៅថ្ងៃបុណ្យឯករាជ្យជាតិ អត្ថបទលីកាដូចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៧។ http://www.licadho.org/articles/20071116/68/index.html

[៣៧] *ព្រះសង្ឃខ្មែរកម្ពុជាក្រោមត្រូវនគរបាលក្រុងភ្នំពេញដេញវាយ និងបណ្តាលឱ្យរងរបួស* សេចក្តីថ្លែងព័ត៌មានរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និងលីកាដូថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៧។

[៣៨] វង្ស សុខេង: *ភាគីទាំងពីរបានត្រជាក់វិញ ក្រោយពីការប៉ះទង្គិចគ្នា* កាសែត ភ្នំពេញប៉ុស្តិ៍ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ដល់ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨។

(១៨) របាយការណ៍សង្ខេបរបស់លីកាដូ

រដ្ឋាភិបាលបានបន្តព្យាយាមធ្វើការកែតម្រូវចំពោះការផ្សឹកព្រះសង្ឃ ទឹម សាខន ហើយក្នុងខណៈពេលនេះដែរ គេពុំអាចពន្យល់បានទេអំពីមូលដ្ឋានច្បាប់ចំពោះការបញ្ជូនព្រះសង្ឃ ទឹម សាខន ទៅប្រទេសវៀតណាមនោះ។ នៅក្នុងការឆ្លើយតបកាលពីខែមករា ឆ្នាំ២០០៨ ទៅនឹងតំណាងពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស រដ្ឋាភិបាលបាននិយាយថា ព្រះសង្ឃត្រូវបានផ្សឹក ដោយសារលោកមិន "គោរពបទបញ្ញត្តិព្រះពុទ្ធសាសនា"។ លិខិតនោះបានចោទប្រកាន់ព្រះសង្ឃ ទឹម សាខន ថាបានចែកផ្សាយព្រឹត្តិបត្រចេញផ្សាយដោយអង្គការមួយដែលមានមូលដ្ឋានបរទេស ដើម្បីធ្វើការតស៊ូមតិដោយ (សន្តិវិធី និងស្របច្បាប់) ដើម្បីសិទ្ធិរបស់ខ្មែរកម្ពុជាក្រោម។ លិខិតនោះក៏បានអះអាងផងដែរថា លោកបានរៀបចំធ្វើបាតុកម្មខុសច្បាប់ជាមួយព្រះសង្ឃចំនួនពីរដង ដោយប្រើពូថៅ និងដំបងវាយព្រះសង្ឃដូចគ្នា ដែលបណ្តាលឱ្យមនុស្សជាច្រើនរបួស (តាមមើលទៅនេះជាការបំផ្លើសយ៉ាងខ្លាំងចំពោះការតវ៉ានៅថ្ងៃទី២៧ ខែកុម្ភៈ និងថ្ងៃទី២០ ខែមេសា ដែលគ្មានប្រើប្រាស់ពូថៅ ឬ ដំបងណាមួយសោះ)។ រដ្ឋាភិបាលបានបញ្ជាក់ថា ព្រះសង្ឃ ទឹម សាខន ត្រូវបានផ្សឹកដោយសារលោកបានរំលោភលើវិន័យព្រះពុទ្ធសាសនា ហើយលោក "ពេលនោះកំពុងត្រូវបានឃុំឃាំងដោយអាជ្ញាធរប្រទេសវៀតណាម" ដោយគ្មានការបកស្រាយអំពីការបញ្ជូនលោកទៅទីនោះ ដោយអាជ្ញាធរកម្ពុជាឡើយ។

វាសនារបស់ព្រះសង្ឃ ទឹម សាខន បញ្ជាក់អំពីស្ថានភាពមិនច្បាស់លាស់របស់បងប្អូនខ្មែរកម្ពុជាក្រោមនៅកម្ពុជា ហើយជាពិសេសវាសនារបស់សកម្មជនដែលបានភៀសខ្លួនពីការធ្វើទុក្ខបុកម្នេញនៅប្រទេសវៀតណាម។ រដ្ឋាភិបាលបានបញ្ជាក់ថា រដ្ឋាភិបាលបានចាត់ទុកខ្មែរកម្ពុជាក្រោមជាពលរដ្ឋខ្មែរដែរ ដែលមានន័យថា ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននៅប្រទេសកម្ពុជាចាត់ទុកថា ពួកអ្នកទាំងនោះគ្មានសិទ្ធិស្វែងរកសិទ្ធិជ្រកកោននៅក្នុងប្រទេសកម្ពុជានេះបានទេ។ ការិយាល័យនេះតែងតែបដិសេធពាក្យសុំសិទ្ធិជ្រកកោនរបស់សកម្មជនខ្មែរប្រទេសកម្ពុជាក្រោម ដែលបានភៀសខ្លួនពីប្រទេសវៀតណាម ពីព្រោះអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននេះបានលើកឡើងថា អ្នកទាំងនោះមានសុវត្ថិភាព និងមានកិច្ចការពារគ្រប់គ្រាន់ជាពលរដ្ឋកម្ពុជា។ ប៉ុន្តែ ដូចដែលឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានលើកឡើងអំពីករណីការបញ្ជូនព្រះសង្ឃ ទឹម សាខន ថា "វាជាការរំលោភយ៉ាងខ្លាំងលើធម្មនុញ្ញស្តីពីការហាមឃាត់ការនិរទេសពលរដ្ឋខ្មែរ ប្រសិនបើខ្មែរក្រោមមានស្ថានភាពជាពលរដ្ឋខ្មែរ ។ ប្រសិនបើគេគ្មានទេ ពេលនោះខ្មែរក្រោមណាដែលអះអាងថាបានទទួលរងការធ្វើទុក្ខបុកម្នេញ គួរត្រូវបានអនុញ្ញាតឱ្យស្វែងរកសិទ្ធិជាជនភៀសខ្លួនតាមកតិកាសញ្ញាពាក់ព័ន្ធនានា ទៅនឹងស្ថានភាពនៃជនភៀសខ្លួននោះ ដែលកម្ពុជាបានចុះហត្ថលេខា"។[៣៩]

---

[៣៩] *តួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស* របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ឧត្តមស្នងការ និងអគ្គលេខាធិការ – A/HRC/7/56, ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។

## តំណាងសហជីពកម្មករ

ក្នុងឆ្នាំ២០០៧ តំណាងសហជីពកម្មករនៅតែជាគោលដៅនៃការគំរាមកំហែង ចាប់ចង បង្ករបួសស្នាម និងរហូតដល់មានអំពើធ្វើឃាតថែមទៀត ។

ការយាយីរំខានភាគច្រើនបានប្រព្រឹត្តមកលើពួកសហជីពដែលពាក់ព័ន្ធក្នុងការធ្វើកូដកម្ម និងបាតុកម្មផ្សេងៗ ។ ក្នុងខែមករា សកម្មជន ៣ នាក់ត្រូវបានចាប់ខ្លួននៅរាជធានីភ្នំពេញក្នុងពេលតវ៉ាដោយសន្តិវិធីនៅក្នុងក្រុមហ៊ុនទូរទស្សន៍ខ្សែកាបរាជធានីភ្នំពេញ ដើម្បីទាមទារឱ្យក្រុមហ៊ុនផ្តល់ការងារដល់បុគ្គលិក ៨ នាក់ ដែលត្រូវបានបណ្តេញចេញពីក្រុមហ៊ុនក្នុងឆ្នាំ២០០៦ កន្លងទៅ ដោយសារការចូលរួមបង្កើតសហជីព ។ ក្នុងខែឧសភា នគរបាលបានបាញ់គ្រាប់បែកផ្សែង ហើយកងសន្តិសុខបានបាញ់ឡើងលើដើម្បីបំបែកពួកកូដករជាង ១.០០០ នាក់ដែលជាកម្មកររោងចក្រកាត់ដេរមកពីរោងចក្រឈ្មោះ វី វើ វីច តិចតាល នៅស្រុកស្អាង ខេត្តកណ្តាល ។ កម្មករទាំងនោះបានទាមទារឱ្យរោងចក្រផ្តល់ការងារឱ្យកម្មករចំនួន ១០ នាក់ ឡើងវិញដែលត្រូវបានបណ្តេញចេញកាលពី ខែវិច្ឆិកា កន្លងទៅ ក្រោមការចោទប្រកាន់ថាបានបង្កើតសហជីពកម្មករ ។ ក្រោយពីមានការធ្វើកូដកម្មរួច ខាងរោងចក្រ វីវើវីច បានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌទៅតុលាការខេត្តកណ្តាល ដោយប្តឹងមេដឹកនាំសហជីពកម្មករចំនួន ៣ នាក់ ពីបទ "ញុះញង់"ឱ្យមានការរំជើបរំជួលនៅក្នុងរោងចក្រ ។ កូដកម្មនេះបានបន្តនៅថ្ងៃទី២១ ខែឧសភា ពេលកម្មករជាង ១.០០០ នាក់ បានឡោមព័ទ្ធមេដឹកនាំសហជីព ដើម្បីការពារកុំឱ្យអាជ្ញាធរនគរបាលប្រមាណ ១៥០ នាក់ នាំខ្លួនមេដឹកនាំទៅតុលាការដើម្បីសួរចម្លើយ ។ នៅខែវិច្ឆិកា តំណាងសហជីព ៤ នាក់ នៅរោងចក្រ ហ្វកជូន ហ្គាមេន និង ណៃធីង ត្រូវបានចាប់ខ្លួននៅខេត្តកណ្តាល ក្រោយពីកម្មករជាង ៨០០ នាក់ មកពីសម្ព័ន្ធប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានធ្វើកូដកម្ម ។ នគរបាលដែលបានវាយបំបែកកូដកម្មនោះ បានប្រើឧស្ម័នបង្ហូរទឹកភ្នែក ដោយអះអាងថា សកម្មជនទាំងនោះបានចោលដុំថ្មបណ្តាលឱ្យរបួសមន្ត្រីនគរបាល ។

សកម្មជនសហជីពក៏ជាក្រុមមនុស្សដែលត្រូវរងគ្រោះថ្នាក់ដោយអំពើហិង្សាលើរូបរាងកាយផងដែរ ។ កាលពីខែមករា លោក សែន ស៊ីធឿន អគ្គលេខាធិការសហជីពសេរីកម្មករនៅរោងចក្រស្បែកជើងមួយកន្លែងឈ្មោះ ព្រីម មៀ នៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ត្រូវបានមនុស្សមួយក្រុមមានគ្នា ៤-៥ នាក់ ព័ទ្ធវាយដោយប្រើប្រាស់បំពង់ទីបវាយក្បាលរបស់គាត់ ខណៈពេលគាត់ចេញពីធ្វើការ ។ នៅខែមេសា លោកស្រី ឆាំ សាមេន ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជានៅរោងចក្រកាត់ដេរមួយឈ្មោះ វីវ៉ាទីណូ ឪសាញ ក្នុងខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ត្រូវរងរបួសក្នុងពេលធ្វើកូដកម្មនៅខាងមុខរោងចក្រ ។ អ្នកស្រី ឆាំ សាមេន ដែលជាស្ត្រីមានផ្ទៃពោះ ត្រូវគេវាយដំ និងទាត់ធាក់បណ្តាលឱ្យមានស្នាមជាំ និងហើមពេញខ្លួន ។

ការវាយប្រហារដូចដែលបានរៀបរាប់មកនេះ ជាការបង្ហាញពីការបន្តអំពើហិង្សាឥតឈប់ឈរ ដែលបានសង្កេតឃើញកើតមានកាលពីឆ្នាំ២០០៦ កន្លងទៅ។ ជនរងគ្រោះពុំបានទទួលយុត្តិធម៌ទេ ហើយនៅក្នុងករណីជាច្រើន សកម្មជនសហជីពដែលបន្តសកម្មភាពរបស់ខ្លួនទោះបីជាមានការព្រមានក៏ដោយ ត្រូវបាត់បង់ការងារនៅឆ្នាំ ២០០៧។

## ព័ត៌មានថ្មី១: មេដឹកនាំសហជីពសេរីកម្មករនៅរោងចក្រ ប្រាយស្កាយ និងសាន់តិច

នៅក្នុងរបាយការណ៍ ស្តីពីការវាយប្រហារ និងគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៦ លីកាដូបានលាតត្រដាងនូវករណីជាច្រើនអំពីសមាជិកសហជីពសេរីកម្មករនៅព្រះរាជាណាចក្រកម្ពុជា នៅរោងចក្រ "ប្រាយស្កាយ" និងរោងចក្រ សាន់តិច ក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ ។ រយៈពេញមួយឆ្នាំ២០០៦ តំណាងសហជីពសេរីកម្មករនៅរោងចក្រទាំងពីរនេះ បានប្រឈមការគំរាមកំហែង និងការបង្កបួសស្នាមជាប់ៗគ្នា។

មន្ត្រីសហជីពសេរីកម្មករចំនួន ៤ នាក់ នៅរោងចក្រប្រាយស្កាយបានរងគ្រោះពីអំពើបង្ករបួសស្នាមក្នុងឆ្នាំ ២០០៦ ។ មកដល់ចុងឆ្នាំ២០០៧ គ្មានជនល្មើសណាម្នាក់ត្រូវបានផ្តន្ទាទោសសោះ។ លើសពីនេះទៅទៀត ពួកសហជីពទាំង ៤ នាក់ ជាមួយនឹងកម្មករជាច្រើននាក់ទៀត បានបាត់បង់ការងារនៅក្នុងរោងចក្រក្រោយពីបានចូលរួមក្នុងការធ្វើកូដកម្មកាលពីខែតុលា ឆ្នាំ២០០៦ កន្លងទៅ —ដោយបានប្រឈមមុខនឹងបញ្ហាលំបាកយ៉ាងខ្លាំងក្នុងការរកការងារថ្មី។ ពួកសកម្មជនសហជីពទាំងនោះ ជឿជាក់ថា ដោយសារតែសកម្មភាពសហជីពដែលបានអនុវត្តកន្លងមក ទើបពួកគេត្រូវមានឈ្មោះនៅក្នុងបញ្ជីខ្មៅរបស់រោងចក្រកាត់ដេរ។

លោក ជី សាម៉ុន ប្រធានសហព័ន្ធសហជីពសេរីកម្មករនៅរោងចក្រប្រាយស្កាយ ត្រូវបានបុរស ៧ នាក់ព្រួតគ្នាវាយយ៉ាងដំណំ ខណៈដែលលោកកំពុងដើរទៅផ្ទះ ក្រោយពីធ្វើការវេនយប់ចប់កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៦។ លោក សាម៉ុន បានស្គាល់មុខបុរសម្នាក់ក្នុងចំណោមបុរសទាំង ៧ នាក់ដែលព្រួតវាយលោក ហើយអ្នកនោះជាសមាជិករបស់សហជីពប្រឆាំងនៅក្នុងរោងចក្រនោះដែរ លោកបានរាយការណ៍ករណីនេះទៅនគរបាល និងដាក់ពាក្យបណ្តឹងទៅតុលាការរាជធានីភ្នំពេញ ប៉ុន្តែ នគរបាល និងតុលាការមិនបានចាត់វិធានការស៊ើបអង្កេតឱ្យបានហ្មត់ចត់ឡើយ។ លោក សាម៉ុន ជាសកម្មជនល្បីឈ្មោះនៅក្នុងសហជីពកម្មករ ហើយចាប់តាំងពីពេលដែលលោកត្រូវបានបណ្តេញចេញ លោករកការងារបានធ្វើតិចតួចបំផុត។ នៅដើមឆ្នាំ២០០៧ លោកទទួលបានការងារនៅក្នុងរោងចក្រកាត់ដេរមួយកន្លែង ហើយធ្វើបានត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះ ក៏ត្រូវរោងចក្របញ្ឈប់ការងារ។ មកដល់ចុងឆ្នាំ២០០៧ លោកនៅតែរកការងារធ្វើមិនទាន់បាននៅឡើយ ហើយជនល្មើសដែលបានវាយលោកនៅតែមិនទាន់ត្រូវបានផ្តន្ទាទោសនៅឡើយដែរ។

ប្រាំបួនថ្ងៃក្រោយពីមានការព្រួតវាយ លោក ជី សាម៉ុន និងសហការីរបស់លោកឈ្មោះ យ៉េង វណ្ណយុទ្ធ ក៏ត្រូវ

បានគេព្រួតវាយស្រដៀងគ្នានេះដែរ។ ហើយនៅថ្ងៃទី៨ ខែមិថុនា លោក ឡែម សិរីទ្ធិ ហិរញ្ញិកនៃសហព័ន្ធសហជីពកម្មករនៅរោងចក្រប្រាយស្កាយ ក៏ត្រូវបានមនុស្សមួយក្រុមមានគ្នាជាង ២០ នាក់ បានព្រួតគ្នាវាយ នៅពេលលោកចេញពីធ្វើការវេនយប់។ ករណីទាំងពីរដែលបានរៀបរាប់មកនេះ ជនល្មើសមិនត្រូវបានផ្តន្ទាទោសទេ ហើយជាលទ្ធផលជនរងគ្រោះជួបការលំបាកក្នុងការស្វែងរកការងារធ្វើនៅឆ្នាំ២០០៧។

ចុងក្រោយបង្អស់លោកស្រី ឯម ឆាយទៀង អនុប្រធានសហព័ន្ធសហជីពកម្មករនៅរោងចក្រប្រាយស្កាយត្រូវនគរបាលម្នាក់ដាល់គាត់មួយដៃចំមុខ ក្នុងពេលធ្វើកូដកម្មកាលពីខែតុលា ឆ្នាំ២០០៦ ។ ចាប់តាំងពីពេលនោះមក លោកស្រី ឆាយទៀង បានចាកចេញពីរោងចក្រនោះ ហើយដាក់ពាក្យសុំការងារធ្វើនៅក្នុងរោងចក្រកាត់ដេរប្រហែល ៤០ កន្លែង ដោយទទួលការងារតិចតួចបំផុត។ នៅខែសីហា ឆ្នាំ២០០៧ លោកស្រីទទួលបានការងារមួយ ប៉ុន្តែរយៈពេល ១ ខែ ក្រោយមក គេបានបណ្តេញគាត់ចេញពីការងារនោះទៀត។ ប្រធាននោះបានប្រាប់ថា លោកស្រីមិនអាចធ្វើការនៅក្នុងរោងចក្រនេះបានទេ ដោយសារលោកស្រីធ្លាប់ធ្វើជាសកម្មជនសហជីព ហើយបានដឹកនាំធ្វើកូដកម្មនៅរោងចក្រប្រាយស្កាយ។ នៅចុងឆ្នាំ លោកស្រីបានចូលធ្វើការនៅក្នុងរោងចក្រមួយផ្សេងទៀត ហើយក៏ត្រូវបានបញ្ឈប់ទៀត ក្រោយពីបានរអ៊ូរទាំអំពីលក្ខខណ្ឌការងារមិនល្អនៅក្នុងរោងចក្រនោះ។

ក្នុងពេលជាមួយគ្នានោះដែរ មន្ត្រីសហព័ន្ធសហជីពកម្មករនៅរោងចក្រជិតគ្នានោះ ដែលជារោងចក្រម្ចាស់តែមួយជាមួយរោងចក្រកាត់ដេរ សាន់តិច ក៏មិនបានទទួលភាពយុត្តិធម៌ពីបទបង្ករបួសស្នាមមកលើពួកគេនោះដែរ។ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៦ លោក ជ័យ រិទ្ធី អនុប្រធានសហព័ន្ធសហជីពកម្មករនៅរោងចក្រកាត់ដេរ សាន់តិច ត្រូវបានបុរសមិនស្គាល់អត្តសញ្ញាណព្រួតគ្នាធ្វើបាបលោក និងភរិយារបស់លោកដែលកំពុងមានផ្ទៃពោះ ដោយបុរសទាំងនោះបានចោលដុំថ្មមកលើពួកគាត់ ពេលដែលពួកគាត់កំពុងជិះម៉ូតូចេញពីធ្វើការទៅផ្ទះវិញ។ បួនខែក្រោយមក លោក ចយ ជិន អគ្គលេខាធិការនៃសហព័ន្ធសហជីពកម្មករនៅរោងចក្រកាត់ដេរសាន់តិចនោះ ត្រូវបានមនុស្សមិនស្គាល់អត្តសញ្ញាណពីរនាក់ ចោលដុំថ្ម និងវាយលោកដោយបំពង់ដែក។ អាជ្ញាធរមិនបានផ្តន្ទាទោសជនល្មើសក្នុងករណីទាំងពីរខាងលើនេះឡើយ ហើយបច្ចុប្បន្នបុរសទាំងពីរនាក់នេះ បានលាលែងពីតំណែងនៅក្នុងសហព័ន្ធសហជីពកម្មករនេះហើយ។

បែបផែននៃការគំរាមកំហែង និងអំពើហិង្សាដែលបានប្រព្រឹត្តមកលើមន្ត្រី សហព័ន្ធសហជីពកម្មករនៅរោងចក្រសាន់តិចក្នុងឆ្នាំ២០០៦ ត្រូវបានបន្ត និងរីកកាន់តែធំឡើងៗមកដល់ឆ្នាំ២០០៧ — ដោយប្រធានសហព័ន្ធសហជីពនេះត្រូវបានគេលួចធ្វើឃាតយ៉ាងសាហាវបំផុត។

## ករណីសិក្សា: ឃាតកម្មលោក ហ៊ី វុទ្ធី

ការវាយប្រហារដ៏គួរឱ្យតក់ស្លុតជាងគេបំផុតមកលើចលនាសហព័ន្ធសហជីពកម្មករក្នុងឆ្នាំ២០០៧ នេះ គឺកើតឡើងក្នុងខែកុម្ភៈ ដែលពេលនោះ លោក ហ៊ី វុទ្ធី ប្រធានសហជីពសេរីកម្មករនៅរោងចក្រ សាន់តិច ត្រូវបានបុរសមិនស្គាល់អត្តសញ្ញាណពីរនាក់លួចបាញ់សម្លាប់ ពេលដែលលោកចេញពីធ្វើការជិះម៉ូតូមកផ្ទះវិញ។ ប្រពន្ធរបស់លោកឈ្មោះ វ៉ា សុភ័ក្រ បានមកដល់កន្លែងកើតហេតុ ហើយបានឃើញថា ប្ដីរបស់នាងនៅរស់នៅឡើយ ប៉ុន្តែនគរបាលបានរារាំងគាត់ប្រហែល ៥ នាទី ដោយមិនអនុញ្ញាតឱ្យនាងនាំប្តីនាងទៅមន្ទីរពេទ្យទេ ។ ដោយការយឺតយ៉ាវក្នុងការបញ្ជូនទៅមន្ទីរពេទ្យ លោក វុទ្ធី បានដាច់ខ្យល់ស្លាប់តាមផ្លូវ ។

មុននឹងលោកត្រូវគេបាញ់សម្លាប់ លោក វុទ្ធី បានទទួលការគំរាមកំហែងដល់អាយុជីវិតតាមទូរស័ព្ទ ដោយព្រមានលោកឱ្យលាលែងពីមុខតំណែងនៅក្នុងសហជីព។ ក្រោយពីសម្លាប់លោកហើយ ភរិយារបស់លោកដែលជាស្ត្រីមេម៉ាយក៏ជាកម្មកររោងចក្រសាន់តិចដែរនោះ ត្រូវបានមនុស្សជិះម៉ូតូពាក់ម៉ាស់បិទមុខតាមនាង ហើយនាងត្រូវរត់គេចខ្លួន។ លោក ជា មុន្នី ប្រធានសហព័ន្ធសហជីពសេរីកម្មករជាតិ បានរាយការណ៍ប្រាប់សារព័ត៌មានជាតិថា ថ្មីៗនេះលោក វុទ្ធី ធ្លាប់មានការប្រឈមមុខដោយកំហឹងយ៉ាងខ្លាំងជាមួយសមាជិកសហព័ន្ធសហជីពកម្ពុជា ដែលមានទំនោរគាំទ្រគណបក្សប្រជាជនកម្ពុជា ហើយលោក ជួន មុំថុល ប្រធានសហព័ន្ធសហជីពបានចោទថា លោក ជា មុន្នី ស្ថិតនៅពីក្រោយឃាតកម្មនេះ។[៤០]

ទោះបីជាអន្តរជាតិបានស្រែកអំពាវនាវយ៉ាងណាក៏ដោយអំពីករណីឃាតកម្មនេះ ក៏នៅតែគ្មានការចាប់ខ្លួនជនល្មើសណាម្នាក់ដែរ។ នៅខែមេសា លោក ទូច ណារ៉ុថ ស្នងការនគរបាលរាជធានីភ្នំពេញបានអះអាងថា នគរបាលបានទទួលដីកាចាប់ជនសង្ស័យពីរនាក់ហើយ ប៉ុន្តែលោកបានបដិសេធមិនផ្ដល់ព័ត៌មានលំអិតទេ។[៤១] ហើយការអះអាងបែបនេះក៏ត្រូវបានឯកឧត្តម ខៀវ សុភ័ក្រ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានលើកឡើងម្ដងទៀតដែរនៅខែឧសភា។[៤២] ប៉ុន្តែរហូតមកដល់ចុងឆ្នាំ២០០៧ មេធាវីរបស់គ្រួសារលោក ហ៊ី វុទ្ធី បានបញ្ជាក់ថា នគរបាលគ្មានរបាយការណ៍អង្កេតទាល់តែសោះក្នុងករណីឃាតកម្មនេះ ហើយបំភ្លេចចោលដីកាចាប់ខ្លួនក្នុងសំណុំរឿងនៅតុលាការរាជធានីភ្នំពេញ។[៤៣] នៅក្នុងខែមករា ឆ្នាំ២០០៨ លោក ទូច ណារ៉ុថ បានលើកឡើងម្ដងទៀតថា លោកបានទទួលដីកាចាប់ខ្លួនជនសង្ស័យពីរនាក់

---

[៤០] ដាន ពុយាតុន និង សំ រិទ្ធ : *ចលនាសហជីពបានបណ្ដាលឱ្យស្ត្រីម្នាក់ទៀតក្លាយជាស្ត្រីមេម៉ាយ* កាសែត ភ្នំពេញប៉ុស្តិ៍ថ្ងៃទី៩-២២ ខែមិនា ឆ្នាំ២០០៧ ។

[៤១] *ក្រុមហ៊ុនលក់សម្លៀកបំពាក់ពិភពលោក បានទាមទារឱ្យមានការស៊ើបអង្កេតករណីឃាតកម្មលើសកម្មជនសហជីព* កាសែត ឌឺ ឃែមបូឌាដេលីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៧។

[៤២] យន់ សាមាន និង ជេមវេល : *ក្រុមហ៊ុន អាឌីដាះ ក្រុមអង្គការពលកម្មបានអំពាវនាវឱ្យមានការស៊ើបអង្កេតលើករណីឃាតកម្ម* កាសែត ឌឺ ឃែមបូឌាដេលីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៧។

[៤៣] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ ។

ប៉ុន្តែមួយខែក្រោយមក លោកបាននិយាយផ្ទុយទៅវិញថា នគរបាលពុំទាន់បានស្គាល់អត្តសញ្ញាណជនសង្ស័យនៅឡើយទេ ក្នុងករណីឃាតកម្មនេះ។[៤៤]

ករណីឃាតកម្មលើរូបលោក ហ៊ី វុទ្ធី បានរំឭកឡើងវិញយ៉ាងខ្លាំងដល់ឃាតកម្មលើលោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករ ការសម្លាប់លោក រស់ សុវណ្ណារេត នៅក្នុងឆ្នាំ២០០៤ ករណីនីមួយៗក្នុងករណីទាំងពីរនេះ ជនរងគ្រោះសុទ្ធតែបានទទួលការគំរាមកំហែងដល់អាយុជីវិត មុននឹងត្រូវបានបុរសពីរនាក់ជិះម៉ូតូបានសម្លាប់ពួកលោក។ ពេលមានការផ្តន្ទាទោស និងវិនិច្ឆ័យទោសនៅក្នុងករណីទាំងពីរនេះ អង្គការសិទ្ធិមនុស្សនានា បានសម្តែងនូវការសង្ស័យថា ការផ្តន្ទាទោសលើជនសង្ស័យនោះ អាចពុំមែនជាឃាតករពិតប្រាកដទេ។ នៅក្នុងករណីឃាតកម្មលើលោក ជា វិជ្ជា គេឃើញមានភស្តុតាងយ៉ាងច្រើនលើសលប់បញ្ជាក់ថា ប៊ន សំណាង និង សុខ សំអឿន បុរសពីរនាក់នេះត្រូវគេផ្តន្ទាទោសដាក់ពន្ធនាគារម្នាក់ ២០ ឆ្នាំ ពុំមែនជាឃាតករពិតប្រាកនោះទេ។ សវនាការករណីនេះនៅសាលាឧទ្ធរណ៍កាលពីខែមេសា ឆ្នាំ២០០៧ កន្លងទៅ ត្រូវបានទទួលរងការថ្កោលទោសយ៉ាងខ្លាំងអំពីការមិនប្រតិបត្តិតាមបទដ្ឋានអប្បបរមាយុត្តិធម៌។ នៅចុងឆ្នាំ បុរសទាំងពីរនេះនៅតែជាប់ពន្ធនាគារពីបទល្មើសដែលពួកគេមិនបានប្រព្រឹត្ត ក្នុងខណៈដែលឃាតករពិតប្រាកដនៅតែបន្តរួចខ្លួនដដែល។[៤៥]

ឃាតកម្មលើរូបលោក ហ៊ី វុទ្ធី កើតឡើង ក្រោយពីមានការវាយប្រហារលើពួកសហជីពនៅក្នុងប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ដែលបានធ្វើឱ្យមានការថ្កោលទោស និងព្រួយបារម្ភយ៉ាងខ្លាំង។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៧ ក្រុមហ៊ុនសម្លៀកបំពាក់អន្តរជាតិធំៗចំនួន ៥ បានសរសេរលិខិតចំហរមួយច្បាប់ទៅរដ្ឋាភិបាល ដោយបានសម្តែងនូវកង្វល់របស់ពួកគេ ចំពោះករណីឃាតកម្ម និងអំពើហិង្សាក្នុងទម្រង់ផ្សេងៗ មកលើមេដឹកនាំសហជីព ហើយបានសុំអំពាវនាវឱ្យមានការស៊ើបអង្កេតដោយបានហ្មត់ចត់ និងឯករាជ្យ ដើម្បីនាំខ្លួនឃាតករមកផ្តន្ទាទោសតាមច្បាប់។[៤៦] នៅថ្ងៃទី១ ខែឧសភា អង្គការសហព័ន្ធ និងក្រុមហ៊ុនចំនួន ២៤២ នៅជុំវិញពិភពលោក រួមទាំងក្រុមហ៊ុនលក់រាយធំៗផងដូចជា អាឌីដាស បានចេញសេចក្តីថ្លែងការណ៍មួយអំពាវនាវឱ្យមានយុត្តិធម៌ចំពោះ លោក ហ៊ី វុទ្ធី ហើយបែរជាឃើញមានការវាយប្រហារថ្មីៗ មកលើមេដឹកនាំសហជីពថែមទៀត។[៤៧]

[៤៤] *ការដើរក្បួនដើម្បីរំឭកដល់ឃាតកម្មមេដឹកនាំសហជីព* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨។ យន់ សាមាន: *សហជីពសេរីកម្មករអំពាវនាវឱ្យមានការស៊ើបអង្កេតលើករណីឃាតកម្ម* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨។

[៤៥] សម្រាប់ព័ត៌មានលំអិត សូមអានរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា: *យុត្តិធម៌គ្មានភាពប្រាកដនិយម* របស់លីកាដូខែធ្នូ ឆ្នាំ២០០៧ ។

[៤៦] លិខិត et al from Eddie Bauer, Gap Inc, H&M Hennes & Mauritz, Liz Claiborne and Phillips-Van Heusen ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៧ ផ្ញើជូននាយករដ្ឋមន្ត្រី។

[៤៧] *ការអំពាវនាវរកយុត្តិធម៌:* សេចក្តីថ្លែងការណ៍រួមដែលចុះហត្ថលេខាដោយ ២៤២ ក្រុមនៅកម្ពុជា និង ៨២ ប្រទេសទៀតនៅទូទាំងពិភពលោកថ្ងៃទី ១ ខែឧសភា ឆ្នាំ២០០៧។

ប្រហែលជា ចំណុចសំខាន់បំផុត អង្គការពលកម្មអន្តរជាតិ បានសម្តែងនូវការព្រួយបារម្ភកាន់តែខ្លាំងឡើងៗ ក្នុងបរិយាកាសភ័យខ្លាច និង ហិង្សាក្នុងចំណោមសកម្មជនសហជីពកម្មករនៅកម្ពុជា។

នៅខែមិថុនា ឆ្នាំ២០០៧ គណៈកម្មាធិការអង្គការពលកម្មអន្តរជាតិស្តីពីសហព័ន្ធសមាគមបានជូនរបាយការណ៍មួយច្បាប់ទៅគណៈកម្មាធិការគ្រប់គ្រងអង្គការ ដោយបានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះ "ភាពធ្ងន់ធ្ងរ" នៃស្ថានភាពនៅកម្ពុជា។ របាយការណ៍នោះបានសង្កត់ធ្ងន់លើករណីឃាតកម្មលើ លោក ហ៊ី វុទ្ធី ជា វិជ្ជា និង រស់ សុវណ្ណារេត ព្រមទាំងការវាយប្រហារផ្សេងៗទៀតមកលើសមាជិកសហជីពរួមមានលើមន្ត្រីសហជីពសេរីកម្មករកម្ពុជា នៅរោងចក្រប្រាយស្តាយ និងសាន់តិច ដូចបានលើកឡើងខាងលើ។ គណៈកម្មាធិការបានលើកឡើងធ្ងន់ៗថា "ចំពោះករណីនេះ ផ្នែករដ្ឋាភិបាលពុំបានប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីស៊ើបអង្កេតឱ្យបានហ្មត់ចត់ទេ" ក្នុងករណីឃាតកម្មលើរូបលោក ហ៊ី វុទ្ធី និងការវាយប្រហារផ្សេងៗទៀតមកលើមេដឹកនាំសហជីពនានា រដ្ឋាភិបាលគួរតែទទួលយកបេសកកម្មជំនាញរបស់អង្គការពលកម្មអន្តរជាតិមកកាន់កម្ពុជាដើម្បីធ្វើការស៊ើបអង្កេតករណីនេះ។[៤៨]


កម្រងផ្កាបុណ្យសពលោក ហ៊ី វុទ្ធី

នៅក្នុងខែមិថុនា គណៈកម្មាធិការអង្គការពលកម្មអន្តរជាតិស្តីពីការអនុវត្តន៍ស្តង់ដាបានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងអំពីឃាតកម្មលើលោក ហ៊ី វុទ្ធី ជា វិជ្ជា និង រស់ សុវណ្ណារេត ការគំរាមកំហែងដល់អាយុជីវិតនិង "ការកើតឡើងនូវបរិយាកាសនិទ្ទណ្ឌភាពនៅកម្ពុជា" ហើយបានទាមទារឱ្យរដ្ឋាភិបាលកម្ពុជាទទួលយកបេសកកម្មអង្គការពលកម្មអន្តរជាតិមកកម្ពុជា។[៤៩]

ក្នុងខែមេសា ឆ្នាំ២០០៨ ដោយមានការឯកភាពពីរដ្ឋាភិបាលបេសកកម្មរបស់អង្គការពលកម្មអន្តរជាតិបានធ្វើទស្សនកិច្ចនៅកម្ពុជា ដោយមានការវាយតម្លៃត្រួសៗ អំពីកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរកម្ពុជាក្នុងការស៊ើបអង្កេត "រាល់ករណីគំរាមកំហែង ឬ ឃាតកម្មនានា"។ បេសកកម្មនេះនឹងរាយការណ៍ជូនគណៈកម្មាធិការជំនាញនៃអង្គការពលកម្មអន្តរជាតិស្តីពីការអនុវត្តន៍អនុសញ្ញា និង អនុសាសន៍នានានៅចុងឆ្នាំនេះ។[៥០] លីកាដូកំពុងរង់ចាំនូវលទ្ធផលនៃការស្រាវជ្រាវរបស់គណៈកម្មាធិការនេះហើយសង្ឃឹមថា លទ្ធផលនេះនឹងអាចជួយឱ្យមានការឈានទៅមុខ ក្នុងការស្វែងរកយុត្តិធម៌សម្រាប់លោកហ៊ី វុទ្ធី និង សមាជិកសហជីពនានាដែលត្រូវបានធ្វើទុក្ខបុកម្នេញដោយសារកិច្ចការពារសិទ្ធិមនុស្សរបស់ពួកគេ។

---

[៤៨] គណៈកម្មាធិការអង្គការពលកម្មពិភពលោកស្តីពីសេរីភាពក្នុងការចូលសមាគម-របាយការណ៍លេខ ៣៤៦ (ឆ្នាំ២០០៧ សេរី ខ លេខ ២)ខែមិថុនា ឆ្នាំ ២០០៧។

[៤៩] របាយការណ៍របស់គណៈកម្មាធិការស្តីពីការអនុវត្តន៍ស្តង់ដារឯកសារបណ្តោះអាសន្ន-សន្និសីទអង្គការពលកម្មអន្តរជាតិលើកទី៩៦ ទីក្រុងហ្សឺណែវ ឆ្នាំ ២០០៧។

## តំណាងសហគមន៍ក្នុងបញ្ហាទំនាស់ដីធ្លី

ការវាយប្រហារដ៏ច្រើនបំផុតមកលើអ្នកការពារសិទ្ធិមនុស្សដែលបានកត់ត្រានៅឆ្នាំ២០០៧ ទាក់ទងជាមួយនឹងសកម្មជនសហគមន៍ដែលបានក្លាយជាគោលដៅវាយប្រហារ ដោយសារតែការធ្វើជាតំណាងប្រជាពលរដ្ឋនៅក្នុងបញ្ហាទំនាស់ដីធ្លី ជាមួយអ្នកមានអំណាចខាងនយោបាយ និងផលប្រយោជន៍សេដ្ឋកិច្ច ។ ការគំរាមកំហែងផ្ទាល់មាត់មកលើតំណាង ដូចជាការគំរាមដល់អាយុជីវិត គឺជាបញ្ហាទូទៅបំផុតដែលបានកើតឡើងយ៉ាងច្រើនដោយមិនបានរាយការណ៍។ ប៉ុន្តែ និន្នាការប្រព្រឹត្តទៅលើតំណាងដោយប្រើប្រាស់ការចាប់ចង ឃុំឃាំង និងការព្យាបាទដោយប្រើការចោទប្រកាន់តាមផ្លូវច្បាប់ បានកើតឡើងកាន់តែច្រើនឡើងៗជាងបណ្តាឆ្នាំមុនៗទៅទៀត។

ក្នុងខែមករា តំណាងរបស់ប្រជាពលរដ្ឋជាង ៥០០ គ្រួសារដែលបានពាក់ព័ន្ធក្នុងទំនាស់ដីធ្លីមួយយ៉ាងយូរអង្វែងនៅខេត្តកោះកុង ត្រូវបានតុលាការខេត្តកោះហៅ ដើម្បីសាកសួរអំពីករណីឃាតកម្មកាលពីខែមុន។ ដោយគ្មានភស្តុតាងពាក់ព័ន្ធជាមួយគាត់នៅក្នុងករណីឃាតកម្មនេះ ការកោះហៅនោះត្រូវបានមតិភាគច្រើនយល់ឃើញថា ជាការបំភិតបំភ័យចំពោះសកម្មភាពដែលគាត់បានធ្វើកន្លងមក។ ជាការបង្ហាញសាមគ្គីភាពរបស់ប្រជាពលរដ្ឋ អ្នកភូមិ ៥០ នាក់ដែលគាត់តំណាងឱ្យពួកគេនោះ បានស្ម័គ្រចិត្តដើរទៅកាន់ទីរួមខេត្ត និងរាយការណ៍ដល់សារព័ត៌មាន ហើយដោយខ្លាចមានការផ្សព្វផ្សាយអាក្រក់ តុលាការក៏បានសុខចិត្តលុបចោលការសាកសួរនោះវិញ។

នៅខែឧសភា មនុស្ស ៤ នាក់ដែលជាតំណាងរបស់ប្រជាពលរដ្ឋ ៣០ គ្រួសារ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទរំលោភទ្រព្យសម្បត្តិឯកជន នៅក្រុងកែប ដោយផ្អែកលើការបណ្តេញប្រជាពលរដ្ឋចេញពីដីដោយបង្ខំដែលបានកើតឡើងកាលពីឆ្នាំ២០០៤ ។ ក្នុងខែនោះ មានបុរសពីរនាក់ទៀតដែលជាតំណាងប្រជាពលរដ្ឋ ៥០ គ្រួសារនៅក្នុងបញ្ហាទំនាស់ដីធ្លីមួយនៅខេត្តព្រៃវែង ក៏ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ដោយគ្មានភស្តុតាងពីបទលួចស្រូវ។ បញ្ហារំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ជាច្រើនត្រូវបានកត់ត្រានៅក្នុងបញ្ហាទំនាស់មួយនេះ រួមមានការសម្លាប់យុវជនម្នាក់អាយុ ១៧ឆ្នាំ ឈ្មោះ យេង សុជាតិ កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៦ ។ សុជាតិ បានស្លាប់ក្នុងការបាញ់ប្រហារដោយជនប្រដាប់ដោយអាវុធមានគ្នាប្រមាណ ២០ នាក់ ដែលបានធ្វើការបាញ់រះទៅលើប្រជាពលរដ្ឋស្លូតត្រង់បាតដៃទទេដែលបានព្យាយាមចូលទៅជួបលោកអភិបាលរងស្រុកពាមជរ ឈ្មោះ អ៊ី សំអុល ។ គ្មានជនល្មើសណាម្នាក់ត្រូវបានផ្តន្ទាទោសទេនៅក្នុងករណីឃាតកម្មនេះទេ។[៥១]

---

[៥០] ទំនាក់ទំនងរវាងអង្គការពលកម្មអន្តរជាតិ និងលីកាដូ ខែកុម្ភៈ ឆ្នាំ២០០៨។

[៥១] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ ។

នៅខែមិថុនា តុលាការខេត្តបាត់ដំបងបានលើកលែងការចោទប្រកាន់លើបុរសម្នាក់ឈ្មោះ ជឹម កែវ ដែលជាតំណាងប្រជាពលរដ្ឋ ១៤ គ្រួសារ នៅភូមិកោះរាម ឃុំខ្នាចរមាស ស្រុកបវេល ។ លោក ជឹម កែវ បានជាប់ពន្ធនាគារបណ្តោះអាសន្នរង់ចាំការកាត់ក្តីតាំងពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៦មក ក៏ត្រូវបានបញ្ជូនត្រឡប់ទៅពន្ធនាគារវិញ ដើម្បីរង់ចាំការប្តឹងឧទ្ធរណ៍។ តុលាការបានចោទគាត់ពីបទរំលោភលើទ្រព្យសម្បត្តិឯកជន ដែលជាបញ្ហាពាក់ព័ន្ធជាមួយនឹងទំនាស់ដីធ្លីយ៉ាងយូរអង្វែងមួយ ជាមួយនឹងអ្នកជំនួញម្នាក់ឈ្មោះ អៀង អឿន ដែលជាប្អូនថ្លៃរបស់ឯកឧត្តមឆាយ សារេត អភិបាលខេត្តពោធិ៍សាត់។ ក្រុមកិច្ចការពិសេសនៃក្រសួងយុត្តិធម៌ ដែលបានស៊ើបអង្កេតលើករណីទំនាស់ដីនោះកាលពីខែធ្នូ ឆ្នាំ២០០៦ បានធ្វើសេចក្តីសន្និដ្ឋានថា តុលាការបានឃុំឃាំងលោក ជឹម កែវ ដោយខុសច្បាប់ ហើយត្រូវដោះលែងគាត់ឱ្យនៅក្រៅឃុំជាបន្ទាន់។ ក្រោយពីមានអន្តរាគមន៍ពីសំណាក់អង្គការសិទ្ធិមនុស្សជាច្រើន ទីបំផុតតុលាការបានដោះលែងគាត់នៅក្នុងខែតុលា ។ បណ្តឹងឧទ្ធរណ៍ជំទាស់នឹងការដោះលែងគាត់ឱ្យនៅក្រៅឃុំត្រូវបានបន្តដំណើរការដដែល។[៥២]

នៅខែសីហា បុរសពីរនាក់ដែលជាតំណាងរបស់ប្រជាពលរដ្ឋជាង ១០០ គ្រួសារ ត្រូវបានតុលាការខេត្តសៀមរាប ចាប់ឃុំឃាំងក្នុងពន្ធនាគារអស់រយៈពេល ២-៣ ថ្ងៃ ពាក់ព័ន្ធនឹងសកម្មភាពដឹកនាំប្រជាពលរដ្ឋនៅក្នុងបញ្ហាទំនាស់ដីធ្លីមួយកន្លែង។ ក្នុងការប្រើល្បិចកលដែលគេធ្លាប់បានដឹងគ្រប់ៗគ្នា តុលាការបានកោះហៅពួកគេ ដើម្បីសាកសួរចម្លើយ នេះគឺជាវិធីចាប់ឃាត់ខ្លួន និងឃុំឃាំងពេលពួកគេទៅដល់តុលាការនោះ។[៥៣]

បច្ចុប្បន្ននេះគេសង្កេតឃើញប្រពលរដ្ឋកាន់តែច្រើនឡើងៗ ដែលបានរងគ្រោះក្នុងបញ្ហាទំនាស់ដីធ្លីចូលចិត្តធ្វើដំណើរមកភ្នំពេញដើម្បីបង្ហាញបញ្ហាកង្វល់របស់ខ្លួនទៅមន្ត្រីអាជ្ញាធរថ្នាក់ជាតិនានា។ តាមពិតប្រជាពលរដ្ឋទាំងនោះកម្រទទួលបានជោគជ័យណាស់ ហើយច្រើនតែទទួលបានការគំរាមកំហែង និងការបំភិតបំភ័យ។ ក្នុងខែមិនា ប្រជាពលរដ្ឋ ១២២ នាក់មកពីខេត្តកោះកុងដែលធ្វើដំណើរដោយថ្មើរជើងមករាជធានីភ្នំពេញ ដើម្បីយកញត្តិមកជូនរដ្ឋាភិបាល ត្រូវបានគំរាមកំហែងដោយជនល្មើសមួយក្រុម បើករថយន្តដែលមានបំពាក់គ្រឿងបំពងសម្លេងនៅលើនោះក្រវែលប្រជាពលរដ្ឋ ដោយព្រមានថា "គ្មានការធានាសន្តិសុខដល់ពួកគេទេ"។ នៅខែតុលា ប្រជាពលរដ្ឋប្រមាណ ១០០ នាក់ បានធ្វើដំណើរពីខេត្តស្វាយរៀងមកដល់ភ្នំពេញ ដើម្បីតវ៉ាចំពោះការរំលោភយកដីរបស់ពួកគាត់ ដោយក្រុមហ៊ុនចម្ការកៅស៊ូរបស់រដ្ឋមួយ ប៉ុន្តែពួកគាត់ត្រូវបានអាជ្ញាធរចាប់បង្ខំឱ្យឡើងរថយន្តក្រុងមួយគ្រឿង ហើយដឹកបញ្ជូនទៅខេត្តស្វាយរៀងវិញ។ អាជ្ញាធរបានវាយដំប្រជាពលរដ្ឋខ្លះ ហើយបណ្តាលឱ្យមនុស្សពីរនាក់ដួលសន្លប់ត្រូវដឹកទៅកាន់មន្ទីរពេទ្យ។[៥៤]

---

[៥២] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ ។

[៥៣] ឆាយ ចានីដា : *ពួកបាតុករបានទាមទារឱ្យតុលាការដោះលែងពិរុទ្ធជន* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៧។

[៥៤] សេចក្តីថ្លែងសារព័តិមានរបស់លីកាដូ: សូមអានអត្ថបទរបស់ប្រាក់ ចាន់ថុល និង យន់ សាមាន : *អ្នកភូមិបានតវ៉ាខាងក្រៅផ្ទះសម្តេចនាយករដ្ឋមន្ត្រី ដើម្បីទាមទារយកដីរបស់ពួកគេវិញ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧។

អំពើហិង្សា និងការចោទប្រកាន់ផ្នែកច្បាប់មកលើសកម្មជនក្នុងទំនាស់ដីធ្លីក្នុងឆ្នាំ២០០៧ គឺវិវឌ្ឍន៍ពីបញ្ហាដែលបានកើតឡើងកាលពីឆ្នាំ២០០៦ ដោយមានករណីពីរបានបង្ហាញក្នុងឆ្នាំនីមួយៗយ៉ាងច្បាស់។

## ព័ត៌មានថ្មី១: ករណី សូ សុជាតិ ទំនាស់ដីធ្លីនៅវត្តបូព៌ ខេត្ត សៀមរាប

នៅក្នុងរបាយការណ៍ស្តីពី *ការវាយប្រហារ និងគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាឆ្នាំ ២០០៦* លីកាដូបានលាតត្រដាងករណីកញ្ញា សូ សុជាតិ អាយុ ២៣ ឆ្នាំ ដែលត្រូវបានតែងតាំងជាតំណាងសហគមន៍នៅភូមិវត្តបូព៌ ខេត្តសៀមរាប ដែលប្រជាពលរដ្ឋចំនួន ៤៩ គ្រួសារ មានបញ្ហាទំនាស់ដីធ្លីមួយយ៉ាងយូរអង្វែងជាមួយព្រះសង្ឃចៅអធិការវត្តនោះ។ ប្រជាពលរដ្ឋទាំងនោះបានអះអាងថា ពួកគាត់បានរស់នៅទីនោះអស់រយៈពេលជាច្រើនទសវត្ស ហើយមានប័ណ្ណកម្មសិទ្ធិដែលផ្តល់ជូននៅឆ្នាំ១៩៩០ ចំណែកឯចៅអធិការវត្តដែលគាំទ្រដោយព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស បានធ្វើឯកសារសំគាល់កម្មសិទ្ធិដីដែលចុះនៅឆ្នាំ១៩៩៥ ដើម្បីទាមទារដីនោះ។

នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៦ កញ្ញា សុជាតិ បានរៀបចំធ្វើការតវ៉ាមួយដោយសន្តិវិធី ហើយនគរបាលប្រមាណ ៤០ នាក់ប្រដាប់ដោយអាវុធគ្រប់ដៃបានវាយបំបែកហ្វូងបាតុករដោយបានប្រើដំបងឆក់វាយដំលើប្រជាពលរដ្ឋទាំងនោះ។ នាងសុជាតិបានព្យាយាមអន្តរាគមន៍អំពើហិង្សានោះ ហើយក៏ត្រូវវាយដំយ៉ាងដំណំរហូតដល់នាងមិនអាចដើររួច ហើយក៏ត្រូវបានចាប់ដាក់ខ្នោះ និងឃុំខ្លួននៅប៉ុស្តិ៍នគរបាល។ ពេលទៅដល់ទីនោះ មន្ត្រីនគរបាលម្នាក់បានបង្ខំឱ្យនាងផ្តិតមេដៃលើឯកសារមួយដែលជាការសារភាពថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែ សុជាតិបានបដិសេធចំពោះការចុះហត្ថលេខានោះ។ បន្ទាប់ពីបានឃុំឃាំងមួយយប់នៅក្នុងប៉ុស្តិ៍នគរបាល គេបានដោះលែងគាត់ឱ្យនៅក្រៅឃុំក្រោយពីប្រជាពលរដ្ឋបានធ្វើការចរចាជាមួយអាជ្ញាធរដោយមានអន្តរាគមន៍ពីអង្គការសិទ្ធិមនុស្សនានា។ ប៉ុន្តែពេលនោះ តុលាការខេត្តសៀមរាបបានចោទប្រកាន់នាងពីបទវាយដំ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។

ការចោទប្រកាន់ពីបទវាយដំ និងបង្ករបួសស្នាម ជាបទចោទទាក់ទងជាមួយបណ្តឹងរបស់នគរបាលដែលបានចោទថា ប្រជាពលរដ្ឋបានចាប់ទាញពងស្វាសរបស់គាត់នៅក្នុងការបង្ក្រាបបាតុករ ហើយការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ គឺជាការចោទប្រកាន់របស់នគរបាលដដែលនោះដែរ ដែលវិទ្យុទាក់ទងរបស់នគរបាលបានធ្លាក់បែកនៅក្នុងកំឡុងពេលនោះដែរ។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៧ តុលាការខេត្តសៀមរាប បានបើកសវនាការករណីរបស់សុជាតិ ។ នៅក្នុងសវនាការនោះ នាយនគរបាលម្នាក់ឈ្មោះ យឿន ឧត្តម បានចោទប្រកាន់ថា មានប្រជាពលរដ្ឋ ២-៣ នាក់បានទាញពងស្វាសរបស់គាត់ ហើយបានឆក់យកវិទ្យុទាក់ទងរបស់គាត់ ប៉ុន្តែគាត់ក៏បាននិយាយផងដែរថា កញ្ញាសុជាតិអត់បានចូលរួមក្នុងការទាញ និងឆក់វិទ្យុទាក់ទងនោះទេ ។ ខាងនគរបាលមិនបានបង្ហាញលិខិតវេជ្ជសាស្ត្រ ឬលិខិតផ្សេងៗទៀតមកបញ្ជាក់តុលាការថា មន្ត្រីនគរបាល លោក យឿន ឧត្តម មានរបួសទេ ។ ស្រដៀងគ្នានេះដែរ

ភស្តុតាងនៃការខូចវិទ្យុទាក់ទងក៏មិនបានយកមកបញ្ជាក់ទៅមុខតុលាការដែរ។

ទោះបីជាគ្មានភស្តុតាងដាក់បន្ទុកមកលើនាងក៏ដោយ ក៏កញ្ញា សូ សុជាតិត្រូវបានផ្តន្ទាទោសពីបទល្មើសទាំងពីរនេះ។ ចៅក្រម ឃុន សុផល បាននិយាយថា កញ្ញា សុជាតិ មិនបានប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់គាត់ផ្ទាល់ខ្លួនទេ ប៉ុន្តែតុលាការបានផ្តន្ទាទោសគាត់ពីបទ "មេដឹកនាំ" ដែលផ្ទុយទៅនឹងច្បាប់កម្ពុជាយ៉ាងច្បាស់។ តុលាការបានផ្តន្ទាទោសនាងដាក់ពន្ធនាគាររយៈពេល ៨ ខែ និងផាកពិន័យជាទឹកប្រាក់ចំនួន ៥០០.០០០ រៀល (១២៥ ដុល្លារ) នៅចុងឆ្នាំ២០០៧ នាងនៅមានសេរីភាពនៅឡើយ ដោយរង់ចាំសវនាការសាលាឧទ្ធរណ៍ដែលប្តឹងទាស់នឹងសាលក្រមនេះ។

## ព័ត៌មានថ្មី៧: ករណី ឈា នី និង ជម្លោះដីធ្លីនៅស្រុក បវេល

នៅក្នុងរបាយការណ៍ស្តីពី *ការវាយប្រហារ និងការគំរាមកំហែងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៦* លីកាដូបានលាតត្រដាងករណីរបស់ លោក ឈា នី និងតំណាងប្រជាពលរដ្ឋចំនួន ៣.១៧០ គ្រួសារផ្សេងទៀត ដែលបានពាក់ព័ន្ធក្នុងករណីជម្លោះដីធ្លីនៅស្រុកបវេល ខេត្តបាត់ដំបង។ ករណីនេះពាក់ព័ន្ធជាមួយដីនៅជុំវិញតំបន់បឹងប្រាំ ឃុំអំពិលប្រាំដើម ស្រុកបវេល ដែលត្រូវបានគ្រួសារអតីតយុទ្ធជនគ្មានដីធ្លីមកតាំងទីលំនៅលើដីនោះដោយជឿជាក់ថា ជាដីព្រៃរបស់រដ្ឋ។ ប៉ុន្តែក្រោយមក ស្រាប់តែមានពាណិជ្ជករម្នាក់មកអះអាងថា គេបានទិញដីនោះពីមេបញ្ជាការយោធាម្នាក់។

ក្រោយពីមានបណ្តឹងពីពាណិជ្ជករដែលអះអាងថាជាម្ចាស់ដីនោះ តំណាងសហគមន៍ឈ្មោះ ឈា នី ត្រូវបានចាប់ខ្លួនក្នុងការតវ៉ាមួយកាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០០៦ ហើយបញ្ជូនទៅពន្ធនាគារខេត្តបាត់ដំបង។ នៅថ្ងៃទី៤ ខែកញ្ញា គេបានចាប់បុរសម្នាក់ទៀតឈ្មោះ ហែម ឡាក់ និងបុរសម្នាក់ទៀតឈ្មោះ មូ សាប់អាយុ៧៨ ឆ្នាំ ឃុំឃាំងជាមួយ ឈា នី ដែរ។ សកម្មជនពីរនាក់ទៀត រស់ សារឿន និងអឿន ម៉ៅ បានរត់គេចខ្លួនបាត់ ហើយមិនត្រូវបានចាប់ខ្លួនទេ។ បុរសទាំង ៥ នាក់នេះ ត្រូវបានចោទប្រកាន់ពីបទរំលោភលើទ្រព្យសម្បត្តិឯកជន ហើយ លោក ឈា នី ហែម ឡាក់ និង មូ សាប់ ត្រូវបានតុលាការបដិសេធមិនដោះលែងឱ្យនៅក្រៅឃុំទេ។

នៅក្នុងសវនាការកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ តុលាការបានផ្តន្ទាទោសបុរសទាំង ៥ នាក់ នោះពីបទប្រើអំពើហិង្សារំលោភលើទ្រព្យសម្បត្តិឯកជនរបស់អ្នកដទៃ។ លោក ឈា នី មិនបានបង្ហាញមុខនៅតុលាការទេ ដោយត្រូវបានផ្ទេរមកពន្ធនាគារនៅភ្នំពេញ ហើយតុលាការតែងតែបដិសេធសំណើរបស់មេធាវីគាត់ដែលស្នើឱ្យបញ្ជូនគាត់មកពន្ធនាគារខេត្តបាត់ដំបងវិញ។ នៅក្នុងសវនាការនោះ គ្មានដើមបណ្តឹង ឬ សាក្សីដាក់បន្ទុកណាម្នាក់បង្ហាញមុខនៅក្នុងសវនាការ ហើយគ្មានភស្តុតាងបង្ហាញពីសកម្មភាពហិង្សាណាដែលចុងចោទបានប្រព្រឹត្តដែរ។ ទោះជាយ៉ាងណាក្តី លោក ឈា នី រស់ សារឿន និង អឿន ម៉ៅ ត្រូវបានផ្តន្ទាទោសដោយកំបាំងមុខជាប់ពន្ធនាគាររយៈពេល ១ ឆ្នាំ

និងសងជម្ងឺចិត្ត ៤០០ ដុល្លារសហរដ្ឋអាមេរិកទៅដើមបណ្តឹង។ លោក ហែម ឡាក់ និង មូ សាប់ ដែលមានវត្តមាននៅក្នុងសវនាការ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៦ ខែ។ ដោយសារអ្នកទាំងពីរត្រូវបានឃុំឃាំងបណ្តោះអាសន្នរង់ចាំការកាត់ក្តីរយៈពេល ៦ ខែ រួចហើយ ហេតុនេះតុលាការក៏បានដោះលែងក្រោយពីសវនាការចប់។

សវនាការនេះបង្ហាញពីដំណើរមិនប្រក្រតីនៃយុត្តិធម៌ ក្នុងការរើសអើងចំពោះសកម្មជនការពារសិទ្ធិដីធ្លី។ នៅក្នុងករណីនេះ មេធាវីរបស់ដើមបណ្តឹងបានទទួលស្គាល់ថា កូនក្តីរបស់គាត់គ្មានប័ណ្ណកម្មសិទ្ធិលើដីទំនាស់នោះទេ ហើយនៅក្នុងសាលក្រមចៅក្រមបានណែនាំថា គាត់គួរតែដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិនៅគណៈកម្មាធិការសុរិយោដី។ ប៉ុន្តែទោះបីជាមានការទទួលស្គាល់ថា ភាគីដើមបណ្តឹងពុំមែនជាម្ចាស់ដីក៏ដោយ តុលាការនៅតែផ្តន្ទាទោសចុងចោទពីបទរំលោភទ្រព្យសម្បត្តិឯកជនរបស់អ្នកដទៃដដែល។

ដោយ ឈា នី អវត្តមាននៅក្នុងសវនាការ ដូច្នេះតុលាការបានបើកសវនាការជាថ្មីម្តងទៀតសម្រាប់ករណីរបស់គាត់ ដែលធ្វើនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៧ ហើយពេលនោះមេធាវីរបស់គាត់បានបង្ហាញឯកសារភស្តុតាងនានាបន្ថែមទៀត ដើម្បីបង្ហាញថាដីទំនាស់នោះគឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ពុំមែនជាទ្រព្យសម្បត្តិឯកជនទេ។ នៅក្នុងសាលក្រមដែលប្រកាសនៅថ្ងៃទី១១ ខែឧសភា បទចោទប្រកាន់ត្រូវបានប្តូរទៅជាការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ហើយការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ បានប្តូរមក ៩ ខែវិញ និងព្យួរទោស ៣ ខែ។ ទោះបីឈា នី បានជាប់ឃុំអស់រយៈពេលជាង ៩ ខែ នៅក្នុងការឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ក្តី ក៏គាត់នៅតែបន្តជាប់នៅក្នុងពន្ធនាគារដដែល រហូតដល់មានបទចោទប្រកាន់មកលើគាត់បន្ថែមទៀត។

នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៧ ឈា នី ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ៣ ខែ ថែមទៀត និងត្រូវសងជម្ងឺចិត្តជាប្រាក់ចំនួន ៤០០.០០០រៀល (១០០ ដុល្លារសហរដ្ឋអាមេរិក) ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនដោយខុសច្បាប់។ ថ្វីត្បិតតែគាត់បានបម្រើទោសនេះរួចហើយនៅក្នុងការឃុំឃាំងបណ្តោះអាសន្នរង់ចាំការកាត់ក្តីក៏ដោយ ក៏ឈានីត្រូវបានឃុំឃាំងនៅក្នុងពន្ធនាគារ ក្រោយពីព្រះរាជអាជ្ញាតុលាការ ខេត្តបាត់ដំបង លោក ស យសថាវរៈ បានប្តឹងឧទ្ធរណ៍ជំទាស់នឹងសាលក្រមនេះ។

ពេលនោះ ឈា នី បានក្លាយទៅជាជនរងគ្រោះដោយការអនុវត្តន៍ច្បាប់មិនត្រឹមត្រូវនៅកម្ពុជាមួយទៀត ដែលវិធីនេះត្រូវបានតុលាការប្រើប្រាស់ជាទូទៅដើម្បីផ្តន្ទាទោសអ្នកកាពារសិទ្ធិមនុស្ស និងប្រជាពលរដ្ឋផ្សេងទៀតដែលគ្មានឥទ្ធិពលខាងហិរញ្ញវត្ថុ និងអន្តរាគមន៍ពីមន្ត្រីមានអំណាចណាមួយ។

នៅកម្ពុជាប្រសិនបើព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ ជំទាស់នឹងសាលក្រមណាមួយដែលចេញដោយសាលាដំបូងនោះ ពិរុទ្ធជននៅតែស្ថិតនៅក្នុងពន្ធនាគារដដែល រហូតដល់តុលាការសាលាឧទ្ធរណ៍បើកសវនាការករណីនោះ។ អាស្រ័យដោយការពន្យាពេលសវនាការនៅតុលាការសាលាឧទ្ធរណ៍ ពិរុទ្ធជនដែលត្រូវលើកលែងការចោទប្រកាន់ ឬ ទណ្ឌិតដែល

បានបម្រើទោសរួចហើយ អាចត្រូវនៅជាប់ពន្ធនាគារបន្តទៀតអស់រយៈពេលរាប់ឆ្នាំ ដើម្បីរង់ចាំការបើកសវនាការសាលាឧទ្ធរណ៍។

គោលការណ៍ដែលមានតាំងពីយូរយាមកហើយនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជាកាលពីខែសីហា ឆ្នាំ២០០៧ កន្លងទៅនេះ ដោយមាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដែលជាការរំខាននៃការអភិវឌ្ឍន៍ក្នុងការធ្វើសេចក្តីព្រាងច្បាប់ ក្រោមជំនួយពីទីប្រឹក្សាអ្នកច្បាប់អន្តរជាតិ។ ដោយនីតិវិធីនេះ គឺផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិនៅឡើយ។ ការបន្តឃុំឃាំងនៅក្នុងស្ថានភាពបែបនេះ គួរតែជាករណីលើកលែងមិនគួរជាបញ្ញត្តិទេ ហើយគេគួរតែពិចារណាថាបញ្ញត្តិបែបនេះគួរធ្វើតែក្នុងបទល្មើសធ្ងន់ធ្ងរតែមួយគត់ ដូចជាអំពើឃាតកម្ម និងការបង្កបួសស្នាម ឬ រំលោភផ្លូវភេទធ្ងន់ធ្ងរតែប៉ុណ្ណោះ។

ជាការល្អម្យ៉ាងដែរ ដែលមាត្រា ៣៩៨ បានអនុញ្ញាតឱ្យព្រះរាជអាជ្ញាពិចារណាការសុំនៅក្រៅឃុំតាមស្ថានភាពជាក់លាក់មួយចំនួន តែក៏មិនបានចងកាតព្វកិច្ចឱ្យព្រះរាជអាជ្ញាត្រូវតែធ្វើដូច្នេះដែរ។ នៅក្នុងករណីរបស់ ឈា នី ការដាក់ពាក្យសុំនៅក្រៅឃុំ គឺបានផ្អែកទៅលើមាត្រា ៣៩៨ នេះ ទទួលបានជោគជ័យ ហើយចុងក្រោយតុលាការបានដោះលែងគាត់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៧។ បណ្តឹងឧទ្ធរណ៍នៅមិនទាន់ចប់នៅឡើយ ដូចដែលបានចោទប្រកាន់នៅក្នុងបទល្មើសផ្សេងទៀត គឺការរំលោភលើសិទ្ធិបុគ្គល។

មកដល់ពេលនេះ ករណីរបស់ឈា នី គឺជាករណីតែមួយគត់ដែលលីកាដូបានដឹងថា បានប្រើប្រាស់មាត្រា ៣៩៨ ដើម្បីដោះលែងពិរុទ្ធជនដែលមិនគួរត្រូវស្ថិតនៅក្នុងពន្ធនាគារទាល់តែសោះ។ [៥៥] ព្រះរាជអាជ្ញា លោក ស យសថាវារៈ ក្នុងករណីនេះ ត្រូវបានសរសើរចំពោះការប្រកាន់ខ្ជាប់នូវបទដ្ឋានសិទ្ធិមនុស្ស ហើយសង្ឃឹមថាព្រះរាជអាជ្ញាផ្សេងទៀតនឹងអនុវត្តតាមគំរូល្អនេះ។ បញ្ហានេះ គឺលោកអគ្គព្រះរាជអាជ្ញាត្រូវចេញសេចក្តីណែនាំមួយឱ្យព្រះរាជអាជ្ញាទាំងនោះគោរពនូវបទដ្ឋាននេះ ហេតុដូច្នេះរដ្ឋាភិបាលកម្ពុជាត្រូវពិចារណាធ្វើវិសោធនកម្មមាត្រា ៣៩៨ ដើម្បីឱ្យបានស្របជាមួយបទដ្ឋានអន្តរជាតិ។

[៥៥] នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៧ សកម្មជនសិទ្ធិដីធ្លី ឈ្មោះ ជឹម កែវ ដែលត្រូវបានលើកលែងការចោទប្រកាន់នៅក្នុងសវនាការកាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៧ ហើយកំពុងស្ថិតនៅក្នុងពន្ធនាគារដដែលដោយព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ ត្រូវបានតុលាការខេត្តបាត់ដំបងដោះលែងឱ្យនៅក្រៅឃុំដែរ។ ប៉ុន្តែក្នុងស្ថានភាពនេះ តុលាការមិនបានប្រើប្រាស់មាត្រា ៣៩៨ ទេ ។ ចំពោះព័ត៌មានបន្ថែម សូមអានទំព័រ ៥៤។

## ករណីសិក្សា: សហគមន៍ដីក្រហម

ករណីជម្លោះដីធ្លីខ្លះនៅក្នុងឆ្នាំ២០០៧ បានបង្ហាញនូវការអនុវត្តន៍យ៉ាងច្បាស់ក្រឡែត ដែលអ្នកជំនួញ រដ្ឋាភិបាល នគរបាល និងតុលាការ ឃុបឃិតគ្នាព្យាបាទផ្តន្ទាទោសតំណាងសហគមន៍ច្បាស់ជាងករណីដីក្រហម នៅភ្នំពេញទៅទៀត។ ដីក្រហមគឺជាសហគមន៍មួយ ដែលប្រឈមមុខនឹងការបណ្តេញចេញពីតំបន់មួយនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន។ ដីដ៏មានតម្លៃនោះ ជាដំបូងត្រូវបានគេសន្យាថា ឱ្យប្រជាពលរដ្ឋក្រីក្រដែលបានរស់នៅយូរ ហើយជាដីសម្បទានសង្គមកិច្ច។ ប៉ុន្តែនៅឆ្នាំ២០០៥ គេបានប្រាប់ឱ្យប្រជាពលរដ្ឋទាំងនោះរុះរើផ្ទះចេញពីតំបន់ដីក្រហមនេះ ហើយប្តូរទៅនៅកន្លែងថ្មី ដែលមានចម្ងាយ ២០ គីឡូម៉ែត្រ។ ប្រជាពលរដ្ឋជាច្រើនបានជំទាស់ប្រឆាំងនឹងបញ្ហានេះ ហើយបដិសេធមិនទទួលស្គាល់កិច្ចព្រមព្រៀងក្លែងក្លាយដែលតំណាងបានចុះហត្ថលេខាជំនួសពួកគេឡើយ។ ប៉ុន្តែ ជំនួសឱ្យការបដិសេធកិច្ចព្រមព្រៀង និងការចរចាដើម្បីឈានទៅដល់ដំណោះស្រាយដែលអាចទទួលយកបាន ក្រុមហ៊ុនដែលបានទាមទារដីនោះ បានធ្វើយុទ្ធនាការយាយីរំខានបំភិតបំភ័យប្រជាពលរដ្ឋ និងតំណាងសហគមន៍ឱ្យព្រមទទួលយកកិច្ចព្រមព្រៀង និងដកថយចេញពីដីនោះដោយ "ស្ម័គ្រចិត្ត"។

ការបំភិតបំភ័យត្រូវបានធ្វើឡើងក្នុងទម្រង់ផ្សេងៗជាច្រើន តាំងពីការគំរាមតាមពាក្យសម្តីលើប្រជាពលរដ្ឋ និងពាក្យចចាមអារ៉ាមអំពីការបណ្តេញចេញភ្លាមៗរហូតដល់ការប្រឈមមុខដាក់គ្នា ដោយប្រើហិង្សាជាមួយសមាជិកសន្តិសុខ និងកម្មកររបស់ក្រុមហ៊ុនឈ្មោះថា សេវេនអេនជី ដែលជាក្រុមហ៊ុនទាមទារយកដីនោះ។ ការគំរាមកំហែងដែលជាល្បិចខ្ពស់បំផុតនោះ ប្រហែលជាមានការចោទប្រកាន់ ដោយគ្មានភស្តុតាងរបស់តុលាការក្រុងភ្នំពេញមកលើតំណាងសហគមន៍ដីក្រហមដែលភាគច្រើនផ្អែកលើការបង្កហេតុបណ្តឹង និងការចោទប្រកាន់របស់ក្រុមហ៊ុនសេវេន អេនជី។



អ្នកភូមិវាយតបតជាមួយនគរបាល ខណៈពេលពួកគេព្យាយាមការពារលំនៅស្ថានរបស់ពួកគេ

នៅថ្ងៃទី៣ ខែកក្កដា តុលាការបានចោទប្រកាន់តំណាងសហគមន៍ ប្រាំ នាក់ ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។ ការចោទប្រកាន់នោះ ត្រូវបានធ្វើឡើងផ្អែកទៅលើបណ្តឹងព្រហ្មទណ្ឌរបស់ក្រុមហ៊ុនសេវេនអេនជី ហើយភ្ជាប់ជាមួយព្រឹត្តិការណ៍ថ្ងៃទី២៦-៣០ ខែមិថុនា ដែលអ្នកភូមិបានវាយបំផ្លាញរបង ដែលក្រុមហ៊ុនបានធ្វើព័ទ្ធជុំវិញដីសហគមន៍នោះ។

នៅថ្ងៃទី៣ ខែតុលា តំណាងសហគមន៍ ប្រាំ នាក់ រួមមានទាំងតំណាងសហគមន៍ បី នាក់ ត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិថ្មីទៀត។ តំណាងម្នាក់ជាស្ត្រីឈ្មោះ ទូច រដ្ឋា ត្រូវបានចោទប្រកាន់ថែមទៀត ពីបទប្លន់

ដោយផ្អែកទៅលើឧបទ្ទវហេតុមួយ ដែលកើតឡើងក្នុងសន្និសីទកាសែតមួយកាលពីថ្ងៃទី២៧ ខែកញ្ញា ពេលដែលសន្តិសុខក្រុមហ៊ុនម្នាក់បានព្យាយាមថតរូបគាត់ដោយប្រើទូរស័ព្ទដៃ។ តំណាងសហគមន៍រូបនោះបានគ្រវាសដៃរបស់សន្តិសុខនោះចេញ ហើយបណ្តាលឱ្យគាត់ជ្រុះទូរស័ព្ទពីដៃ។ បុរសនោះមិនបានរើសទូរស័ព្ទឡើងវិញទេ បែរជាដើរចេញទៅប្តឹងនគរបាលថា មានចោរលួចទូរស័ព្ទរបស់គាត់។ នគរបាលបានចាប់នាង ទូច វដ្ឋា ទៅប៉ុស្តិ៍នគរបាល ហើយមានមនុស្សជាច្រើនបានទៅចោមរោមតាមមើល ហើយគេបានចោទថា មនុស្សទាំងនោះបានធ្វើឱ្យខូចម៉ូតូរបស់នគរបាលទាំងនេះ ហើយដែលគេសន្មតចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិទៅវិញ។

តុលាការបានចោទប្រកាន់នាង ទូច វដ្ឋា ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិមួយផ្សេងទៀតនៅថ្ងៃទី២២ ខែតុលា ជាមួយនឹងតំណាងពីរនាក់ និងប្រជាពលរដ្ឋសហគមន៍ដីក្រហម ប្រាំ នាក់ទៀត។ ការចោទប្រកាន់នេះទាក់ទងជាមួយព្រឹត្តិការណ៍ថ្ងៃទី១៧ ខែតុលា នៅពេលដែលអាជ្ញាធរសង្កាត់បានលើក បដាដែលសរសេរថាដីក្រហមគឺជា "សួនសាធារណៈ" ហើយអាជ្ញាធរបានចោទប្រកាន់ប្រជាពលរដ្ឋថាបានរុះរើបដានោះចោល។

ក្រោយមកនៅថ្ងៃទី៧ ខែធ្នូ តំណាងសហគមន៍ ពីរ នាក់ត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបង្ករបួសស្នាម ហើយការចោទប្រកាន់ពេលនេះក៏ផ្អែកលើពាក្យបណ្តឹងរបស់ក្រុមហ៊ុន សេវែនអេនជីដែរ។ បញ្ហានេះទាក់ទងជាមួយព្រឹត្តិការណ៍មួយកាលពីថ្ងៃទី៣ ខែធ្នូ ពេលដែលក្រុមហ៊ុនព្យាយាមបើកគ្រឿងចក្រចូលទៅក្នុងតំបន់ដីក្រហមនោះ ដែលធ្វើឱ្យប្រជាពលរដ្ឋមានការភ័យខ្លាចថាមានការឈូសឆាយផ្ទះសម្បែង។ ពេលនោះអ្នកភូមិខ្លះ (ភាគច្រើនជាកុមារ) បានចោលដុំថ្មទៅលើគ្រឿងចក្រនោះ បណ្តាលឱ្យបែកកញ្ចក់ និងចោទថាធ្វើឱ្យមានរបួសដល់បុគ្គលិកក្រុមហ៊ុន។ ប៉ុន្តែតំណាងសហគមន៍ដែលជាគោលដៅក្នុងការផ្តន្ទាទោស បានអំពាវនាវទៅហ្វូងមនុស្សឱ្យស្ងប់ស្ងាត់ ហើយកុំប្រើអំពើហិង្សាទៅលើបុគ្គលិក ឬ ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនឱ្យសោះ។ បញ្ហាទាំងពីរនេះបានក្លាយជាប្រធានបទ ក្នុងការចោទប្រកាន់ដោយខុសឆ្គងកាលពីដើមឆ្នាំកន្លងមកហើយ។

មនុស្សដែលលើកឡើងខាងលើ បច្ចុប្បន្ននេះនៅមានសេរីភាពនៅឡើយ ទោះបីជាមានការគំរាមថា ត្រូវជាប់ពន្ធនាគាររយៈពេលវែង ព្រមទាំងការដាក់សំពាធឱ្យឈប់ការពារសិទ្ធិរបស់អ្នកភូមិទាំងនោះក៏ដោយ។ ប៉ុន្តែ តំណាងម្នាក់ជាស្ត្រីភេទ ឈ្មោះ រស់ ពៅ សំណាងអាក្រក់ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៤ ខែកញ្ញា ក្រោមការចោទប្រកាន់ពីបទបង្ករបួសស្នាម ហើយត្រូវបានឃុំឃាំងក្នុងពន្ធនាគារព្រៃសរ។ តុលាការបានចោទប្រកាន់គាត់ថាបានបំពាន និងបង្ករបួសស្នាមដល់កម្មករក្រុមហ៊ុន សេវែនអេនជី ក្នុងឧប្បត្តិហេតុមួយកើតឡើងកាលពីថ្ងៃទី៤ ខែសីហា ពេលដែលកម្មករមួយក្រុមចូលមករុះរើផ្ទះសម្បែងនៅក្នុងសហគមន៍។ បុគ្គលិកសិទ្ធិមនុស្សម្នាក់ដែលមានវត្តមាននៅសហគមន៍ក្នុងពេលរុះរើនោះ ពុំបានឃើញនាងបានបង្ករបួសស្នាមលើអ្នកណាម្នាក់ទេ ប៉ុន្តែនៅថ្ងៃទី២១ ខែមករា ២០០៨ នាងត្រូវបានតុលាការផ្តន្ទាទោសពីបទបង្ករបួសស្នាម ហើយដាក់ពន្ធនាគារ ៦ ខែ ព្រមទាំងព្យួរទោស ១៨ ខែថែមទៀត។ ការផ្តន្ទាទោសនេះ គឺធ្វើឡើងដោយផ្អែកលើការចោទប្រកាន់ដាក់បន្ទុករបស់បុគ្គលិកក្រុមហ៊ុន សេវែន

អេនជី តែមួយគត់ ហើយការចោទប្រកាន់នោះ ក៏មិនបានលើកយកលិខិតកោសល្យវិច័្ឆយពេទ្យមកបង្ហាញជាភស្តុតាង អំពីរបួសស្នាមនោះទេ ។

មកដល់ពេលនោះ តុលាការក្រុងភ្នំពេញ បានបង្ហាញនូវការចាប់អារម្មណ៍តិចតួចក្នុងការចាត់ការពាក្យបណ្តឹងរបស់សហគមន៍ដីក្រហមដែលបានប្តឹងក្រុមហ៊ុន សេរេនអេនជី និងមនុស្សផ្សេងទៀតដែលទទួលខុសត្រូវក្នុងការក្លែងបន្លំឯកសារដណ្តើមយកដីរបស់ប្រជាពលរដ្ឋទាំងនោះ ។ ផ្ទុយទៅវិញតុលាការហាក់ដូចសប្បាយចិត្តក្នុងការចោទប្រកាន់ និងផ្តន្ទាទោសតំណាងសហគមន៍ពីបទព្រហ្មទណ្ឌធ្ងន់ធ្ងរ ដោយគ្មានភស្តុតាងទៅវិញ ។

## ករណីសិក្សាៈ ជម្លោះដីធ្លីនៅភូមិគងយុ

ជម្លោះរវាងជនជាតិចារ៉ាយ នៅខេត្តរតនគិរី និងសាច់ញាតិរបស់មន្ត្រីរដ្ឋាភិបាលដ៏មានអំណាចម្នាក់បានក្លាយទៅជាករណីសាកល្បងមួយកាន់តែធំឡើងៗ ដោយមិនត្រឹមតែជាករណីសាកល្បងការគោរព កិច្ចការពារផ្នែកច្បាប់ដីធ្លីរបស់ជនជាតិដើមភាគតិចប៉ុណ្ណោះទេ ប៉ុន្តែករណីនេះក៏ជាការសាកល្បងដល់មេធាវីសិទ្ធិមនុស្សផងដែរ ថាតើពួកគេអាចការពារកូនក្តីរបស់ខ្លួនដោយសេរីបានដែរឬទេ ។

នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៧ តំណាងប្រជាពលរដ្ឋភូមិគងយុ និងគងធំ ស្រុកអូរយ៉ាដាវ ១២ នាក់ បានដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី និងព្រហ្មទណ្ឌទៅតុលាការខេត្តរតនគិរី ប្តឹងទាមទារដី ៤៥០ ហិកតា ជាដីរួមរបស់សហគមន៍ដែលត្រូវបានគេរំលោភយកកាលពីឆ្នាំ២០០៤ កន្លងទៅ ។ ដីនោះត្រូវបានរំលោភយកដោយលោកជំទាវ គាត កុល្យណី ប្អូនស្រីរបស់លោក គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាភរិយាលោក ឆាន់ សាផាន់ រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

លោកជំទាវ គាត កុល្យណី នៅតែអះអាងថា បានទិញដីនោះដោយស្របច្បាប់ ។ ចំណែកប្រជាពលរដ្ឋវិញបាននិយាយថា ពួកគេត្រូវបានគេបោកបញ្ឆោតយកដីនោះ ។ ដើមឡើយ គេបានយល់ព្រមផ្តល់ដីទំហំ ៥០ ហិកតា ប៉ុណ្ណោះឱ្យទាហ៊ានរំសាយរបស់សម្តេចនាយរដ្ឋមន្ត្រីដើម្បីប្រើប្រាស់ ដោយពួកគាត់ត្រូវបានគេប្រាប់ថា ទោះបីជាពួកគេមិនឱ្យក៏ដោយ ក៏ត្រូវតែយកដែរ ហើយថាពួកគាត់ត្រូវបានគេបញ្ឆោតឱ្យផ្តិតមេដៃលើក្រដាស *ស* មួយ ក្រោយពីបានផឹកស្រាស្រវឹងរួច ។ មេធាវីរបស់ប្រជាពលរដ្ឋទាំងនោះបានជំទាស់ថា តាមច្បាប់ភូមិបាលឆ្នាំ២០០១ ការផ្ទេរសិទ្ធិកាន់កាប់ដីសមូហភាពរបស់ជនជាតិភាគតិច គឺត្រូវបានហាមឃាត់ ហេតុដូច្នេះ ការលក់ ទិញ និងផ្ទេរគ្រប់ប្រភេទត្រូវចាត់ទុកថាគ្មានសុពលភាពជាស្វ័យប្រវត្តិ ។

នៅថ្ងៃទី២១ ខែមិថុនា លោកជំទាវគាត កុល្យណីបានឆ្លើយតបដោយការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌទៅតុលាការខេត្តរតនគិរី ប្តឹងតំណាងប្រជាពលរដ្ឋទាំង ១២ នាក់នោះវិញ ដោយចោទប្រកាន់ពីបទក្លែងបន្លំ ញុះញង់បរិហារកេរ្តិ៍

និងសមគំនិត។ លោកជំទាវ ក៏បានចោទប្រកាន់មេធាវី ១០ នាក់ មកពីមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ពីបទញុះញង់ប្រជាពលរដ្ឋទាំងនោះឱ្យប្តឹងលោកជំទាវ ប៉ុន្តែបណ្តឹងរបស់លោកជំទាវមិនបានប្តឹងចំឈ្មោះមេធាវីណាម្នាក់ថាជាជនសង្ស័យនៅក្នុងករណីព្រហ្មទណ្ឌទេ។ ប៉ុន្តែ មេធាវីដែលបានឃើញសំណុំរឿងនោះបាននិយាយថា ឈ្មោះរបស់ពួកគេភាគច្រើនមាននៅក្នុងបណ្តឹងនោះ ហើយព្រួយបារម្ភចំពោះបណ្តឹងព្រហ្មទណ្ឌណាមួយដែលអាចប្តឹងបកមកពួកគេវិញ។

ការដាក់សម្ពាធមកលើតំណាងសហគមន៍ បានគាបសង្កត់មកលើពួកគេពេញមួយឆ្នាំ។ នៅខែសីហា លោក សយ សុភាព អ្នកសារព័ត៌មានប្រចាំបណ្តាញទូរទស្សន៍កម្ពុជា ស៊ីធីអិន បានចាក់ផ្សាយរបាយការណ៍ពីរដែលទាក់ទងនឹងជីវទំនាស់។ ការផ្សាយនោះបានលំអៀងទៅខាងលោកជំទាវ គាត កុល្យាណី យ៉ាងខ្លាំង ហើយបានចោទប្រកាន់អង្គការមិនមែនរដ្ឋាភិបាលថា បានញុះញង់ប្រជាពលរដ្ឋ។ នៅក្នុងការផ្សាយនោះ ទូរទស្សន៍ពុំបានសម្ភាសន៍ប្រជាពលរដ្ឋ ឬមេធាវី អង្គការមិនមែនរដ្ឋាភិបាលណាមួយទេ ប៉ុន្តែ បែរជាចាក់ផ្សាយបទសម្ភាសន៍ជាមួយសាច់ញាតិរបស់អតីតមេភូមិដែលប្រជាពលរដ្ឋបានចោទប្រកាន់ថា ជាអ្នករត់ការក្នុងការរំលោភយកដីនោះទៅវិញ។[៥៦]

ពេលដែលការផ្សព្វផ្សាយជុំវិញករណីនោះចេះតែកើនឡើង អាជ្ញាធរមូលដ្ឋានបានព្យាយាមហាមឃាត់អ្នកការពារសិទ្ធិមនុស្សពីមជ្ឈដ្ឋានខាងក្រៅ មិនឱ្យចូលទៅភូមិគងយុ។ នៅខែកញ្ញា និងខែវិច្ឆិកា អាជ្ញាធរមូលដ្ឋានបានហាមឃាត់អង្គការមិនមែនរដ្ឋាភិបាលចំនួនពីរ ដែលបានគ្រោងទៅរៀបចំវេទិកាសាធារណៈនៅភូមិគងយុ ហើយបុគ្គលិកអង្គការទាំងនោះត្រូវបាននគរបាលរាំងផ្លូវមិនឱ្យចូលទៅកាន់ភូមិនោះ។ នៅខែតុលា ក្រុមអ្នកច្បាប់របស់តំណាងសហគមន៍ផ្ទាល់ ក៏ត្រូវបានហាមឃាត់មិនឱ្យចូលក្នុងភូមិនោះដែរ ពេលដែលពួកគេព្យាយាមទៅជួបអតិថិជនរបស់ខ្លួន។ ហើយនៅខែធ្នូ មន្ត្រីសាលាស្រុកដែលអមដំណើរដោយនគរបាល និងយោធាប្រដាប់ដោយអាវុធគ្រប់ដៃបានឃាត់ដំណើរលោក យ៉ាស់ ហ្គាយ ដែលជាតំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្រោយពីលោកបានជួបប្រជុំជាមួយប្រជាពលរដ្ឋរួច ដោយចោទប្រកាន់គាត់ថាចូលមកក្នុងភូមិដោយគ្មានការអនុញ្ញាត។ ប៉ុន្តែ លោក អួន គិត អភិបាលរងស្រុក មិនហ៊ានចាប់ខ្លួនលោក យ៉ាស់ ហ្គាយទេ នៅពេលដែលគាត់អញ្ជើញលោកអភិបាលឱ្យចាប់ ប្រសិនបើគាត់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ។

បច្ចុប្បន្ននេះ ក្រុមមេធាវីសិទ្ធិមនុស្សកំពុងប្រឈមមុខបញ្ហាផ្ទាល់ខ្លួនថែមទៀត។ មិនត្រឹមតែពួកគេមានឈ្មោះនៅក្នុងបណ្តឹងព្រហ្មទណ្ឌប៉ុណ្ណោះទេ ប៉ុន្តែនៅថ្ងៃទី១៩ ខែមិថុនា លោកជំទាវ គាត កុល្យាណី បានដាក់ពាក្យបណ្តឹងទៅគណៈមេធាវី ដោយបានរាយនាមក្រុមមេធាវីអង្គការមិនមែនរដ្ឋាភិបាលទាំង ១០ នាក់នោះ។ ដោយចោទប្រកាន់មេធាវីទាំងនោះពីបទញុះញង់អ្នកភូមិឱ្យប្តឹងដោយខុសច្បាប់ និងបង្ខូចកេរ្តិ៍ឈ្មោះលោកជំទាវ ព្រមទាំងបានស្នើឱ្យគណៈ

[៥៦] *សេចក្តីថ្លែងព័ត៌មានរួមចេញផ្សាយដោយបណ្តាញអង្គការមិនមែនរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលអំពីការចាក់ផ្សាយរបស់ទូរទស្សន៍ ស៊ីធីអិន* ដែលបានរាយការណ៍ពីភូមិគងយុ ស្រុកអូរយ៉ាដាវ ខេត្តរតនគីរីថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៧។

មេធាវី "ចាត់វិធានការច្បាប់ក្នុងការស៊ើបអង្កេតករណីនេះ"។[៥៧] គណៈមេធាវីបានបើកការស៊ើបអង្កេតករណីនោះ ដោយតម្រូវឱ្យមេធាវីម្នាក់ៗ ឆ្លើយតបទៅនឹងការចោទប្រកាន់នោះ ហើយអាចប្រឈមមុខនឹងការមិនឱ្យធ្វើការថែមទៀត។

ភ្លាមៗនោះ សម្ពាធក៏កាន់តែកើនឡើង។ នៅថ្ងៃទី២៤ ខែមិថុនា លោក លី តាយសេង អគ្គលេខាធិការនៃគណៈមេធាវីបានបញ្ជាក់ជាសាធារណៈថា អង្គការមិនមែនរដ្ឋាភិបាលត្រូវតែចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ជាមួយគណៈមេធាវីដើម្បីជួលមេធាវីធ្វើការស្របច្បាប់។ គាត់បានចោទប្រកាន់មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ដែលជាអង្គការមួយ ក្នុងចំណោមអង្គការទាំងពីរដែលបានបញ្ជូនមេធាវីទៅការពារប្រជាពលរដ្ឋនៅភូមិគងយុថា បានរំលោភ *ច្បាប់ស្តីពីគណៈមេធាវី* ដោយពុំបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដូចដែលគាត់បានលើកឡើង។ លោក លី តាយសេង បានអះអាងថា អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ជាអង្គការទីពីរដែលបានបញ្ជូនមេធាវីការពារប្រជាពលរដ្ឋនៅភូមិគងយុ និងអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ថា អាចរំលោភច្បាប់ផងដែរ។[៥៨] នៅថ្ងៃទី២២ ខែមិថុនា គណៈមេធាវីបានសរសេរលិខិតមួយច្បាប់ទៅអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដោយអះអាងថា អង្គការណាដែលជួលមេធាវីឱ្យបម្រើការ គឺជាអំពើល្មើសច្បាប់ ពីព្រោះការធ្វើបែបនេះអាចរំលោភលើឯករាជ្យភាព និងស្វ័យភាពរបស់វិជ្ជាជីវៈច្បាប់។ អ្នកវិភាគផ្សេងៗមកពីអង្គការជំនួយផ្នែកច្បាប់នានា មិនឯកភាពចំពោះការបកស្រាយ *ច្បាប់ស្តីពីគណៈមេធាវី* បែបនេះទេ ដោយជំទាស់ថា គ្មានហេតុផលណាដែលមេធាវីបំរើការក្នុងអង្គការបាត់បង់ឯករាជ្យភាពរបស់ ខ្លួនទេ។[៥៩]

ការគំរាមកំហែងមកលើមេធាវីសិទ្ធិមនុស្សបែបនេះ គឺពុំមែនជារឿងថ្មីទេ។ នៅខែឧសភា ឆ្នាំ២០០៧ មេធាវីកម្មសិក្សា ១២ នាក់ ដែលធ្វើការជាមេធាវីកម្មសិក្សានៅតាមអង្គការសិទ្ធិមនុស្ស និងអង្គការមិនមែនរដ្ឋាភិបាលនានា ត្រូវបានគណៈមេធាវីបង្ខំឱ្យឈប់ពីការងារ។ ប្រធានគណៈមេធាវី លោក គី តិច បានគំរាមបដិសេធមិនដាក់បញ្ចូលមេធាវីកម្មសិក្សាទាំងនោះ ចូលទៅក្នុងបញ្ជីគណៈមេធាវីទេ ប្រសិនបើពួកគេនៅតែបន្តធ្វើកម្មសិក្សា ដែលឧបត្ថម្ភដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។ មេធាវីកម្មសិក្សាទាំងនោះបានឈប់ពីសកម្មភាពកម្មសិក្សារបស់ខ្លួន។

[៥៧] ប្រាក់ ចាន់ថុល និង អេរិកា ឃីណេត : *លោកជំទាវ គាត កុល្យណី ប្តឹងមេធាវី ១០ នាក់*។ កាសែតឌឹ ឃែមបូឌាដេលីថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ២០០៧ ។

[៥៨] អេរិកា ណេត និង យន់ សាមាន: *គណៈមេធាវីសួរអំពីសិទ្ធិផ្លូវច្បាប់របស់ក្រុមមេធាវីជំនួយច្បាប់*។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ២០០៧ ។

[៥៩] អេរីកា ណេត និង ប្រាក់ ចាន់ថុល: *គណៈមេធាវីបានប្រាប់អង្គការមិនមែនរដ្ឋាភិបាល ឈប់ជួលមេធាវីធ្វើការជាបុគ្គលិក*។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧។

ប៉ុន្តែ ការកំណត់ពេលក្នុងការចេញសេចក្តីថ្លែងការណ៍បែបនេះ ចេញប៉ុន្មានថ្ងៃក្រោយពីលោកជំទាវ គាត កុល្យាណី បានប្តឹងទៅគណៈមេធាវី ដែលអាចសន្និដ្ឋានថា ជាការបំភិតបំភ័យដល់មេធាវីការពារប្រជាពលរដ្ឋភូមិគងយុ។ នៅដំណាច់ឆ្នាំនោះ យ៉ាងតិចមេធាវីពីរនាក់ ដែលបារម្ភពីសុវត្ថិភាព បានលាលែងពីអង្គការនោះ ហើយឈប់ការពារក្តីឱ្យប្រជាពលរដ្ឋនៅភូមិគងយុ។ គេអាចយល់បានថា អតីតមេធាវីការពារប្រជាពលរដ្ឋភូមិគងយុ មិនចង់និយាយពីករណីនិងសម្ពាធដែលបានគាបសង្កត់មកលើពួកគេឡើយ។ ទោះជាយ៉ាងណាក្តី លីកាដូបានទទួលព័ត៌មានដែលគួរឱ្យទុកចិត្តបានថា យ៉ាងហោចណាស់មេធាវីជាច្រើននាក់ ក្នុងចំណោមមេធាវីដែលបានលាលែងពីតំណែង ធ្លាប់បានទទួលរងនូវការបំភិតបំភ័យ (រួមមានដូចជាការគំរាមសម្លាប់) មុនពេលដែលពួកគាត់សំរេចចិត្តលាឈប់ពីការងាររបស់ពួកគេ។

នៅដំណាច់ឆ្នាំ២០០៧ គ្មានករណីជម្លោះណាមួយនៅភូមិគងយុ ត្រូវបានដោះស្រាយទេ។ នៅខែមេសា ២០០៨ ចៅក្រមស៊ើបអង្កេតតុលាការខេត្តរតនគិរី លោក យ៉ា ណារិន្ទ បានប្រកាសថា គាត់ឈប់ធ្វើការស៊ើបអង្កេតករណីបណ្តឹងរដ្ឋប្បវេណីរបស់ប្រជាពលរដ្ឋ ដែលប្តឹងទាមទារដីពីលោកជំទាវ គាត កុល្យាណី នៅភូមិគងយុទៀត ហើយលោកចៅក្រមនោះ បាននិយាយថា គាត់មិនសប្បាយចិត្ត ដែលគ្មានភាគីណាមួយក្នុងចំណោមភាគីទាំងពីរយល់ព្រមបង់ប្រាក់ថ្លៃសេវាកម្មតុលាការចំនួន ១.៥០០ ដុល្លារ ទេ ហើយប្រជាពលរដ្ឋបានបដិសេធមិនឱ្យក្រុមហ៊ុនរបស់លោកជំទាវ គាត កុល្យាណី ចុះវាស់ដីសម្រាប់ករណីតុលាការនោះទេ។[៦០] ទោះបីជាមានមេធាវី ភាគច្រើនបានឈប់ការពារក្តីករណីនោះតទៅទៀតក៏ដោយ តែការស៊ើបអង្កេតរបស់គណៈមេធាវី ក្នុងករណីរបស់មេធាវីទាំងនោះនៅតែមិនទាន់ឈប់នៅឡើយ ហើយពួកគេក៏មិនបានដឹងពីលទ្ធផលនៃការស៊ើបអង្កេតនោះដែរ។

□□□

[៦០] យន់ សាមាន: *ចៅក្រមក្នុងករណីទំនាស់ដីធ្លី ឈប់បន្តស្វែងរកភស្តុតាងតទៅទៀត*។ កាសែត ឌឹ ឃែមបូឌាដេលីចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៨។ យោងតាមទីប្រឹក្សាច្បាប់ដែលបានដឹងករណីនោះច្បាស់និយាយថា ចៅក្រមមិនបានចេញបញ្ជាឱ្យបង់ថ្លៃសេវាកម្មតុលាការដែលតម្រូវដោយច្បាប់នីតិវិធីរដ្ឋប្បវេណីទេ ។

# ៤. អនុសាសន៍

លីកាដូជឿជាក់ថា រាជរដ្ឋាភិបាលគួរចាត់វិធានការដូចខាងក្រោមនេះ ហើយសហគមន៍អន្តរជាតិគួរទទូចឱ្យរាជរដ្ឋាភិបាលអនុវត្តអនុសាសន៍ទាំងនេះ។

- ចាត់វិធានការជាបន្ទាន់ ដើម្បីស៊ើបអង្កេត និងផ្តន្ទាទោសជនល្មើសដែលបានប្រព្រឹត្តអំពើហិង្សា និងបំភិតបំភ័យមកលើអ្នកការពារសិទ្ធិមនុស្ស ។
- សូមឱ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់សហការ និង ឈប់បង្កឧបសគ្គរារាំងសកម្មភាពស្របច្បាប់របស់អង្គការសិទ្ធិមនុស្សនានា។
- លុបបទល្មើសបរិហារកេរ្តិ៍ចេញពីបទព្រហ្មទណ្ឌទាំងស្រុង ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន (ច្បាប់អ៊ុនតាក់) ព្រមទាំងលុបបទល្មើសផ្សាយព័ត៌មានមិនពិតចេញពីបទព្រហ្មទណ្ឌផងដែរ។ ធានាយ៉ាងណាកុំឱ្យមានបញ្ញត្តិ បរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិតនៅក្នុងក្រមព្រហ្មទណ្ឌថ្មីដែលនឹងត្រូវចេញនៅពេលឆាប់ៗនេះ។
- ធ្វើការផ្សព្វផ្សាយនូវសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីៗ ហើយស្វាគមន៍ចំពោះការផ្តល់មតិយោបល់ទៅលើខ្លឹមសាររបស់វា។
- លុបចោលមាត្រា ៣៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ហើយជំនួសមកវិញនូវមាត្រាណាមួយដែលសង្កត់ធ្ងន់ទៅលើគោលការណ៍សេរីភាពរបស់ជនណាដែលត្រូវបានលើកលែងការចោទប្រកាន់នៅតុលាការ ឬ បានបម្រើទោសចប់សព្វគ្រប់រួចហើយ។ ពេលដែលមាត្រាទាំងនេះនៅមិនទាន់បានធ្វើវិសោធនកម្មនៅឡើយ អគ្គព្រះរាជអាជ្ញាគួរចាត់វិធានការជាបន្ទាន់ ដើម្បីណែនាំគោលការណ៍នេះដល់ព្រះរាជអាជ្ញាទាំងអស់ទូទាំងប្រទេស ហើយធ្វើយ៉ាងណាឱ្យការបន្តឃុំឃាំងធ្វើតែចំពោះករណីធ្ងន់ធ្ងរប៉ុណ្ណោះ។
- ជំទាស់ការទាមទាររបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះការស្នើឱ្យមានអនុស្សរណៈនៃការយោគយល់គ្នា ក្នុងការជួលមេធាវីបំរើការងារនៅក្នុងអង្គការកម្ពុជានានា ហើយត្រូវធ្វើយ៉ាងណាឱ្យមេធាវីទាំងអស់នៅកម្ពុជា មានលទ្ធភាពតំណាងកូនក្តីរបស់ខ្លួន ដោយគ្មានការភ័យខ្លាចចំពោះបញ្ហាសុវត្ថិភាពផ្ទាល់ខ្លួន។
- ចាត់វិធានការបញ្ចប់ការធ្វើទុក្ខបុកម្នេញដល់ព្រះសង្ឃខ្មែរកម្ពុជាក្រោម ដែលចូលរួមក្នុងការតស៊ូមតិដោយស្របច្បាប់ និងសន្តិវិធី ព្រមទាំងចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាន និងការតវ៉ា។

- ចេញសេចក្តីណែនាំ ដើម្បីបំភ្លឺអំពីបញ្ហាច្បាប់នៅកម្ពុជាឱ្យបានច្បាស់លាស់ ស្តីពីខ្មែរកម្ពុជាក្រោមមកពីទឹកដីកម្ពុជាក្រោម នៅប្រទេសវៀតណាម ដូចជា ស្ថានភាពអន្តោប្រវេសន៍ និងសិទ្ធិដែលទទួលបាននៅក្នុងច្បាប់ប្រទេសកម្ពុជា។
- អនុវត្តតាមឱ្យបានពេញលេញនូវកាតព្វកិច្ច តាមអនុសញ្ញាស្តីពីជនភៀសខ្លួន ឆ្នាំ១៩៥១ ហើយបញ្ឈប់ការគំរាមកំហែង ការយាយីរំខាន និងការបំភិតបំភ័យចំពោះបុគ្គលទាំងឡាយដែលបានជួយអ្នកស្វែងរកសិទ្ធិជ្រកកោន។
- ច្បាប់ទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាដីធ្លី និងធនធានធម្មជាតិត្រូវអនុវត្តប្រកបដោយយុត្តិធម៌ និងត្រឹមត្រូវដោយតុលាការកម្ពុជា។
- ត្រូវធានាថា គ្រប់ភាគីនានានៅក្នុងទំនាស់ដីធ្លី និងធនធានធម្មជាតិ មិនត្រូវចោទប្រកាន់ពីបទរំលោភលើទ្រព្យសម្បត្តិអ្នកដទៃ ក្នុងខណៈដែលភាពជាម្ចាស់កម្មសិទ្ធិដី ឬ ធនធានធម្មជាតិនោះ នៅមិនទាន់បានដោះស្រាយនៅឡើយ។

□□□

# ឧបសម្ព័ន្ធៈ តារាងព្រឹត្តិការណ៍ឧប្បត្តិហេតុកើតឡើងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាពីខែមករាដល់ខែធ្នូ ឆ្នាំ២០០៧

| កាលបរិច្ឆេទ | ព័ត៌មានលំអិតអំពីករណី |
| --- | --- |
| ថ្ងៃទី១ ខែមករា | **ការរារាំងការតវ៉ាជំទាស់ការលក់បឹងសាធារណៈនៅខេត្តកំពត**[៦១]<br>▪ មនុស្សជាង ៦៤ នាក់ តំណាងឱ្យអ្នកប្រជាពលរដ្ឋរាប់រយនាក់មកពីឃុំនានា បានធ្វើការតវ៉ាជំទាស់នឹងអ្នកលក់ទិញដីដែលកំពុងវាស់វែងបឹងមួយនៅស្រុកកំពង់ត្រាច ។<br>▪ ប្រជាពលរដ្ឋដែលរស់នៅដោយប្រកបរបរនេសាទ និងបូមទឹកពីបឹងបញ្ចូលស្រែបានអះអាងថា បឹងនេះត្រូវបានអាជ្ញាធរមូលដ្ឋានលក់ឱ្យទៅក្រុមហ៊ុនឯកជនមួយ ។<br>▪ ទោះបីជាគ្មានសេចក្តីរាយការណ៍ស្តីពីអំពើហិង្សាក៏ដោយ តែមាននគរបាលពីរនាក់ប្រដាប់ដោយអាវុធអាកា៤៧ បានរារាំងប្រជាពលរដ្ឋមិនឱ្យដើរទៅកាន់បឹងនោះដែរ ។<br>▪ ទីបំផុតអាជ្ញាធរនៅតែលក់បឹងនោះបានជោគជ័យ ហើយគ្រួសារអ្នកភូមិមួយចំនួនបានទទួលបានសំណងពី ១០០ ទៅ ២០០ ដុល្លារអាមេរិក ។ |
| ថ្ងៃទី៣ ខែមករា | **តំណាងសហគមន៍ជាច្រើននាក់ត្រូវបានវាយដំ និងចាប់ខ្លួននៅក្នុងករណីជម្លោះដីធ្លីមួយនៅក្រុងព្រះសីហនុ**[៦២]<br>▪ លោក ផាន ប៊ុនធី អាយុ ៤៥ ឆ្នាំ និងប្រពន្ធឈ្មោះ មាស នាង អាយុ៤២ឆ្នាំ រងការវាយដំ និងឆក់ដោយដំបងឆក់ ពីសំណាក់នគរបាលនៅក្នុងជម្លោះដីធ្លីមួយកន្លែងក្នុងមណ្ឌល១ នៃខណ្ឌមិត្តភាព ។ ក្រោយមក លោក ផាន ប៊ុនធីត្រូវចាប់ខ្លួនហើយដាក់ឃុំឃាំងក្នុងពន្ធនាគារ ។<br>▪ ប្រជាពលរដ្ឋក្រុងព្រះសីហនុប្រមាណជាង ៣០ នាក់ បានមកតវ៉ានៅខាងមុខស្នងការនគរបាលក្រុងទាមទារឱ្យដោះលែងលោក ផាន ប៊ុនធី វិញ ។<br>▪ ថ្ងៃទី៦ ខែមករា ប្រជាពលរដ្ឋ ៧ នាក់ ត្រូវបានតុលាការក្រុងកោះហៅសួរចម្លើយ |

[៦១] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ : សូមអានអត្ថបទកាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៣ ខែមករា ឆ្នាំ២០០៧ សរសេរដោយ គុជ ណារ៉ែន ដែលមានចំណងជើងថា : *អ្នកតវ៉ានិយាយថា មេឃុំលក់បឹងរបស់ស្រុក*។

[៦២] គុជ ណារ៉ែនៈ *ពាតុករបានទាមទារឱ្យអាជ្ញាធរដោះលែងបុរសជាច្រើននាក់ដែលត្រូវបានចាប់ និងឃុំខ្លួន* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៥ ខែមករា ឆ្នាំ២០០៧ ។

និងចោទប្រកាន់ថា បានញុះញង់ប្រជាពលរដ្ឋឱ្យវាយនគរបាល ប៉ុន្តែក្រុមអ្នកស៊ើបអង្កេតសិទ្ធិមនុស្សបានសង្កេតឃើញថា ប្រជាពលរដ្ឋមិនបានវាយនគរបាលទេ ក្នុងព្រឹត្តិការណ៍ហិង្សានោះទេ។

- អ្នកដែលត្រូវបានចាប់ខ្លួន ត្រូវបានដោះលែងវិញ បន្ទាប់ពីប្រជាពលរដ្ឋបានធ្វើការតវ៉ាទាមទារនៅមុខតុលាការក្រុង។
- ការចោទប្រកាន់នៅតែបន្ត ហើយប្រជាពលរដ្ឋនៅបន្តរស់នៅលើដីទំនាស់នៅឡើយ។

**ថ្ងៃទី៨ ខែមករា**

**សកម្មជនសហជីពនៅភ្នំពេញ ត្រូវបានបណ្ដេញចេញពីការងារដោយសារការធ្វើកូដកម្មគាំទ្រសហការីដែលត្រូវបានបញ្ឈប់ពីការងារ**[៦៣]

- បុគ្គលិកក្រុមហ៊ុនទូរទស្សន៍ខ្សែកាបរាជធានីភ្នំពេញចំនួន ២២ នាក់ នៅខណ្ឌ៧មករា ក្រុងភ្នំពេញ ត្រូវបានបណ្ដេញចេញពីការងារ ដោយសារបុគ្គលិកទាំងនោះបានធ្វើកូដកម្មគាំទ្រសមាជិកសហជីពផ្សេងៗទៀត។
- សកម្មជនទាំងនោះបានទាមទារឱ្យក្រុមហ៊ុនផ្ដល់ការងារដល់បុគ្គលិក ៨ នាក់ ដែលត្រូវបានបញ្ឈប់ពីការងារកាលពីឆ្នាំ២០០៦ ដោយសារតែបុគ្គលិកទាំងនោះបាននាំគ្នាបង្កើត សហជីពនៅក្នុងក្រុមហ៊ុន ។
- បន្ទាប់ពីមានការចរចារនៅថ្ងៃទី១៥ ខែមករា សកម្មជនជាច្រើនត្រូវបានអនុញ្ញាតឱ្យចូលធ្វើការវិញ។ ប៉ុន្តែក្រុមហ៊ុនបានបដិសេធមិនផ្ដល់ការងារឱ្យសកម្មជនចំនួន ៥ នាក់ ដោយក្រុមហ៊ុនបានចោទប្រកាន់ថា បានលួចតខ្សែកាបខុសច្បាប់ដើម្បីយកផលចំណេញផ្ទាល់ខ្លួន។

**ថ្ងៃទី១១ ខែមករា**

**សកម្មជនសហជីពនៅភ្នំពេញត្រូវបានចាប់ខ្លួន ក្នុងពេលតវ៉ាជំទាស់នឹងការបណ្ដេញសហការីចេញពីការងារ**[៦៤]

- លោក អេង វណ្ណា ប្រធានសហជីពប្រចាំនៅក្រុមហ៊ុនទូរទស្សន៍ខ្សែកាបរាជធានីភ្នំពេញ និងអនុប្រធានរបស់គាត់ឈ្មោះ លី សេងហ៊ន ព្រមទាំងតំណាងសហព័ន្ធសហជីពសេរីឈ្មោះ ប៉ុល សុភ័ក្រ ត្រូវបានចាប់ខ្លួននៅក្នុងការអង្គុយតវ៉ានៅខាងក្រៅការិយាល័យក្រុមហ៊ុនក្នុងខណ្ឌ៧មករា។

---

[៦៣] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ។

[៦៤] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ។ សូមអានអត្ថបទសរសេរដោយ យន់ សាមាន ដែលមានចំណងជើងថា *បុរស ៣ នាក់ ត្រូវចាប់ខ្លួន ដោយបានចូលរួមនៅក្នុងការអង្គុយតវ៉ា* ។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១២ ខែមករា ឆ្នាំ២០០៧ និងអត្ថបទមានចំណងជើងថា *មេដឹកនាំសហជីពនៃក្រុមហ៊ុនទូរទស្សន៍ខ្សែកាបរាជធានីភ្នំពេញ ត្រូវបានឃុំខ្លួន* សេចក្ដីប្រកាសព័ត៌មានរបស់ (FTUWKC) ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៧។

**ថ្ងៃទី១៩ ខែមករា**

- បុរសទាំង ៣ នាក់ បានតវ៉ាជំទាស់នឹងការបណ្តេញបុគ្គលិក ២២ នាក់ ដែលជាសមាជិកសហជីពកាលពី២ថ្ងៃមុន និងជំទាស់ការបណ្តេញបុគ្គលិក៨នាក់ទៀតកាលពីឆ្នាំ២០០៦។
- បុរសទាំង៣នាក់នោះ ត្រូវបានឃុំខ្លួននៅអធិការដ្ឋាននគរបាលខណ្ឌអស់រយៈពេលជាច្រើនម៉ោង ហើយក្រោយមកត្រូវបានដោះលែងវិញ ក្រោយពេលយល់ព្រមចុះកិច្ចសន្យាថា មិនធ្វើបាតុកម្មទៀតទេ ។

**តំណាងសហគមន៍ត្រូវបានកោះហៅ ដើម្បីសាកសួរអំពីករណីឃាតកម្មនៅខេត្តកោះកុង** [៦៥]

- លោក គង់ ស៊ីនឈួន តំណាងប្រជាពលរដ្ឋ ៥០០ គ្រួសារនៅឃុំជីខលើ ស្រុកស្រែអំបិល ដែលចេញមុខដោះស្រាយបញ្ហាជម្លោះដីធ្លីនៅឃុំជីខលើ ស្រុកស្រែអំបិល ត្រូវបានតុលាការខេត្តកោះកុងហៅសួរចម្លើយ។
- ការសួរចម្លើយនោះពាក់ព័ន្ធទៅនឹងអំពើឃាតកម្មលើប្រជាពលរដ្ឋម្នាក់ឈ្មោះ អាន អ៊ីន (ជនសកម្មម្នាក់ការពារសិទ្ធិដីធ្លីនៅក្នុងឃុំផងដែរ) ដែលស្លាប់ដោយការកាប់នឹងពូថៅកាលពីធ្នូ ឆ្នាំ២០០៦។ ពុំមានភស្តុតាងណាមួយដែលបង្ហាញថា ស៊ីនឈួន ជាប់ពាក់ព័ន្ធនឹងអំពើឃាតកម្មនេះទេ ហើយអ្នកសង្កេតការណ៍ជាច្រើនបារម្ភថា ការកោះហៅនេះគឺជាការបំភិតបំភ័យទៅលើសកម្មភាពតវ៉ាក្នុងករណីជម្លោះដីធ្លីទៅវិញ។
- មេធាវីរបស់លោក ស៊ីនឈួន អាចជួយសុំពន្យារពេលការកោះហៅដើម្បីសាកសួរចម្លើយនោះរហូតដល់ថ្ងៃទី២២ ខែមករា ដែលនៅពេលនោះមានមនុស្ស៥០នាក់បានអមដំណើរគាត់ក្នុងពេលធ្វើដំណើរទីរួមខេត្ត។ ដោយដឹងថា តំណាងសារព័ត៌មានកំពុងរង់ចាំក្រុមមនុស្ស ដែលគាំទ្រគាត់នៅក្នុងទីរួមខេត្ត ហើយមើលទៅខ្លាចមានការផ្សព្វផ្សាយអវិជ្ជមានតុលាការ ក៏បានផ្អាកការសួរចម្លើយនោះវិញ។
- ក្រុមគ្រួសារនៅក្នុងជម្លោះនោះបានអះអាងថា ក្រុមហ៊ុនមួយដែលគ្រប់គ្រងដោយលោក លី យ៉ុងផាត់ ជាសមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា បានកាប់បំផ្លាញដំណាំរបស់ពួកគាត់នៅឆ្នាំ២០០៦ ដើម្បីធ្វើផ្លូវចូលទៅចម្ការអំពៅដែលមានទំហំ ២០.០០០ហិកតា។ នៅខែមិនាឆ្នាំ២០០៧ មានការគំរាមកំហែងមកលើអ្នកតំណាងមួយក្រុម ក្រោយពីពួកអ្នកតំណាងទាំងនោះបានធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បី យកករណីដីធ្លីរបស់ពួកគាត់ ដាក់ជូនអាជ្ញាធរជាតិ (សូមអានទំព័រ ២៥)។

---

[៦៥] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ។

**ថ្ងៃទី២៩ ខែមករា**

**មេដឹកនាំសហជីពត្រូវរងបង្ករបួសស្នាមនៅទីក្រុងភ្នំពេញ**[៦៦]

- លោក សែន ស៊ីធួន ដែលជាប្រធានសហជីពកម្មករនៅរោងចក្រផលិតស្បែកជើងឈ្មោះ ហ្សូព្រីមៀរ (Shoes Premier) ត្រូវបានមនុស្សពាក់ម៉ាស់បិទមុខ បួននាក់ព័ទ្ធវាយ នៅពេលដែលគាត់ចេញពីរោងចក្រនៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ។
- លោក ស៊ីធួន ដែលបានបម្រើការងារជាអគ្គលេខាធិការនៃសហព័ន្ធសហជីពសេរីកម្មករកម្ពុជា ប្រចាំនៅរោងចក្រនោះ ត្រូវបានគេវាយដំដោយបំពង់ដែកបណ្ដាលឱ្យរបួសក្បាលខាងឆ្វេង ។
- ការវាយប្រហារនោះបានកើតឡើងក្រោយពីមានការវាយប្រហារស្រដៀងគ្នានេះមកលើមេដឹកនាំសហជីពជាច្រើនក្នុងឆ្នាំ២០០៦ ហើយជាពិសេសការវាយដំមកលើមេដឹកនាំសហជីពសេរីកម្មករ ( សូមអានទំព័រទី ២១ ) ។

**ថ្ងៃទី១៣ ខែកុម្ភៈ**

**សកម្មជនសហគមន៍ប្រាំនាក់ ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារក្នុងរឿងជម្លោះដីធ្លីមួយនៅខេត្តបាត់ដំបង**[៦៧]

- ប្រជាពលរដ្ឋ ប្រាំ នាក់ រួមមានម្នាក់ជាបុរសចំណាស់វ័យ៧៨ឆ្នាំ ត្រូវបានតុលាការផ្ដន្ទាទោស ពីបទប្រើប្រាស់អំពើហិង្សារំលោភលើទ្រព្យសម្បត្តិឯកជនរបស់អ្នកដទៃនៅក្នុងបញ្ហាជម្លោះដីធ្លីដ៏យូរអង្វែងមួយក្នុងស្រុកបវេល ។
- ចុងចោទសំខាន់ជាងគេគឺឈ្មោះ ឈា នី មិនមានវត្តមាននៅក្នុងសវនាការទេដោយគាត់ត្រូវបានផ្ទេរមកពន្ធនាគារភ្នំពេញ ។ តុលាការបានធ្វើមិនដឹងមិនឮចំពោះការស្នើសុំបញ្ជូន ឈា នី ទៅបាត់ដំបងវិញ ដោយមេធាវីរបស់គាត់ ។
- នៅក្នុងសវនាការនោះ ពុំមានដើមបណ្ដឹង និងសាក្សីណាម្នាក់ឡើងបង្ហាញភស្ដុតាងឡើយ ដែលជាមូលហេតុមិនអាចឱ្យមេធាវីការពារចុងចោទដេញដោលសួរបាន ហើយគ្មានភស្ដុតាងបង្ហាញថា ចុងចោទទាំងនោះបានប្រព្រឹត្តហិង្សាលើនរណាម្នាក់ឡើយ ។
- ទោះបីជាពុំមានភស្ដុតាងគ្រប់គ្រាន់ក៏ដោយ ក៏តុលាការបានផ្ដន្ទាទោសលោក ឈា នី ដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ ព្រមទាំងត្រូវសងជម្ងឺចិត្ត ១.៦ លានរៀល ទៅដើម

[៦៦] *អគ្គលេខាធិការសហព័ន្ធសហជីពសេរីកម្មករកម្ពុជាប្រចាំនៅរោងចក្រផលិតស្បែកជើងត្រូវបានវាយប្រហារ*។ សេចក្ដីប្រកាសព័ត៌មានរបស់សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC) ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ ។

[៦៧] សេចក្ដីថ្លែងព័ត៌មានរបស់លីកាដូថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៧ ក្រោមចំណងជើងថា: *សាលក្រមអយុត្តិធម៌ក្នុងរឿងជម្លោះដីធ្លីនៅស្រុកបវេល*។ សូមអានព័ត៌មានថ្មី *ឈា នី និង ជម្លោះដីធ្លីនៅស្រុក បវេល* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ ។

បណ្ដឹង។ ជនជាប់ចោទ ពីរ នាក់ ទៀតដែលមិនបានចូលខ្លួនក្នុងសវនាការ ដោយពួកគេបានគេចខ្លួន ក៏ត្រូវបានតុលាការផ្ដន្ទាទោសដូចគ្នាដែរ។ ជនជាប់ចោទ ពីរ នាក់ ចុងក្រោយ ម្នាក់ឈ្មោះ ហែម ឡាក់ និងម្នាក់ទៀត ជាបុរសវ័យចំណាស់ ៧៨ ឆ្នាំ ឈ្មោះ មូ សាប់ ដែលបានចូលខ្លួនក្នុងសវនាការនោះ ត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារម្នាក់ៗរយៈពេល៦ខែ។ ដោយជនទាំងពីរនាក់ បានជាប់ឃុំក្នុងពន្ធនាគាររងចាំសវនាការជាង ៦ ខែ រួចហើយ ហេតុនេះ បុរសទាំង ២ នាក់ នោះក៏ត្រូវបានដោះលែងក្រោយពីសវនាការចប់។

- ខែឧសភា ឆ្នាំ២០០៧ ករណី ឈា នី ត្រូវបានលើកយកមកបើកសវនាការជាថ្មីម្ដងទៀត។ ពេលនោះតុលាការបានផ្ដន្ទាទោសគាត់ម្ដងទៀត ប៉ុន្តែបទចោទប្រកាន់ត្រូវបានប្ដូរពីអំពើហិង្សាលើព្រទ្យសម្បត្តិអ្នកដទៃ ទៅជាអំពើហិង្សាលើទ្រព្យសម្បត្តិសាធារណៈវិញ ( សំរាប់ព័ត៌មានលំអិត សូមអានទំព័រខាងក្រោម) ។

ថ្ងៃទី២៦ ខែកុម្ភៈ

**មេដឹកនាំសហជីពម្នាក់ត្រូវបានធ្វើឃាតនៅភ្នំពេញ**[៦៨]

- លោក ហ៊ី វុទ្ធី ប្រធានសហជីពសេរីកម្មករប្រចាំនៅរោងចក្រកាត់ដេរសាន់តិចត្រូវបាន មនុស្សមិនស្គាល់អត្តសញ្ញាណពីរនាក់ជិះម៉ូតូ បាញ់ស្លាប់ក្នុងខណៈដែលគាត់ចេញពីកន្លែងការងារទៅផ្ទះវិញ។
- មុននឹងគាត់ត្រូវបាញ់ស្លាប់ លោក ហ៊ី វុទ្ធី ធ្លាប់បានទទួលការគំរាមសម្លាប់តាមទូរស័ព្ទ ដោយព្រមានគាត់ឱ្យលាឈប់ពីការងារ។
- ក្នុងខណៈពេលដែលកំពុងសរសេររបាយការណ៍នេះ ពុំមាននរណាម្នាក់ត្រូវបានចាប់ខ្លួនក្នុងករណីឃាតកម្មនេះឡើយ។
- លោក ទូច ណារ៉ុថ ស្នងការនគរបាលរាជធានីភ្នំពេញ បានអះអាងថាលោកមានដីកាចាប់ខ្លួនពីរទាក់ទងករណីនេះ។ ប៉ុន្តែ មេធាវីរបស់គ្រួសារជនរងគ្រោះ បាននិយាយថាគ្មានដីកានៅក្នុងសំណុំរឿងរបស់លោកទេ។
- មរណភាពនេះគឺជាការប្រព្រឹត្តិតាមឃាតកម្មលើ មេដឹកនាំសហជីពសេរីកម្មករឈ្មោះ ជា វិជ្ជា និង រស់ សុវណ្ណារេត នៅឆ្នាំ២០០៤ ព្រមទាំងការវាយប្រហារជាច្រើនរាប់មិនអស់មកលើមេដឹកនាំសហជីពសេរីកម្មករ និងសហជីពផ្សេងៗក្នុងឆ្នាំ២០០៦។

[៦៨] *សេចក្ដីថ្លែងការណ៍រួមស្ដីពីករណីឃាតកម្មលើលោក ហ៊ី វុទ្ធី* របស់អង្គការ អាដហុក មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងលីកាដូថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧។ សូមអានអត្ថបទកាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ និងការចុះផ្សាយក្រោយមកទៀត សរសេរដោយ យន់ សាមាន និង ឌូក្លា ជីលសុន ដែលមានចំណងជើងថា: *មន្ត្រីសហជីពត្រូវបានបាញ់សម្លាប់* ។

**ថ្ងៃទី២៧ ខែកុម្ភៈ**

**នគរបាលធ្វើការបង្រ្កាបលើព្រះសង្ឃ ដែលធ្វើការតវ៉ាស្តីពីសិទ្ធិជនជាតិភាគតិចនៅភ្នំពេញ** [៦៩]

- កម្លាំងនគរបាល និងកម្លាំងប្រឆាំងកុបកម្មជាង ១៥០ នាក់ ប្រដាប់ដោយអាវុធ ខែល ឧស្ម័នបង្ហូរទឹកភ្នែក និងដំបងឆក់ត្រូវបានដាក់ពង្រាយតាមផ្លូវ ដើម្បីរារាំងព្រះសង្ឃកម្ពុជាក្រោម ៥២ អង្គ កុំឱ្យធ្វើបាតុកម្មនៅខាងមុខស្ថានទូតវៀតណាម។
- នគរបាលបានព្យាយាមបង្ខំព្រះសង្ឃទាំងនោះចូលទៅក្នុងឡាន ដើម្បីសម្រាតស្បង់ចីពរ ប៉ុន្តែសកម្មភាពនេះត្រូវបានរារាំងដោយការចរចារបស់បុគ្គលិកសិទ្ធិមនុស្ស។
- ព្រះសង្ឃទាំងនោះ បានតវ៉ាជំទាស់នឹងការសម្រេចចិត្តមួយចំនួនរបស់អាជ្ញាធរវៀតណាម ដែលបានផ្សឹកព្រះសង្ឃកម្ពុជាក្រោម ក្រោមការចោទប្រកាន់ថាបានចូលរួមក្នុងបាតុកម្មមួយនៅកម្ពុជាក្រោមវៀតណាមខាងត្បូង។
- ផែនការបាតុកម្មដែលជាផ្នែកមួយនៃយុទ្ធនាការដ៏ធំធ្វើឡើងនៅប្រទេសមួយចំនួន ក្នុងពិភពលោក ដើម្បីតវ៉ាជំទាស់ការផ្សឹកព្រះសង្ឃ។

**ថ្ងៃទី២៧ ខែកុម្ភៈ**

**ការសុគតរបស់ព្រះសង្ឃកម្ពុជាក្រោមនៅខេត្តកណ្តាល បានធ្វើឱ្យមានការសង្ស័យ ក្រោយពីព្រះសង្ឃអង្គនោះ បានចូលរួមការតវ៉ាស្តីពីសិទ្ធិជនជាតិភាគតិច** [៧០]

- ព្រះសង្ឃខ្មែរកម្ពុជាក្រោម ១ អង្គព្រះនាម អេង សុខធឿន ត្រូវបានគេជួបប្រទះសុគតនៅក្នុងវត្តមួយក្នុងស្រុកអង្គស្នួល រយៈពេលប៉ុន្មានម៉ោង ក្រោយពីព្រះអង្គបានចូលរួមតវ៉ានៅមុខស្ថានទូតវៀតណាម ។ មានស្នាមអារដាច់សាច់ពីរបីកន្លែងនៅលើបំពង់ករបស់ព្រះអង្គ។
- អង្គការសិទ្ធិមនុស្សនានាមានការសង្ស័យចំពោះនរគបាល ដែលបានអះអាងថា ព្រះសង្ឃអង្គនោះ បានធ្វើអត្តឃាតដោយអារករដោយអង្គឯង។ អាជ្ញាធរបានយកសាកសពព្រះសង្ឃអង្គនោះ ទៅបញ្ចុះក្នុងរយៈពេល ២៤ ម៉ោងក្រោយពីលោកសុគតដោយពុំទាន់បានធ្វើកោសល្យវិច្ច័យនៅឡើយ។
- ថ្ងៃទី៧ ខែមិនា សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម បានធ្វើសំណើឱ្យព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាលលោក ហួត វុទ្ធី គាស់សាកសពឡើងដើម្បីធ្វើការកោសល្យ

[៦៩] *សេចក្តីថ្លែងការណ៍រួមស្តីពីការបង្រ្កាបលើព្រះសង្ឃដែលតវ៉ាដោយសន្តិវិធី* របស់លីកាដូ អាដហុក និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ និងការផ្សាយបន្តបន្ទាប់ទៀត។ សូមអានបន្ថែមអត្ថបទរបស់ យន់ សាមាន *ព្រះសង្ឃ ៥០ អង្គ ធ្វើការតវ៉ានៅក្បែរស្ថានទូតវៀតណាម* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧។

[៧០] របាយការណ៍ស៊ើបអង្កេតមិនផ្សព្វផ្សាយរបស់លីកាដូ និងសូមអានអត្ថបទកាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៣-៤ ខែមិនា ឆ្នាំ២០០៧ សរសេរដោយ ប្រាក់ ចាន់ថុល មានចំណងជើងថា: *ព្រះសង្ឃមួយអង្គសុគត ក្រោយពីចូលរួមតវ៉ាប្រឆាំងវៀតណាម* ព្រមទាំងអត្ថបទ: *ការអំពាវនាវឱ្យមានការស៊ើបអង្កេតឡើងវិញ ចំពោះការសុគតរបស់ព្រះសង្ឃកម្ពុជាក្រោម* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៧ ខែមិនា ឆ្នាំ២០០៧ អត្ថបទសរសេរដោយ យន់ សាមាន។

វិច្ឆ័យឡើងវិញ ។ លោកព្រះរាជអាជ្ញាពុំទាន់ផ្តល់ការអនុញ្ញាតដល់សំណើនោះនៅឡើយទេ។

**ថ្ងៃទី៧ ខែមិនា**

**អ្នកតវ៉ាបញ្ហាដីធ្លីនៅភ្នំពេញត្រូវបានគំរាមកំហែង** [៧១]

- មនុស្សមួយក្រុមដែលមានគ្នា ១២២ នាក់ មកពីខេត្តកោះកុង ត្រូវបានគេប្រាប់តាមឧបករណ៍បំពងសម្លេងថា ប្រសិនបើពួកគេបន្តបោះតង់នៅលើសួនច្បារមុខរដ្ឋសភាតទៅទៀត ដើម្បីទាមទារដីដែលបាត់បង់ នោះពួកគេ "គ្មានសុវត្ថិភាពទេ" ។
- មនុស្សមួយក្រុមនោះ គឺជាអ្នកតំណាងឱ្យប្រជាពលរដ្ឋជាង ៥០០ គ្រួសារ នៅឃុំជីខលើ ស្រុកស្រែអំបិល ហើយបានមកដល់ភ្នំពេញនៅថ្ងៃទី៦ ខែមិនា បន្ទាប់ពីបានដើរអស់រយៈពេលមួយសប្តាហ៍ ដើម្បីមកជួបសម្តេចនាយករដ្ឋមន្ត្រី ។
- ប្រជាពលរដ្ឋបានអះអាងថា ក្រុមហ៊ុនមួយដែលគ្រប់គ្រងដោយ លោក លី យ៉ុង ផាត់ សមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជាបានបំផ្លាញដំណាំរបស់ពួកគាត់កាលពីឆ្នាំ ២០០៦ ដើម្បីធ្វើផ្លូវចូលទៅចម្ការអំពៅទំហំ ២០.០០០ ហិកតា។
- ក្នុងខែមករា តំណាងប្រជាពលរដ្ឋម្នាក់ត្រូវបានបំភិតបំភ័យ ដោយតុលាការខេត្តកោះកុង ដោយត្រូវបានចោទប្រកាន់ថាពាក់ព័ន្ធជាមួយអំពើឃាតកម្ម លើអ្នកភូមិម្នាក់កាលពីឆ្នាំ២០០៦។ (សូមអានទំព័រ ២៥)។

**ថ្ងៃទី១០ ខែមិនា**

**អ្នកសង្កេតការណ៍សិទ្ធិមនុស្សម្នាក់ត្រូវបានចាប់ឃុំខ្លួន ក្នុងព្រឹត្តិកាណ៍មួយដែលអាជ្ញាធរដេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាននៅខេត្តសៀមរាប** [៧២]

- លោក សួន ណារិន អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស អង្គការអាដហុកប្រចាំនៅខេត្តសៀមរាប និងលោក គង់ លាភ មន្ត្រីនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រចាំនៅខេត្តសៀមរាប ត្រូវបាននគរបាលខេត្តនាំខ្លួនយកទៅសួរចម្លើយ ខណៈដែលពួកគាត់កំពុងសង្កេតការណ៍ក្នុងព្រឹត្តិការណ៍បណ្តេញប្រជាពលរដ្ឋជាង ១០០ គ្រួសារចេញពីដីនៅលើតំបន់អង្គរ។
- បុគ្គលិកសិទ្ធិមនុស្សទាំងពីរនាក់នោះ ត្រូវបានដោះលែងឱ្យមានសេរីភាពវិញមួយម៉ោងក្រោយមក បន្ទាប់ពីត្រូវបានមន្ត្រីអាជ្ញាធរអប្បារាសួរចម្លើយរួច។

---

[៧១] យន់ សាមាន និង ឌូក្លាស ជីលសុនៈ *ប្រជាពលរដ្ឋសង្ឃឹមថា បានជួបនាយករដ្ឋមន្ត្រីអំពីរឿងជម្លោះដីធ្លី* ។ កាសែត ឌឹ ឃែមបូឌាដេលីផ្សាយថ្ងៃទី៩ ខែមិនា ឆ្នាំ២០០៧ និង យន់ សាមាន និង ឌូក្លាស ជីលសុនៈ *ប្រជាពលរដ្ឋតវ៉ារឿងដីធ្លីមកពីខេត្តកោះកុង ត្រូវការការជួយអន្តរាគមន៍ពីសំណាក់នាយករដ្ឋមន្ត្រី* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៧ ខែមិនា ឆ្នាំ២០០៧។

[៧២] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ ។ សូមអានអត្ថបទសរសេរដោយ ជាន សុខា ដែលមានចំណងជើងថាៈ *គ្រួសារចំណោកស្រុកជាច្រើន ត្រូវបានបណ្តេញចេញពីតំបន់អង្គរ* កាសែត ភ្នំពេញប៉ុស្តិ៍ថ្ងៃទី៦-១៩ ខែមេសា ឆ្នាំ២០០៧។

**ថ្ងៃទី១៨ ខែមេសា**

**ការបង្ករបួសស្នាមមកលើមេដឹកនាំសហជីពនៅភ្នំពេញ**[៧៣]

- អ្នកស្រី ឆាំ សាមេន ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជាប្រចាំនៅរោងចក្រ វីវ៉ាទីណូ ឱសាញ ស្ថិតនៅក្នុងខណ្ឌឫស្សីកែវ ត្រូវបានគេវាយបណ្ដាលឱ្យរបួសក្នុងពេលធ្វើកូដកម្ម នៅខាងមុខរោងចក្រ។
- ក្នុងពេលនោះអ្នកស្រី ឆាំ សាមេន (កំពុងមានផ្ទៃពោះផងដែរនោះ) ត្រូវបានគេវាយដំ និងទាត់ធាក់យ៉ាងដំណំបណ្ដាលឱ្យជាំ និងហើមជាច្រើនកន្លែង។ សហព័ន្ធសហជីពកម្មករកម្ពុជា បានអះអាងថាការបង្ករបួសស្នាមនេះបានកើតឡើង ខណៈដែលអង្គរក្សប្រធាន រោងចក្រពីរនាក់បានដណ្ដើមឧបករណ៍បំពងសម្លេងពីដៃនាង។
- សហព័ន្ធសហជីពកម្មករកម្ពុជាបានដាក់ពាក្យបណ្ដឹងទៅក្រសួងការងារ និងសម្ដេចនាយករដ្ឋមន្ត្រីហ៊ុនសែនផងដែរ។ ពាក្យបណ្ដឹងនោះ ត្រូវបានគេលើកលែងការចោទប្រកាន់ បន្ទាប់មានការសងជម្ងឺចិត្តដល់អ្នកស្រី ឆាំ សាមេន។

**ថ្ងៃទី២០ ខែមេសា**

**អ្នកភូមិជនជាតិភាគតិចជាច្រើននាក់ បានជាប់ពន្ធនាគារដោយសារការជួយអ្នកសុំសិទ្ធិជ្រកកោននៅខេត្តរតនគិរី**[៧៤]

- លោក ថុល ងៀង ក្រឡាន ភឿង និងរោចាម ហ្វី ជាជនជាតិចារ៉ាយនៅស្រុកអណ្ដូងមាស ត្រូវបានអាជ្ញាធរចាប់ខ្លួនដោយសារតែពួកគាត់បាននាំផ្លូវក្រុមសុំសិទ្ធិជ្រកកោនជនជាតិម៉ុងតាញ៉ាវៀតណាមចំនួន ១៨ នាក់ ដើម្បីទៅជួបតំណាងអង្គការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន។ តុលាការខេត្តរតនគិរី បានឃុំខ្លួនបុរសទាំង៣នាក់នោះដើម្បីរង់ចាំការផ្ដន្ទាទោស ដោយចោទប្រកាន់ពីបទជួយជ្រោមជ្រែងឱ្យមានអន្តោប្រវេសន៍ខុសច្បាប់។
- ពួកអ្នកភូមិជាច្រើនបានអះអាងថា ជនរងគ្រោះទាំង ៣ នាក់នោះគ្រាន់តែជួយពួកម៉ុងតាញ៉ា ពេលរស់នៅក្នុងទឹកដីប្រទេសកម្ពុជាតែប៉ុណ្ណោះ ដូចជាជួយទិញម្ហូបអាហារ និងសម្ភារៈផ្សេងៗសម្រាប់ក្រុមនោះ ខណៈដែលពួកគេកំពុងរង់ចាំការអនុញ្ញាតពីអាជ្ញាធរ ឱ្យអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សធ្វើដំណើរទៅទទួលពួកគេ។

[៧៣] ព័ត៌មានទទួលបានពីមជ្ឈមណ្ឌលអាមេរិក ដើម្បីសាមគ្គីភាពកម្មករអន្តរជាតិ ខែមេសា ឆ្នាំ២០០៧ និងខែកុម្ភៈ ឆ្នាំ២០០៨។ សូមអានអត្ថបទដែលមានចំណងជើងថា *អង្គរក្សរោងចក្រវាយដំកម្មករដែលធ្វើកូដកម្ម* ។ សេចក្ដីប្រកាសព័ត៌មានរបស់សហជីពសេរីកម្មករកម្ពុជាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៧ ។

[៧៤] ថេត សម្បត្តិ: *អង្គការសហប្រជាជាតិបានដាក់ជនជាតិ ម៉ុងតាញ៉ា ១៨ នាក់ក្រោមកិច្ចការពារ* ។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៣ ឆ្នាំមេសា ឆ្នាំ២០០៧ និងការផ្សាយព័ត៌មានបន្តបន្ទាប់ទៀត ព្រមទាំងព័ត៌មានផ្ដល់ដោយអង្គការអាដហុក ខែកុម្ភៈ ឆ្នាំ២០០៨ ។

**ថ្ងៃទី២០ ខែមេសា**

- តាំងពីដំបូងលោកចៅក្រម អាន សំណាង បានបដិសេធមិនពិចារណាឱ្យពួកគេបាននៅក្រៅឃុំទេ ដោយគាត់និយាយថា លុះត្រាតែជនសង្ស័យទី៤ម្នាក់ទៀតសារភាពចំពោះមុខតុលាការ ទើបគាត់ដោះលែងបុរសទាំង ៣នាក់នេះឱ្យនៅក្រៅឃុំដែលទង្វើបែបនេះជាការប្រើប្រាស់បុរស ៣ នាក់នេះជាចំណាប់ខ្មាំងយ៉ាងមានប្រសិទ្ធិភាព។
- នៅថ្ងៃទី១៦ ខែកញ្ញា បុរសទាំង៣នាក់នោះ ត្រូវបានដោះលែងបន្ទាប់ពីត្រូវបានឃុំឃាំង អស់រយៈពេលជិត៩ខែក្នុងពន្ធនាគារខេត្តរតនគីរី ។
- ក្រោយមកបុរសពីរនាក់ទៀត ត្រូវបានធានាឱ្យនៅក្រៅឃុំ ប៉ុន្តែតុលាការនៅព្យួរបទចោទលើពួកគេ។

**ការបង្ក្រាបដោយប្រើអំពើហិង្សាលើព្រះសង្ឃតវ៉ាអំពីសិទ្ធិជនជាតិភាគតិចនៅភ្នំពេញ**[៧៥]

- ព្រះសង្ឃខ្មែរកម្ពុជាក្រោមមួយក្រុម ដែលមានគ្នាប្រមាណ ៥០ អង្គបានព្យាយាមយកលិខិតតវ៉ាមួយច្បាប់ដាក់ជូនស្ថានទូតវៀតណាម អំពីការប្រព្រឹត្តិរបស់អាជ្ញាធរវៀតណាមមកលើព្រះសង្ឃនៅកម្ពុជាក្រោម។ លិខិតនោះបានអំពាវនាវឱ្យអាជ្ញាធរវៀតណាមទទួលខុសត្រូវចំពោះការបាត់ខ្លួនព្រះសង្ឃ ៣ អង្គ ហើយអនុញ្ញាតឱ្យបំបួសអតីតសង្ឃ ៦ អង្គឡើងវិញ បន្ទាប់ពីត្រូវបានផ្សឹកកាលពីខែកុម្ភៈ ដោយត្រូវបានចោទប្រកាន់ថាបានចូលរួមក្នុងការធ្វើឱ្យមានការរំជើបរំជួលនយោបាយ។
- បន្ទាប់ពីត្រូវបានរារាំងដោយនគរបាលមិនឱ្យចូលទៅកាន់ស្ថានទូតវៀតណាម ព្រះសង្ឃទាំងនោះបាននិមន្តតាមផ្លូវក្នុងទីក្រុងភ្នំពេញរហូតដល់មានព្រះសង្ឃ និងមនុស្សមិនស្គាល់អត្តសញ្ញាណមួយក្រុមស្លៀកពាក់ស៊ីវិល ចេញពីវត្តឧណ្ណាលោមបានស្ទាក់ក្បួនដង្ហែរបស់ព្រះសង្ឃទាំងនោះ។ ពេលនោះ ជម្លោះមួយបានកើតឡើងបណ្តាលឱ្យព្រះសង្ឃមួយចំនួនរងរបួស។
- មានការសង្ស័យថា អាជ្ញាធរបានបញ្ជាឱ្យព្រះសង្ឃវត្តឧណ្ណាលោម និងជនស៊ីវិលដទៃទៀតមករារាំងក្បួនដង្ហែបាតុកម្មនោះ។
- មួយថ្ងៃក្រោយមកមានសេចក្តីរាយការណ៍មកថា ព្រះសង្ឃមួយអង្គដែលបានចូលរួមក្នុងបាតុកម្មនោះត្រូវបានមនុស្សមួយក្រុមមិនស្គាល់អត្តសញ្ញាណ វាយដំបណ្តាលឱ្យរងរបួសយ៉ាងធ្ងន់ធ្ងរ ខណៈដែលព្រះអង្គកំពុងនិមន្តត្រឡប់ទៅវត្តវិញ។

---

[៧៥] កាយ គឹមសុង: *ព្រះសង្ឃក្នុងស្រុក និងព្រះសង្ឃកម្ពុជាក្រោមបានវាយប្រហារគ្នា ក្នុងការនិមន្តតវ៉ា* ។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២១-២២ ខែមេសា ឆ្នាំ២០០៧។ អត្ថបទសរសេរដោយ យន់ សាមាន និង អេលីហ្សាបេត ថុមឺ: *គណបក្សប្រឆាំងទាមទារឱ្យមានការស៊ើបអង្កេតក្នុងករណីព្រះសង្ឃប្រយុទ្ធគ្នា*។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ ។

ដើមខែឧសភា

**មេធាវីត្រូវបានហាមមិនឱ្យចូលរួមវគ្គហ្វឹកហ្វឺកសិទ្ធិមនុស្ស**[៧៦]

- មេធាវីថ្មីចំនួន ១២ នាក់ បានចូលរួមក្នុងកម្មវិធីហ្វឹកហ្វឺនច្បាប់ដែលឧបត្ថម្ភដោយកម្មវិធីស្តីពីសិទ្ធិ និងយុត្តិធម៌របស់ទីភ្នាក់ងារអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ត្រូវបានបង្ខំឱ្យលាឈប់ពីកម្មវិធី ។
- កម្មវិធីនេះបានចាប់ផ្តើមកាលពីឆ្នាំ២០០៥ ដោយបញ្ជូនសិក្ខាកាមមេធាវីឱ្យធ្វើកម្មសិក្សានៅតាមអង្គការសិទ្ធិមនុស្ស និងអង្គការនានាសំរាប់រយៈពេល១ឆ្នាំ។ កម្មសិក្សានេះជាផ្នែកមួយនៃវគ្គហ្វឹកហ្វឺនដែលតម្រូវឱ្យធ្វើបែបនេះ ដើម្បីអាចចូលក្នុងគណៈមេធាវីបាន ហើយចំណុចនេះមានចែងនៅក្នុងមាត្រា៣៥ នៃច្បាប់ស្តីពីគណៈមេធាវី ។
- សិក្ខាកាមកាលពីឆ្នាំមុន បានបញ្ចប់កម្មសិក្សា និងបានចូលរួមជាមួយគណៈមេធាវី ដោយមិនមានបញ្ហាអ្វីឡើយ។
- ប៉ុន្តែ លោក គី តិច ប្រធានគណៈមេធាវីបានគំរាមមិនឱ្យសិក្ខាកាមមេធាវីចូលជាសមាជិកក្នុងគណៈមេធាវីទេ ក្នុងឆ្នាំ២០០៧ ប្រសិនបើសិក្ខាកាមណានៅតែបន្តចូលរួមក្នុងកម្មវិធីនេះ ហើយដូច្នេះ សិក្ខាកាមទាំងនោះត្រូវតែលាឈប់ពីកម្មវិធីទាំងអស់។ មេធាវីក៏ត្រូវបានបង្ខំឱ្យធ្វើកិច្ចសន្យាថា នៅពេលអនាគតនឹងមិនធ្វើការនៅក្នុងកម្មវិធី ឬ អង្គការមិនមែនរដ្ឋាភិបាលណាមួយឡើយ។

ថ្ងៃទី៩ ខែឧសភា

**តំណាងសហគមន៍ក្រុងកែប ៤ នាក់ ត្រូវបានចាប់ខ្លួន**[៧៧]

- បុរសបីនាក់ និងស្ត្រីម្នាក់ ដែលជាអ្នកតំណាងប្រជាពលរដ្ឋ ២៩ គ្រួសារ នៅក្នុងជម្លោះដីធ្លីដ៏យូរអង្វែងមួយ ជាមួយអ្នកជំនួញជាស្ត្រីម្នាក់នៅក្រុងនោះ ត្រូវបានចាប់ខ្លួនបន្ទាប់ពីបានឆ្លើយតបទៅនឹងការកោះហៅរបស់តុលាការខេត្តកំពត ដើម្បីសាកសួរចម្លើយ។
- ករណីដែលកើតឡើងចំពោះអ្នកតំណាងទាំងបួននាក់នោះ បានចាប់ផ្តើមតាំងពីខែកុម្ភៈ ឆ្នាំ២០០៤ នៅពេលដែលគ្រួសារទាំងនោះ ត្រូវបានបង្ខំឱ្យចាកចេញពីដីរបស់ខ្លួននៅក្នុងសង្កាត់ពងទឹក ខណ្ឌដំណាក់ចង្អើរ ដែលពួកគាត់បានធ្វើស្រែតាំងពីឆ្នាំ១៩៩៤មកម្ល៉េះ។ ផ្ទះសម្បែង និងដំណាំរបស់ប្រជាពលរដ្ឋទាំងនោះ ត្រូវបានឈូសឆាយ និង

---

[៧៦] *ការដាក់កំហិតលើវិជ្ជាជីវៈផ្នែកច្បាប់ដោយគណៈមេធាវីៈ ការគំរាមកំហែងមកលើសេរីភាព និងឯករាជ្យនៃជំនួយផ្នែកច្បាប់នៅកម្ពុជា* របាយការណ៍សង្ខេបរបស់លីកាដូ ខែធ្នូ ឆ្នាំ២០០៧ ។

[៧៧] *ការចាប់ខ្លួនមនុស្ស ៤ នាក់ ក្រោយពីបានបំភ្លឺនៅតុលាការ ដើម្បីជំទាស់ទៅនឹងការកាន់កាប់ដីរបស់ពួកគេដោយខុសច្បាប់នៅខេត្តកំពត* គណៈកម្មាធិការប្រព្រឹត្តិកម្មសិទ្ធិមនុស្សអាស៊ីចុះផ្សាយថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៧ ហើយព័ត៌មានថ្មីៈ http://www.ahrchk.net/ua/mainfile.php/2007/2389

ថ្ងៃទី៦ ខែឧសភា

បំផ្លាញចោលគ្មានសល់ក្នុងព្រឹត្តិការណ៍បណ្តេញនោះ ។

- នៅខែធ្នូ ឆ្នាំ២០០៦ អ្នកទាំង បួន នាក់ ត្រូវបានចោទប្រកាន់ពីបទរំលោភយកទ្រព្យសម្បត្តិអ្នកដទៃដោយប្រើអំពើហិង្សា ដោយផ្អែកលើបណ្តឹងរបស់អ្នកជំនួញជាស្ត្រីនោះ ទាក់ទងទៅនឹងការបណ្តេញប្រជាពលរដ្ឋកាលពីឆ្នាំ២០០៤។ អង្គការសិទ្ធិមនុស្សនានា បានបង្ហាញនូវការខ្វាយខ្វល់ថា ការចោទប្រកាន់នោះ គឺជាផ្នែកមួយនៃការបញ្ឈប់ពួកសកម្មជនទាំងនោះ កុំឱ្យបន្តទាមទារដីតទៅទៀត។
- បុរសពីរនាក់ក្នុងចំណោមអ្នកតំណាងទាំងបួននាក់នោះ ត្រូវបានដោះលែងនៅថ្ងៃទី២៥ ខែ ឧសភា ក្រោយពីផ្តិតមេដៃលើចម្លើយសារភាពដោយបង្ខិតបង្ខំ ដើម្បីឈប់ទាមទារកម្មសិទ្ធិលើដីទំនាស់នោះ ហើយត្រូវបង់ប្រាក់ពិន័យចំនួន ២ លានរៀន(៥០០ ដុល្លារ) ម្នាក់។ អ្នកតំណាងពីរនាក់ផ្សេងទៀត ត្រូវបានដោះលែងនៅថ្ងៃទី២៨ ខែមិថុនា បន្ទាប់ពីមានអន្តរាគមន៍ពីអង្គការសិទ្ធិមនុស្សមួយ និងបន្ទាប់ពីយល់ព្រមឈប់ទាមទារកម្មសិទ្ធិលើដីទំនាស់នោះទៀត។ ចាប់ពីពេលនោះមក មិនមានបញ្ហាអ្វីកើតឡើងចំពោះអ្នកតំណាងទាំងនោះទេ ហើយបើតាមការរាយការណ៍ ដីមានទំនាស់នោះ ត្រូវបានកាន់កាប់ដោយអ្នកជំនួញជាស្ត្រីនោះ។

**ការចាប់ខ្លួនតំណាងសហគមន៍ពីរនាក់នៅខេត្តព្រៃវែង**

- លោក ឌុល ឌិន និងលោក វង់ ប្រិល ជាតំណាងប្រជាពលរដ្ឋ៥០គ្រួសារដែលពាក់ព័ន្ធក្នុងជម្លោះដីធ្លីមួយកន្លែងក្នុងឃុំកោះសំពៅ ស្រុកពាមជរ ត្រូវបានចាប់ខ្លួន ក្រោមការចោទប្រកាន់ពីបទប្លន់ស្រូវ។
- នៅពេលកំពុងសរសេររបាយការណ៍នេះ លោក វង់ ប្រិលត្រូវបានធានាឱ្យនៅក្រៅឃុំ ចំណែក លោក ឌុល ឌិន នៅតែត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ទោះជាយ៉ាងណាក្តី ពុំមានកំណត់ពេលវេលាជាក់លាក់ដើម្បីបើកសវនាការ។
- មានអំពើរំលោភសិទ្ធិមនុស្សជាច្រើននៅក្នុងជម្លោះនោះ ត្រូវបានកត់ត្រាដូចជា ការសម្លាប់យុវជនម្នាក់ឈ្មោះ យ៉េង សុជាតិ អាយុ ១៧ ឆ្នាំ កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៦។ សុជាតិបានត្រូវគ្រាប់កាំភ្លើងស្លាប់ នៅពេលបុរស ២០ នាក់ ប្រដាប់ដោយអាវុធបានបើកការបាញ់ប្រហារទៅលើក្រុមប្រជាពលរដ្ឋដែលមានតែបាតដៃទទេ ក្នុងពេលពួកគាត់បានព្យាយាមទៅជួបលោកអភិបាលរងស្រុកឈ្មោះ អ៊ី សំអុល។ ពុំមានជនល្មើសណា ម្នាក់ត្រូវបានចាប់ខ្លួនទេក្នុងករណីឃាតកម្មនេះ។

**ថ្ងៃទី៦ ខែឧសភា**

**ការសង្ស័យបាត់ខ្លួនដោយបង្ខំអ្នកប្រឆាំងជនជាតិវៀតណាមម្នាក់ក្រោមកិច្ចការពាររបស់អង្គការសហប្រជាជាតិនៅភ្នំពេញ**[៧៨]

- លោក ឡេ ទ្រីទូ មេដឹកនាំសហជីពវៀតណាម និងជាអ្នកតស៊ូមតិដើម្បីសិទ្ធិមនុស្ស និងប្រជាធិបតេយ្យត្រូវបានឃើញមុខចុងក្រោយបំផុតនៅថ្ងៃទី៦ ខែឧសភា ពេលដែលគាត់កំពុងដើរទៅកាន់ហាងអ៊ីនធឺណេតមួយ ពីកន្លែងស្នាក់នៅបណ្តោះអាសន្នរបស់គាត់នៅទីក្រុងភ្នំពេញ ។
- អ្នកស្វែងរកសិទ្ធិជ្រកកោន ឈ្មោះ ឡេ ទ្រីទូ នេះបានចុះឈ្មោះ ព្រមទាំងបានដាក់កម្មវិធីសម្ភាសន៍កំណត់ស្ថានភាពជនភៀសខ្លួន ជាមួយអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនរួចរាល់អស់ហើយ ។
- មុនពេលភៀសខ្លួនមកកម្ពុជាក្នុងខែមេសា ឆ្នាំ២០០៧ លោក ទ្រីទូ ធ្លាប់ត្រូវបានឃុំខ្លួន ដោយអាជ្ញាធរវៀតណាមពីរដងរួចហើយ ព្រមទាំងស្ថិតក្រោមការឃ្លាំមើលរបស់នគរបាល និងការគាបសង្កត់ដើម្បីឱ្យគាត់បញ្ឈប់សកម្មភាពរបស់គាត់ ។
- ១០ថ្ងៃក្រោយពីការបាត់ខ្លួនគាត់ កាសែតវៀតណាមមួយចំនួនបានចុះផ្សាយព្រមៗគ្នានូវអត្ថបទចោទប្រកាន់គាត់ពីបទកាន់កាប់ទ្រព្យសម្បត្តិខុសច្បាប់តាមមាត្រា ១៣៩ នៃក្រមព្រហ្មទណ្ឌរបស់ប្រទេសវៀតណាម ។
- ចាប់តាំងពីខែឧសភា ឆ្នាំ២០០៧មក គេពុំបានដឹងថាលោក ទ្រីទូ នៅទីណាទេ ហើយអង្គការសិទ្ធិមនុស្សនានាជឿជាក់ថា គាត់ទំនងជាត្រូវគេចាប់បញ្ជូនទៅវៀតណាមវិញដោយបង្ខំ ហើយដាក់ពន្ធនាគារនៅទីនោះ ។ ករណីបែបនេះជារឿងធម្មតាទៅហើយសម្រាប់អ្នកស្វែងរកសិទ្ធិជ្រកកោននៅកម្ពុជា ដែលធ្លាប់បានបាត់ខ្លួនកន្លងមកដូចជាអ្នកប្រឆាំងវៀតណាម និងជាជនភៀសខ្លួនដែលត្រូវបានគេទទួលស្គាល់ម្នាក់ ឈ្មោះ ទ្រីច ទ្រីលុក ដែលត្រូវបានចាប់បញ្ជូនពីភ្នំពេញនៅឆ្នាំ២០០២ ហើយមិនដឹងថានៅទីណាទេ អស់រយៈពេលជាងមួយឆ្នាំ ទំរាំគ្រួសារគាត់បានដឹងថា គាត់កំពុងស្ថិតក្នុង

[៧៨] ស៊ូស៊ី ឃីម និង ពិន ស៊ីសុវណ្ណ : *អ្នកប្រឆាំងវៀតណាមបាត់ខ្លួននៅកម្ពុជា* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៧ និងអត្ថបទសរសេរដោយ ដែម វែល្ស : *ការស៊ើបអង្កេតរកអ្នកប្រឆាំងវៀតណាមដែលបានបាត់ខ្លួន* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១៩-២០ ខែឧសភា ឆ្នាំ២០០៧ ។ សូមអានអត្ថបទដែលមានចំណងជើងថា: *សម្លេងនៃការព្រួយបារម្ភណ៍អំពីការបាត់ខ្លួនលោក ឡេ ទ្រីទូ* គណៈកម្មាធិការសិទ្ធិមនុស្សនៅវៀតណាមថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០៨ ។

ថ្ងៃទី៧ ខែឧសភា

ពន្ធនាគារប្រទេសវៀតណាម ដើម្បីរង់ចាំតុលាការបើកសវនាការ។

- ថ្ងៃទី៣០ ខែមិថុនា ព្រះសង្ឃ និងជាសកម្មជនសិទ្ធិមនុស្សមួយអង្គព្រះនាម ទឹម សាខន បានបាត់ព្រះកាយពីវត្តមួយក្នុងខេត្តតាកែវ ក្រោយមកបានដឹងថា លោកត្រូវបានគេចាប់បញ្ជូនទៅប្រទេសវៀតណាមដោយខុសច្បាប់ ហើយដាក់ពន្ធនាគារនៅទីនោះ(សូមអានទំព័រ១៦)។

**អភិបាលក្រុងព្រះសីហនុចោទប្រកាន់បុគ្គលិកសិទ្ធិមនុស្សថាបានញុះញង់ឱ្យមានឧក្រិដ្ឋកម្ម**[៧៩]

- លោក សាយ ហាក់ អភិបាលក្រុងព្រះសីហនុ បានប្រកាសថាលោកបានបញ្ជូនភស្តុតាងទៅតុលាការក្រុងរួចហើយ ដើម្បីចោទប្រកាន់ លោក ឈឹម សាវុធ អ្នកសម្របសម្រួលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រចាំក្រុងព្រះសីហនុ ពីបទញុះញង់ប្រជាពលរដ្ឋ បង្កើតតំបន់ឯករាជ្យពីការគ្រប់គ្រងរបស់រដ្ឋាភិបាល។
- ការចោទប្រកាន់នេះពាក់ព័ន្ធជាមួយភូមិស្ពានឆេះ ខណ្ឌមិត្តភាពជាទីតាំងមួយ ដែលបានកើតមានអំពើហិង្សាយ៉ាងសាហាវ ក្នុងការបណ្តេញប្រជាពលរដ្ឋចេញពីភូមិ កាលពីថ្ងៃទី២០ ខែមេសា។ លោក សាវុធ បានពន្យល់ថាមុននឹងមានការបណ្តេញចេញ គាត់គ្រាន់តែ បានជួយប្រជាពលរដ្ឋក្នុងការរៀបចំសំណើទទួលស្គាល់សហគមន៍របស់គាត់ដោយស្របច្បាប់តែប៉ុណ្ណោះ។
- ពីរបីថ្ងៃក្រោយមក លោក សាវុធ បានចាកចេញពីតំបន់ក្រោយពីមានពាក្យចចាមអារាមផ្សព្វផ្សាយថា អាជ្ញាធរបម្រុងចាប់ខ្លួនគាត់។
- នៅចុងឆ្នាំនោះ លោក សាវុធ បានផ្លាស់មកធ្វើការនៅខេត្តតាកែវ ហើយគាត់ត្រូវបានអាជ្ញាធរចាប់ខ្លួនដោយខុសច្បាប់ពេលដែលគាត់កំពុងរៀបចំវេទិកាសាធារណៈមួយ(សូមអានទំព័រ ១០)។ នៅឆ្នាំ២០០៦ គាត់គឺជាបុគ្គលិកម្នាក់ដែលត្រូវបានគំរាមកំហែង និងឃុំខ្លួនក្នុងចំណោមបុគ្គលិកសិទ្ធិមនុស្ស ៤ នាក់ ពេលដែលពួកគាត់កំពុងឃ្លាំមើលជម្លោះដីធ្លីមួយនៅខេត្តកំពត[៨០]។

[៧៩] ពិន ស៊ីសុវណ្ណ ៖ *អភិបាលក្រុងព្រះសីហនុបាននិយាយថា មន្ត្រីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាញុះញង់ប្រជាពលរដ្ឋ* ។ កាសែត ឌឹ ខេមបូឌាដេលីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៧ និងអត្ថបទសរសេរដោយ ពិន ស៊ីសុវណ្ណ និង ជែម វែល្ស ៖ *បុគ្គលិកសិទ្ធិមនុស្សបានភៀសខ្លួន ដោយភ័យខ្លាចការចាប់ខ្លួន* កាសែត ឌឹ ខេមបូឌាដេលីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៧។

[៨០] *ការវាយប្រហារ និងការគំរាមកំហែងចំពោះអ្នកកាពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៦* របាយការណ៍លីកាដូ ខែធ្នូ ឆ្នាំ២០០៦ ទំព័រ ២៤ ។

**ថ្ងៃទី១៩ ខែឧសភា**

**កូដកររសាមគ្គីភាពប្រឈមអំពើហិង្សារបស់នគរបាល ហើយមេដឹកនាំសហជីពប្រឈមមុខនឹងការចោទប្រកាន់ពីបទញុះញង់នៅខេត្តកណ្តាល** [៨១]

- នគរបាលបានបោកគ្រាប់បែកផ្សែង ហើយកងសន្តិសុខបានបាញ់ឡើងលើជាច្រើនគ្រាប់ ដើម្បីបំបែកបាតុករកម្មកររោងចក្រកាត់ដេរ រីវើរីច (River Rich) ប្រមាណជាង ១.000 នាក់ ស្ថិតនៅក្នុងស្រុកស្អាង ខេត្តកណ្តាល។ កម្មករទាំងនោះបានទាមទារឱ្យផ្តល់ការងារដល់សហការីរបស់ពួកគេ ដែលត្រូវបានបណ្តេញចេញពីការងារកាលពីខែវិច្ឆិកាកន្លងទៅ ក្រោមការចោទប្រកាន់ពីបទបង្កើតសហជីព។
- ក្រោយពីកូដកម្មរួច រោងចក្រ រីវើរីច បានដាក់ពាក្យបណ្តឹងទៅតុលាការខេត្តកណ្តាល ប្តឹងមេដឹកនាំសហជីព ៣ នាក់ពីបទ "ញុះញង់"។
- កូដកម្មបានបន្តម្តងទៀតនៅថ្ងៃទី២១ ខែឧសភា ពេលនោះកម្មករប្រមាណ ១.000 នាក់បានហ៊ុំព័ទ្ធមេដឹកនាំសហជីព ដើម្បីរារាំងកុំឱ្យកម្លាំងនគរបាលប្រឆាំងកូដកម្មប្រមាណ១៥0 នាក់ "នាំខ្លួនយកទៅតុលាការដើម្បីសួរចម្លើយ"។
- នៅថ្ងៃទី៤ ខែមិថុនា ក្រុមហ៊ុនអះអាងថាមន្ត្រីសហជីពបានបំភិតបំភ័យកម្មករឱ្យចូលរួមធ្វើកូដកម្ម ហើយខាងសហជីពបានបដិសេធសេចក្តីថ្លែងការណ៍នោះចោល។
- ក្នុងខែកក្កដា ភាគីខាងរោងចក្របានយល់ព្រមដកពាក្យបណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងមេដឹកនាំសហជីពទាំងបី ដែលជាផ្នែកមួយនៃការចរចារ ដោយរួមបញ្ចូលទាំងការផ្តល់ការងារជូនកម្មករដែលបានបណ្តេញចេញនោះផងដែរ។

**ថ្ងៃទី២១ ខែឧសភា**

**អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សត្រូវបានហាមមិនឱ្យចូលពន្ធនាគារខេត្តពោធិ៍សាត់** [៨២]

- បុគ្គលិកផ្នែកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស និងក្រុមគ្រូពេទ្យរបស់អង្គការលីកាដូ និងអាដហុកត្រូវគេបញ្ជាក់ប្រាប់ថា តុលាការមិនអនុញ្ញាតឱ្យពួកគេចូលក្នុងពន្ធនាគារ ដើម្បីព្យាបាលអ្នកទោសទៀតទេ ។
- បទបញ្ជានេះចេញមកពីព្រះរាជអាជ្ញាអមតុលាការខេត្ត គឺលោក តុប ចាន់សេរីវុធ ហើយការបញ្ជានេះ គឺពាក់ព័ន្ធជាមួយនឹងការចាប់ខ្លួនបុរស៤នាក់ដែលត្រូវបានចោទប្រកាន់ពីបទបង្កើតកងកម្លាំងខុសច្បាប់។ អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស បាន

---

[៨១] *នគរបាលប្រឆាំងកុបកម្ម ប៉ះទង្គិចជាមួយកម្មកររោងចក្រ រីវើរីច ពេលធ្វើកូដកម្មនៅភ្នំពេញ*។ សេចក្តីថ្លែងព័ត៌មានរបស់លីកាដូ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២00៧។ សូមអានអត្ថបទសរសេរដោយ ប្រាក់ ចាន់ថុល ដែលមានចំណងជើងថា: *នគរបាលខេត្តកណ្តាលវាយបំបែកហ្វូងកម្មករដែលធ្វើកូដកម្ម*។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១៩-២0 ខែឧសភា ២00៧ និងការផ្សាយព័ត៌មានបន្តបន្ទាប់ទៀត។

[៨២] របាយការណ៏កម្មវិធីពន្ធនាគាររបស់លីកាដូ ដែលមិនផ្សព្វផ្សាយ។ សូមអានអត្ថបទសរសេរដោយ យន់ សាមាន ដែលមានចំណងជើងថា: *តុលាការហាមបុគ្គលិកសិទ្ធិមនុស្ស មិនឱ្យចូលក្នុងពន្ធនាគារ* ។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៣0 ខែឧសភា ឆ្នាំ២00៧ ។

ថ្ងៃទី៣ ខែមិថុនា

មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីទារុណកម្មដែលអាចកើតឡើង និងការបង្ខំបុរសទាំង ៤ នាក់ ឱ្យសារភាព ។

- លោក តុប ចាន់សេរីវុធ បានបដិសេធថាការហាមប្រាមនេះពុំមានពាក់ព័ន្ធជាមួយករណីណាមួយទេ ដោយបាននិយាយថាអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស "គ្មានសិទ្ធិ ឬ កាតព្វកិច្ចដើម្បីសម្ភាសន៍អ្នកទោសទេ" ហើយមន្ត្រីពន្ធនាគារមានទម្លាប់មិនល្អដែលចេះតែអនុញ្ញាតឱ្យអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សទាំងនោះ ចូលសម្ភាសន៍អ្នកទោសជារៀងរហូតមក ។

**រដ្ឋាភិបាលហាមប្រាមរបាយការណ៍ដែលរិះគន់របស់អង្គការមិនមែនរដ្ឋាភិបាល ហើយបញ្ជាឱ្យរឹបអូសរបាយការណ៍ទាំងអស់ដែលបានចែកផ្សាយ និងបង្ក្រាបការចែកចាយ**[៨៣]

- រដ្ឋមន្ត្រីព័ត៌មាន លោក ខៀវ កញ្ញារីទ្ធ ប្រកាសអំពីការរឹបអូសរបាយការណ៍ទាំងឡាយ ដែលមានចំណងជើងថា: *ខ្មែរស្រឡាយអ្នកលួចជាតិ: ការកាប់ឈើខុសច្បាប់ និងការពុះជ្រៀកទ្រព្យសម្បត្តិសាធារណៈដោយអ្នកដឹកនាំប្រទេសកម្ពុជា*។ របាយការណ៍នេះ ចេញផ្សាយដោយអង្គការគ្លូបប៊ លវិតណេស ។
- របាយការណ៍នេះ ផ្តោតទៅលើផលប៉ះពាល់នៃការរកស៊ីឈើខុសច្បាប់នៅកម្ពុជា ហើយបញ្ចេញឈ្មោះមន្ត្រីរដ្ឋាភិបាលបក្សពួក និងសមាជិកគ្រួសាររបស់ពួកគេ ក្នុងការសមគំនិត កាប់ឈើខុសច្បាប់ និងប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ ។
- អង្គការគ្លូបបូលវិតណេស គឺជាអង្គការអន្តរជាតិមួយ មានមូលដ្ឋាននៅទីក្រុងឡុងដ៍ នៃចក្រភពអង់គ្លេសដែលធ្វើការផ្តោតលើអំពើពុករលួយ និងការកេងប្រវ័ញ្ចធនធានធម្មជាតិ និងធ្វើយុទ្ធនាការដើម្បីបញ្ចប់និទ្ទណ្ឌភាព ជម្លោះពាក់ព័ន្ធជាមួយធនធានធម្មជាតិ និងការរំលោភលើសិទ្ធិមនុស្ស និងបរិស្ថាន ។ អង្គការនេះ ត្រូវបានតែងតាំងជាអ្នកឃ្លាំមើលមន្ត្រីរុក្ខាប្រមាញ់កម្ពុជានៅឆ្នាំ១៩៩៩ ហើយត្រូវបានបណ្តេញចេញពីកម្ពុជានៅឆ្នាំ២០០៣ ក្រោយពីបានរាយការណ៍ អំពីការជាប់ពាក់ព័ន្ធរបស់មន្ត្រីរាជរដ្ឋាភិបាលមួយចំនួននៅក្នុងបទឧក្រិដ្ឋព្រៃឈើ ។
- លើសពីការរឹបអូសរបាយការណ៍នេះ ប៉ុន្មានសប្តាហ៍ក្រោយមក គេបានឃើញមានការគំរាមយ៉ាងធ្ងន់ធ្ងរ មកលើបុគ្គលិកអង្គការ និងក្រុមហ៊ុននានា ដែលបានពាក់ព័ន្ធក្នុងការបកប្រែ និងចែកចាយរបាយការណ៍នេះ ។

---

[៨៣] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ ។ សូមអានអត្ថបទសរសេរដោយ យន់ សាមាន និង ខូក្លា ជីលសុន : *រដ្ឋាភិបាលបញ្ជាឱ្យរឹបអូសរបាយការណ៍របស់អង្គការ គ្លូបបូល វិតណេស* កាសែត ឌឺ ឃែមបូឌាដេលីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៧ និងការផ្សាយបន្តបន្ទាប់ទៀត ។

ថ្ងៃទី៨ ខែមិថុនា

**អភិបាលខេត្តបានគំរាមជាសាធារណៈ ដល់អាយុជីវិតបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល** [៨៤]

- លោក ហ៊ុន ណេង អភិបាលខេត្តកំពង់ចាម និងជាបងប្រុសបង្កើតរបស់សម្តេចនាយករដ្ឋមន្ត្រី បាននិយាយប្រាប់សារព័ត៌មានថា ប្រសិនបើពួកក្លូបបូលវិតណេសមកកម្ពុជា នោះគាត់នឹង "សំពងពួកគេឱ្យបែកក្បាល" ។
- របាយការណ៍ *ខ្សែស្រឡាយអ្នកលួចជាតិ* ដាក់បញ្ចូលនូវការចោទប្រកាន់អំពីសកម្មភាពឧក្រិដ្ឋនានា ដែលពាក់ព័ន្ធជាមួយប្រពន្ធលោក ហ៊ុន ណេង ឈ្មោះ អ្នកស្រី លាង វួចឈាង និងកូនប្រុស ឈ្មោះ ហ៊ុន តូ ។

ថ្ងៃទី៩ ខែមិថុនា

**ការឃុំឃាំងតំណាងសហគមន៍នៅបាត់ដំបងតាមអំពើចិត្ត** [៨៥]

- លោក ជឹម កែវ ត្រូវបានតុលាការខេត្តបាត់ដំបងលើកលែងការចោទប្រកាន់។ គាត់ជាអ្នកតំណាងរបស់ប្រជាពលរដ្ឋ ១៤ គ្រួសារ នៅភូមិកោះរាម ឃុំខ្នាចរមាស ស្រុកបវេល។ ប៉ុន្តែជនរងគ្រោះនេះ ត្រូវបានជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ ចាប់តាំងពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៦មក ហើយត្រូវបានបញ្ជូនទៅពន្ធនាគារវិញ ដោយរង់ចាំបណ្តឹងឧទ្ធរណ៍។
- លោក ជឹម កែវ ត្រូវបានចោទពីបទរំលោភលើទ្រព្យសម្បត្តិឯកជនក្នុងជម្លោះដីធ្លីមួយដ៏យូរអង្វែងជាមួយពាណិជ្ជករម្នាក់ឈ្មោះ អៀង អឿន ដែលត្រូវជាប្អូនថ្លៃរបស់លោកឆាយ សារ៉េត អភិបាលខេត្តពោធិ៍សាត់។
- ក្រុមការងារពិសេសមកពីក្រសួងយុត្តិធម៌ ដែលស៊ើបអង្កេតក្នុងជម្លោះនេះកាលពីខែធ្នូ ឆ្នាំ២០០៦ បានធ្វើសេចក្តីសន្និដ្ឋានថា លោក ជឹម កែវ ត្រូវបានឃុំឃាំងដោយខុសច្បាប់ ហើយត្រូវដោះលែងគាត់ឱ្យនៅក្រៅឃុំជាបន្ទាន់។
- ថ្ងៃទី៤ ខែតុលា ក្រោយពីមានអន្តរាគមន៍ពីសំណាក់អង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិជាច្រើន លោក ជឹម កែវ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ។ ប៉ុន្តែ បណ្តឹងឧទ្ធរណ៍ជំទាស់លើករណីរបស់គាត់ នៅតែកំពុងបន្តដំណើរការនៅឡើយ ។

---

៨៤ យន់ សាមាន និង ខូភ្លា ជីលសុនៈ *ការហាមឃាត់មិនឱ្យផ្សព្វផ្សាយរបាយការណ៍បង្ហូចកិត្តិយសរបស់អង្គការ ក្លូបបូល វិតណេស ផ្តើមការស៊ើបអង្កេត។* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៧ ។

៨៥ របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ ។

ថ្ងៃទី ខែមិថុនា

- ប្រជាពលរដ្ឋពីរនាក់មានភាពច្របូកច្របល់នៅក្នុងជម្លោះមួយ ។ បុរសម្នាក់ឈ្មោះ ទិត ប៊ុនឈឿន និងម្នាក់ទៀតឈ្មោះ ហឿង ជា។ បុរសទាំងពីរនាក់នេះត្រូវបានចាប់ខ្លួននៅចុងខែមិថុនា ដោយគាត់បានភ្ជួររាស់ស្រែលើដីមានទំនាស់ ហើយត្រូវឃុំឃាំងបណ្ដោះអាសន្នរង់ចាំសវនាការអស់រយៈពេល៣ខែមុននឹងត្រូវបានដោះលែង ហើយការចោទប្រកាន់មកលើពួកគាត់នៅតែបន្តនៅឡើយ ។

**រដ្ឋាភិបាល និងមេដឹកនាំសាសនាបានហាមព្រះសង្ឃមិនឱ្យធ្វើបាតុកម្ម** [៨៦]

- រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា លោក ឃុន ហាំង និងសម្ដេចព្រះពោធិវង្ស នួន ង៉ែត បានចេញនូវសេចក្ដីណែនាំរួមមួយ ហាមប្រាមព្រះសង្ឃព្រះពុទ្ធសាសនាទាំងឡាយមិនឱ្យចូលរួមក្នុងបាតុកម្មអហិង្សា ។
- សម្ដេចព្រះពោធិវង្ស នួន ង៉ែត មានសង្ឃដីកាថា សេចក្ដីណែនាំនេះមានគោលបំណងទប់ស្កាត់ " ភាពចលាចល " ហើយអះអាងថា ព្រះសង្ឃដែលធ្វើបាតុកម្មនោះ "ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដោយអង្គឯង" ។
- បទបញ្ជានេះ ទំនងជាការប្រតិកម្មចំពោះការរីករាលដាលនៃការតវ៉ារបស់ខ្មែរកម្ពុជាក្រោមនៅភ្នំពេញ ប្រឆាំងនឹងការធ្វើបាបបងប្អូនរបស់ពួកគេនៅប្រទេសវៀតណាម ។
- លោក ហេង សំរិន ប្រធានរដ្ឋសភាជាតិ និងជាប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា ការប្រកាសនោះ គឺជាកិច្ចខិតខំប្រឹងប្រែងមួយ "ដើម្បីរក្សានូវស្ថេរភាពសង្គម" ។
- លោក សឺន សូប៊ែរ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញបានមានប្រសាសន៍ថា ការហាមឃាត់នេះ គឺជាការរំលោភលើរដ្ឋធម្មនុញ្ញ ។

---

[៨៦] សាម រិទ្ធ និង ឆាល ម៉ាក់ឌឺមីដ : *ការហាមព្រះសង្ឃមិនឱ្យធ្វើបាតុកម្ម ត្រូវបានគេហៅថា ពុំមែនអ្នកកាន់ព្រះពុទ្ធសាសនាទេ* កាសែត ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៩ ខែមិថុនា ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ ។ សូមមើលផងដែរ ឆាយ ច័ន្ទនីដា : *ក្រសួង និងសម្ដេចសង្ឃអំពាវនាវមិនឱ្យព្រះសង្ឃធ្វើបាតុកម្ម* កាសែត ឌឺ ឃែមបូឌាដេលីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧។

**ថ្ងៃទី១០ ខែមិថុនា**

**អ្នកសារព័ត៌មានម្នាក់ត្រូវបានបណ្តេញចេញពីការងារ បន្ទាប់ពីបានចុះផ្សាយរបាយការណ៍អង្គការមួយដែលបណ្តាលឱ្យមានការបិទក្រុមហ៊ុនកាសែតនោះ**[៨៧]

- អ្នកសារព័ត៌មានជាតិបារាំងម្នាក់ឈ្មោះ សូវែន សេឡូ ត្រូវបានបណ្តេញពីការងារ ជាអ្នកយកព័ត៌មានឱ្យកាសែតកាំបូដស័រ ។ ពុំមានការបញ្ជាក់មូលហេតុឱ្យច្បាស់លាស់ចំពោះការបណ្តេញនោះទេ ហើយការបណ្តេញនេះកើតឡើង បន្ទាប់ពីលោកសេឡូបានសរសេរអត្ថបទជាច្រើនអំពីរបាយការណ៍មួយ ដែលមានចំណងជើងថា "ខ្សែស្រឡាយអ្នកលួចជាតិ" ដែលជារបាយការណ៍របស់អង្គការគ្លូបបល វិតណេស ។ ជាពិសេសអត្ថបទដំបូងរបស់លោកសេឡូ ដែលបានចេញផ្សាយកាលពីថ្ងៃទី០១ ខែមិថុនា បានអធិប្បាយរបាយការណ៍នោះយ៉ាងលំអិត ដោយរួមទាំងការចោទប្រកាន់នានា ចំពោះការជាប់ពាក់ព័ន្ធរបស់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលជាច្រើន ។
- ចំណែកឯបុគ្គលិកផ្សេងទៀត ដែលបំរើការងារឱ្យកាសែតនោះ បាននាំគ្នាធ្វើកូដកម្មភ្លាមៗ ដើម្បីគាំទ្រលោកសេឡូ ហើយបានថ្កោលទោសចំពោះការបណ្តេញចេញនោះថាខុសច្បាប់ ហើយហេតុផលនៃការបណ្តេញចេញ មិនច្បាស់លាស់ និងគ្មានយុត្តិធម៌ ។
- ការចរចារដើម្បីបញ្ចប់ការធ្វើកូដកម្ម នៅក្នុងការិយាល័យកាសែតដែលចេញផ្សាយប្រចាំថ្ងៃជាភាសារបារាំងនោះ មិនបានជោគជ័យទេ ហើយនៅថ្ងៃទី១៣ ខែមិថុនា ក្រុមហ៊ុនធំដែលជាម្ចាស់ក្រុមហ៊ុនកាសែតនេះ បានប្រាប់បុគ្គលិកថា កាសែតនេះត្រូវបិទឈប់ដំណើរការ ដោយសារបញ្ហាក្ស័យធន ។
- លោក ភីលីព ម៉ូនីន នាយកក្រុមហ៊ុនធំដែលជាម្ចាស់ក្រុមហ៊ុនកាសែតនេះ និយាយថាបុគ្គលិកដែលតវ៉ា "មានទស្សនៈផ្សេង ចំពោះការអភិវឌ្ឍន៏របស់ប្រទេស" ។ អ្នកយកព័ត៌មានគ្មានព្រំដែនបានកត់សម្គាល់ឃើញថា លោក ម៉ូនីន ជាបុគ្គលម្នាក់ ដែលត្រូវបានជួលដោយទីភ្នាក់ងារអភិវឌ្ឍន៏បារាំងដើម្បីធ្វើជាទីប្រឹក្សាឱ្យក្រសួងកសិកម្ម ហើយបានអះអាងថា គាត់បានប្រាប់លោកសេឡូថា អត្ថបទរបស់គាត់ធ្វើឱ្យ "អាជ្ញាធរអាក់អន់ចិត្តយ៉ាងខ្លាំង" ។ លោក ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម គឺជាមន្ត្រីរដ្ឋាភិបាលមួយរូប ដែលត្រូវបានចោទប្រកាន់នៅក្នុងរបាយការណ៍ "ខ្សែស្រឡាយ អ្នកលួចជាតិចំពោះការប្រព្រឹត្តអំពើពុករលួយ និងការជាប់ពាក់ព័ន្ធនឹងកាប់ឈើខុសច្បាប់ ។

---

[៨៧] ខ្លូក្លា ជីលសុន : *កម្ពុជាបានបាត់សម្លេងសារព័ត៌មានដ៏សំខាន់មួយ*-ឆ្នាំអាស៊ីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧ ។ សូមអានអត្ថបទរបស់អ្នកយកព័ត៌មានគ្មានព្រំដែនដែលមានចំណងជើងថា: *អង្គការនិយាយភាសាបារាំងស្នើឱ្យជួយសង្គ្រោះកាសែតប្រចាំថ្ងៃជាភាសាបារាំង ដែលប្រឈមនឹងការរំសាយចោល* ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៧ ។

ថ្ងៃទី១៦ ខែមិថុនា

- បន្ទាប់ពីការបិទឈប់ដំណើរការជាច្រើនខែមក ការសែតនេះបានចាប់ដំណើរឡើងវិញ ដោយថ្នាក់គ្រប់គ្រងរបស់ខ្លួន ដោយការមានព័ត៌មានចុះផ្សាយបរិយាយមានលក្ខណៈទន់ភ្លន់ជាងមុនគួរឱ្យគត់សំគាល់ ចំពោះរដ្ឋាភិបាល។

**អ្នកសារព័ត៌មានម្នាក់រងការគំរាមកំហែងសម្លាប់ បន្ទាប់បានធ្វើការស៊ើបអង្កេតបទឧក្រិដ្ឋព្រៃឈើ**[៨៨]

- លោក ឡឹម ពិសិដ្ឋ អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី បានទទួលការហៅទូរស័ព្ទពីមន្ត្រីរដ្ឋាភិបាលម្នាក់ដែលមិនបង្ហាញឈ្មោះ ដោយបានប្រាប់គាត់ឱ្យ "*ប្រយ័ត្ន*" *ហើយថាគាត់អាចត្រូវគេសម្លាប់ ដោយសារការ*ធ្វើសេចក្តីរាយការណ៍ស្តីអំពីការកាប់ឈើខុសច្បាប់។
- លោក ពិសិដ្ឋ ទើបតែត្រឡប់មកពីតំបន់ព្រៃឡង ក្នុងខេត្តកំពង់ធំ ជាកន្លែងដែលគាត់បានទៅស៊ើបអង្កេតអំពីការចោទប្រកាន់ថាមានមន្ត្រីរដ្ឋាភិបាល ជាប់ពាក់ព័ន្ធក្នុងរឿងកាប់ឈើខុសច្បាប់ ដែលត្រូវបានសរសេរនៅក្នុងរបាយការណ៍ " ខ្សែស្រឡាយ អ្នកលួចជាតិ "របស់អង្គការក្លូបបូលវិតណេស ដែលត្រូវបានគេហាមឃាត់មិនឱ្យផ្សព្វផ្សាយ (សូមមើលទំព័រ ៥៤)។
- លោក ពិសិដ្ឋ បានអះអាងផងដែរថា លោកត្រូវបានមនុស្សស្លៀកពាក់ស៊ីវិលតាមដានទាំងនៅកំពង់ធំ និងពេលគាត់ត្រលប់មកភ្នំពេញវិញ។ គាត់គិតថាជននោះ គឺជាកងរាជអាវុធហត្ថ ។
- លោក ពិសិដ្ឋ បានរត់ទៅលាក់ខ្លួន ដែលតាមការរាយការណ៍ថា ទៅប្រទេសថៃ។ គាត់បានត្រឡប់មកកម្ពុជាវិញនៅចុងឆ្នាំនោះ។

**សកម្មជនសិទ្ធិមនុស្សបរទេសត្រូវបានឃុំខ្លួន ដោយសារបានចូលរួមក្នុងបាតុកម្មអហិង្សានៅភ្នំពេញ**[៨៩]

- សកម្មជនសិទ្ធិមនុស្ស ៨ នាក់ ដែលមកពីបស្ចឹមប្រទេសត្រូវបាននគរបាលអន្តោប្រវេសន៍ ឃុំខ្លួនអស់រយៈពេលជាង ៩ ម៉ោង ក្រោយពីបានធ្វើការតវ៉ាអំពីបញ្ហាសិទ្ធិមនុស្ស នៅខាងក្រៅកិច្ចប្រជុំរបស់សហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិ ក្នុងភ្នំពេញ ។

[៨៨] កម្ពុជា: *អ្នកសារព័ត៌មានចាកចេញពីប្រទេស បន្ទាប់ពីទទួលការគំរាមកំហែងសម្លាប់* គណៈកម្មការការពារអ្នកសារព័ត៌មានថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧។

[៨៩] ដែម វៃល្ស និង យន់ សាមាន: *ជនបរទេសត្រូវបានឃុំខ្លួន ដោយសារធ្វើការតវ៉ានៅខាងក្រៅកន្លែងប្រជុំរបស់ប្រទេសអ្នកផ្តល់ជំនួយ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៧ និង*អង្គការលើកលែងទោសអន្តរជាតិចោទសួរអំពីការឃុំខ្លួនជនបរទេសនេះ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៧។

**ថ្ងៃទី១៨ ខែមិថុនា**

- សកម្មជនទាំងនោះ មកពីប្រទេសកាណាដា ដាណឺមាក ញូស៊ីឡែន ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក បានធ្វើការតវ៉ាប្រឆាំងនឹងការបន្តឃុំឃាំងលោក ប៊ន សំណាង និងសុខ សំអឿន ជាបុរសពីរនាក់ដែលគេកាត់ទោសដោយបំពានថា បានសម្លាប់លោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ។
- នគរបាលបានឃាត់រថយន្តពីរគ្រឿង ដែលសកម្មជនបានបើកកាត់មុខអាគារក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានៅជិតវត្តភ្នំ ជាទីកន្លែងដែលវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាត្រូវបានគេរៀបចំឡើង ។
- ជនរងគ្រោះទាំងនោះ ត្រូវបានដោះលែង បន្ទាប់ពីបានយល់ព្រមចុះហត្ថលេខាលើឯកសារមួយ ទទួលស្គាល់ថាការចូលរួមរបស់ពួកគេនៅក្នុងការធ្វើបាតុកម្មនោះ បើទោះជា ពួកគេបដិសេធថា ពួកគេមិនបានរំលោភច្បាប់ណាមួយក៏ដោយ ។

**ថ្ងៃទី១៨ ខែមិថុនា**

**មេធាវីសិទ្ធិមនុស្សត្រូវបានបំភិតបំភ័យក្នុងជម្លោះដីធ្លីនៅរតនគិរី** [៩០]

- មេធាវី ៧ នាក់ មកពីមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ និង ៣ នាក់ មកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ត្រូវប្រឈមមុខនឹងបណ្តឹងរបស់លោកជំទាវស្រ្តី គាត កុល្យាណី ដែលត្រូវជាប្អូនស្រីរបស់លោករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គាត ឈន់ និងជាប្រពន្ធលោករដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆាន់ សាផាន់ ប្តឹងទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។
- មេធាវីទាំង ១០ នាក់នោះ ការពារក្តីឱ្យតំណាងជនជាតិភាគតិចចារ៉ាយចំនួន ១២ នាក់ នៅភូមិគងយុ និងគងធំ ស្រុកអូរយ៉ាដាវ ដែលបានដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី និង ព្រហ្មទណ្ឌប្តឹងអ្នកស្រី គាត កុល្យាណី ដែលតាមការចោទប្រកាន់ថា បានរំលោភយកដីសម្ងហភាពរបស់ពួកគាត់ ទំហំ ៤៥០ ហិកតា ។
- ពាក្យបណ្តឹងរបស់អ្នកស្រី គាត កុល្យាណី បានចោទប្រកាន់មេធាវីទាំងនោះថា "បានបញ្ចុះបញ្ចូល ញុះញង់ និងផ្តល់ថវិកាខ្លះៗ ដល់អ្នកភូមិជនជាតិចារ៉ាយ " ទាំងនោះ ដើម្បីឱ្យប្តឹងអ្នកស្រី ហើយអ្នកស្រីបានពិពណ៌នាសកម្មភាពនានារបស់មេធាវីថា ជា"រឿងនយោបាយ " ហើយស្នើឱ្យគណៈមេធាវី ចាត់វិធានការផ្នែកច្បាប់ ដើម្បីស៊ើបអង្កេតករណីនោះ" ។

---

[៩០] ប្រាក់ ចាន់ថុល និង អេរិកា គីនេត: *លោកជំទាវ គាត កុល្យាណី ប្តឹងមេធាវី ១០ នាក់* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ២០០៧ ។ ការហាមឃាត់មិនឱ្យផ្សព្វផ្សាយ សូមអានករណីសិក្សា: *ជម្លោះដីធ្លីនៅភូមិគងយុ* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ ។

ថ្ងៃទី២១ ខែមិថុនា

- បណ្តឹងនោះត្រូវបានចោទថា ជាការប៉ុនប៉ងដើម្បីបំភិតបំភ័យមេធាវីឱ្យបោះបង់ចោលករណីនោះ និងបំភិតបំភ័យអ្នកភូមិជនជាតិចារ៉ាយទាំងនោះឱ្យឈប់ប្តឹងតទៅទៀត ហើយបោះបង់ដីនោះចោល។ ពីរថ្ងៃក្រោយមកអ្នកស្រី គាត កុល្យាណី ក៏បានប្តឹងអ្នកភូមិពីបទព្រហ្មទណ្ឌផងដែរ (សូមអានទំព័រខាងក្រោម) ដែលនៅក្នុងពាក្យបណ្តឹងនោះ ក៏មានការចោទប្រកាន់មេធាវីទាំងនោះផងដែរ។
- នៅចុងឆ្នាំ២០០៧ មេធាវីពីរក្នុងចំណោមមេធាវីទាំងអស់ដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងនោះ បានឈប់ការពារក្តីឱ្យជនជាតិចារ៉ាយ។ ចំណែកឯការស៊ើបអង្កេតរបស់គណៈមេធាវីក្នុងរឿងរបស់មេធាវីទាំងនោះ កំពុងបន្តនៅឡើយ។

**បណ្តឹងព្រហ្មទណ្ឌ ប្តឹងតំណាងសហគមន៍ជនជាតិដើមក្នុងរឿងជម្លោះដីធ្លីនៅរតនគីរី**[៩១]

- តំណាងជនជាតិភាគតិចចារ៉ាយចំនួន ១២ នាក់នៅភូមិគងយុ និងគងធំ ស្រុកអូរយ៉ាដាវ ប្រឈមមុខនឹងបណ្តឹងព្រហ្មទណ្ឌ ប្តឹងដោយអ្នកស្រី គាត កុល្យាណី ដែលជាប្អូនរបស់លោករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គាត ឈន់ និងជាប្រពន្ធលោករដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆាន់ សាផាន់ ដែលដាក់ទៅតុលាការខេត្តរតនគីរី។
- ក្នុងខែមករា ឆ្នាំ២០០៧ អ្នកតំណាងជនជាតិភាគតិច បានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌប្តឹងអ្នកស្រី គាត កុល្យាណី និងមនុស្ស ៧ នាក់ផ្សេងទៀត ដោយចោទប្រកាន់ថាបានរំលោភយកដីសហមូភាពរបស់ពួកគាត់ទំហំ ៤៥០ ហិចតា ។ ពួកគាត់ក៏បានដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមទារដីរបស់ពួកគេវិញផងដែរ។
- អ្នកស្រី គាត កុល្យាណី បានចោទប្រកាន់ប្រជាពលរដ្ឋទាំងនោះថា បានក្លែងបន្លំញុះញង់ បរិហារកេរ្តិ៍ និងផ្សំគំនិត ដោយអះអាងថា អ្នកស្រីបានទិញដីនោះស្របច្បាប់ ហើយដូច្នេះបណ្តឹងចោទប្រកាន់គាត់ពីបទឆបោក និងបំភិតបំភ័យ គឺមិនត្រឹមត្រូវនោះទេ។ ការលក់ដីសមូហភាពរបស់ជនជាតិដើម ត្រូវបានហាមឃាត់ដោយច្បាប់ភូមិបាលឆ្នាំ២០០១ ។

[៩១] ប្រាក់ ចាន់ថុល និង អេរីកា គីណេត : *លោកជំទាវ គាត កុល្យាណី បានដាក់ពាក្យបណ្តឹងទាក់ទងនឹងរឿងជម្លោះដីធ្លី* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ២០០៧។ សម្រាប់ព័ត៌មានបន្ថែម សូមអានករណីសិក្សា: *ជម្លោះដីធ្លីនៅភូមិគងយុ* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ។

**ថ្ងៃទី២៤ ខែមិថុនា**

- ពាក្យបណ្តឹងនោះក៏បានធ្វើការចោទប្រកាន់មកលើមេធាវីអង្គការ ១០នាក់ ដែលការពារក្តីឱ្យប្រជាពលរដ្ឋ ដែលកាលពី២ថ្ងៃមុនបានប្រឈមនឹងបណ្តឹងរបស់អ្នកស្រី គាត កុល្យាណី ប្តឹងទៅគណៈមេធាវីម្តងរួចហើយ (សូមមើលផ្នែកខាងលើ)។ ពាក្យបណ្តឹងថ្មីនេះ បានបញ្ឈប់ការរៀបរាប់ឈ្មោះមេធាវីថាជាភាគីនៃបណ្តឹងព្រហ្មទណ្ឌ ប៉ុន្តែទុកឱកាសឱ្យព្រះរាជអាជ្ញាខេត្តធ្វើការស៊ើបអង្កេត និងចោទប្រកាន់ទៅលើមេធាវីទាំងនោះវិញ។
- មកដល់ចុងឆ្នាំ ២០០៧ ករណីនេះ កំពុងដំណើរការមិនទាន់ចប់នៅឡើយទេ។

**មេធាវីសិទ្ធិមនុស្សត្រូវបានគណៈមេធាវីគំរាម**[៩២]

- លោក លី តាយសេង អគ្គលេខាធិការនៃគណៈមេធាវី បានលើកឡើងជាសាធារណថាអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយត្រូវតែចុះហត្ថលេខាលើកិច្ចព្រមព្រៀងពិសេសមួយ ជាមួយគណៈមេធាវី ដើម្បីអាចជ្រើសរើសបុគ្គលិកជាមេធាវីឱ្យចូលបម្រើការងារក្នុងអង្គការរបស់ខ្លួនបានដោយស្របច្បាប់ ហើយថាមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ ប្រព្រឹត្តទៅដោយរំលោភទៅលើ "*ច្បាប់ស្តីពីគណៈមេធាវី*" ដោយមជ្ឈមណ្ឌលនេះ ពុំមានកិច្ចសន្យាបែបនេះទេ។
- ការអះអាងដែលគ្មានមូលដ្ឋាននៅក្នុងច្បាប់កម្ពុជាណាមួយទាល់តែសោះនោះ បានកើតឡើងប៉ុន្មានថ្ងៃ បន្ទាប់ពីអ្នកស្រី គាត កុល្យាណី ដែលជាប្អូនស្រីលោករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គាត ឈន់ និងជាប្រពន្ធលោករដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆាន់ សាផាន់ ដាក់ពាក្យបណ្តឹងទៅគណៈមេធាវី ប្តឹងមេធាវី ១០នាក់ មកពីមជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍ និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ដែលបានការពារក្តីឱ្យជនជាតិភាគតិចចារ៉ាយ ទាក់ទងនឹងរឿងជម្លោះដីធ្លីជាមួយអ្នកស្រីនោះ។

[៩២] អេរិកា គីណេត និង យន់ សាមាន: *គណៈមេធាវីសួរអំពីសិទ្ធិផ្លូវច្បាប់របស់ក្រុមមេធាវីជំនួយច្បាប់*។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧ ។ សម្រាប់ព័ត៌មានបន្ថែម សូមអានរបាយការណ៏សង្ខេបរបស់លីកាដូ *ការដាក់កំហិតដល់វិជ្ជាជីវៈផ្នែកច្បាប់ ដោយគណៈមេធាវី: ការគំរាមដល់សេរីភាព និងឯករាជ្យភាពរបស់ជំនួយផ្នែកច្បាប់នៅកម្ពុជា* ខែធ្នូ ឆ្នាំ២០០៧ និងករណីសិក្សា: *ជម្លោះដីធ្លីនៅភូមិគងយុ* ក្នុងភាគទី៣ នៃរបាយការណ៏នេះ។

**ថ្ងៃទី៣០ ខែមិថុនា**

- លោក លី តាយសេង បានអះអាងបន្ថែមទៀតថា អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា និងអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ដែលជាអង្គការផ្តល់សេវាកម្មផ្នែកច្បាប់ធំជាងគេនៅក្នុងប្រទេសកម្ពុជា ក៏អាចរំលោភច្បាប់ផងដែរ។
- យុទ្ធសាស្ត្រក្នុងការបំភិតបំភ័យរបស់គណៈមេធាវី បានធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងមកលើមេធាវីការពារសិទ្ធិមនុស្ស ដែលមេធាវីខ្លះបានសំរេចចិត្តចាកចេញពីអង្គការមិនមែនរដ្ឋាភិបាល ហើយធ្វើការជាលក្ខណៈឯកជនវិញ។

**ការបាត់ខ្លួនព្រះសង្ឃមួយអង្គដោយបង្ខំនៅខេត្តតាកែវ ដោយសារការតស៊ូមតិដើម្បីសិទ្ធិខ្មែរកម្ពុជាក្រោម**[៩៣]

- ព្រះសង្ឃព្រះពុទ្ធសាសនា ព្រះនាម ទឹម សាខន ជាសកម្មជនដឹកនាំការទាមទារសិទ្ធិសម្រាប់ខ្មែរកម្ពុជាក្រោម ត្រូវបានចាប់ពង្រត់ចេញពីវត្តភ្នំដិន ក្នុងស្រុកគីរីវង្ស ខេត្តតាកែវ ហើយត្រូវបានបញ្ជូនទៅឃុំឃាំងនៅក្នុងពន្ធនាគារប្រទេសវៀតណាម។
- មុននេះបន្តិចក្នុងថ្ងៃតែមួយ ព្រះសង្ឃ ទឹម សាខន ត្រូវបានគេផ្សឹក តាមបញ្ជារបស់ព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស ដែលបានមានសង្ឃដីកាថា ព្រះសង្ឃ ទឹម សាខន បាន"រំលោភវិន័យរបស់ព្រះពុទ្ធសាសនា និងបានបណ្តាលឱ្យមានការបែកបាក់សាមគ្គីភាពជាតិ និងអន្តរជាតិ ពិសេសរវាងប្រទេសទាំងពីរ កម្ពុជានិងវៀតណាម"។
- ប្រជាពលរដ្ឋជាច្រើនបានរាយការណ៍ថា បានឃើញមន្ត្រីសន្តិសុខកម្ពុជា ដឹកព្រះសង្ឃ ទឹម សាខន តាមរថយន្តមួយគ្រឿង។ ទោះបីជាគ្មានរបាយការណ៍ណាអាចបញ្ជាក់ឱ្យបានច្បាស់ថា ព្រះសង្ឃ ទឹម សាខន ត្រូវបានឃុំឃាំងនៅក្នុងជំរុំយោធានៅវៀតណាមក៏ដោយ ក៏គ្មាននរណាម្នាក់អាចដឹងថា ព្រះអង្គនៅទីណាឡើយ រហូតដល់ថ្ងៃទី០២ ខែសីហា ទើបស្ថានទូតវៀតណាមប្រចាំនៅកម្ពុជាបានប្រកាសថា ព្រះសង្ឃ ទឹម សាខន កំពុងស្ថិតនៅក្រោមការឃុំឃាំង "រង់ចាំការផ្តន្ទាទោសតាមច្បាប់ស្តីពីការបំផ្លិចបំផ្លាញសាមគ្គីភាពនយោបាយ"។

[៩៣] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ។ សម្រាប់ព័ត៌មានបន្ថែម សូមអានអត្ថបទដែលសរសេរដោយ យន់ សាមាន ដែលមានចំណងជើងថា: *ព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស បានបញ្ជាឱ្យផ្សឹកព្រះសង្ឃខ្មែរកម្ពុជាក្រោម* ។ កាសែត ឌឺ ឃែមបូឌាដេលីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧។ ឡាក់ឆ្លាន ហ្វូស៊ី និង វង្ស សុខខេង : *ការចាប់ពង្រត់ព្រះសង្ឃបានបណ្តាលឱ្យមានភាពតានតឹងនៅខេត្តតាកែវ*។ កាសែត ភ្នំពេញប៉ុស្តិ៍ថ្ងៃទី១០-២៣ ខែសីហា ឆ្នាំ២០០៧ និងការផ្សាយបន្តបន្ទាប់- សូមអាន: *សកម្មជនព្រះសង្ឃខ្មែរកម្ពុជាក្រោម* នៅក្នុងផ្នែកទី ៣ នៃរបាយការណ៍នេះ។

**ថ្ងៃទី៩ ខែកក្កដា**

- ក្រោយមកមន្ត្រីរដ្ឋាភិបាលកម្ពុជាបានអះអាងថា ព្រះសង្ឃ ទីម សាខន បានស្នើឱ្យគេបញ្ជូនព្រះអង្គទៅប្រទេសវៀតណាម ចំណែកឯប្រព័ន្ធផ្សាយព័ត៌មានវៀតណាមផ្សាយថា ព្រះសង្ឃ ទីម សាខន ត្រូវបានចាប់ខ្លួន នៅពេលដែលព្រះអង្គព្យាយាមចូលប្រទេសវៀតណាមដោយខុសច្បាប់ ។
- នៅថ្ងៃទី៨ ខែវិច្ឆិកា ព្រះសង្ឃ ទីម សាខន ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ និងព្យួរទោសរយៈ ១៤ ឆ្នាំ ដោយតុលាការខេត្តអាងយ៉ាង ប្រទេសវៀតណាម ។
- ការបាត់ខ្លួនដោយបង្ខំនេះកើតឡើងក្រោយពីមានការតវ៉ាជាញឹកញាប់ដោយព្រះសង្ឃខ្មែរកម្ពុជាក្រោមនៅភ្នំពេញ ដើម្បីឱ្យមានការគោរពសិទ្ធិជនជាតិភាគតិចនៅវៀតណាម ហើយការបាត់ខ្លួនដោយបង្ខំនេះ ជម្រុញឱ្យមានការតវ៉ាកាន់តែខ្លាំងឡើងថែមទៀតនៅក្នុងឆ្នាំនោះ ទោះបីជាមានការហាមឃាត់កាលថ្ងៃទី៨ ខែមិថុនា មិនឱ្យព្រះសង្ឃធ្វើបាតុកម្មក៏ដោយ (សូមអានទំព័រ ៥៥) ។
- ករណីនេះ បានធ្វើឱ្យគេនឹកឃើញឡើងវិញនូវព្រះសង្ឃប្រឆាំង និងជនភៀសខ្លួនវៀតណាមឈ្មោះ ធីច ទ្រីលុក ដែលត្រូវបានចាប់បញ្ជូនដោយខុសច្បាប់ទៅប្រទេសវៀតណាមវិញកាលពីឆ្នាំ២០០២ និងសកម្មជនសិទ្ធិមនុស្ស និងជាអ្នកស្វែងរកសិទ្ធិជ្រកកោនវៀតណាមឈ្មោះ ឡេ ទ្រីទូ ដែលបានបាត់ខ្លួនពីភ្នំពេញនៅក្នុងខែមិថុនាឆ្នាំ២០០៧ ហើយមានការសង្ស័យថា លោក ទ្រីទូ ត្រូវបានចាប់បញ្ជូនខុសច្បាប់ទៅប្រទេសវៀតណាម ។ (សូមអានទំព័រ ៥០) ។

**ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ លើតំណាងសហគមន៍ ៥ នាក់ នៅភ្នំពេញ** [៩៤]

- លោក លី យូឡេង ភួង រដ្ឋា សេក សារឿន ចាន់ វិចិត្រ និង លោក ទូច រដ្ឋា ដែលជាតំណាងសហគមន៍ដីក្រហម នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ត្រូវបានតុលាការក្រុងភ្នំពេញចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ។
- ការចោទប្រកាន់នោះត្រូវបានធ្វើឡើង ផ្អែកតាមបណ្តឹងព្រហ្មទណ្ឌរបស់ក្រុមហ៊ុនសេរិនអិនជី ដែលបានទាមទារទីតាំងដីក្រហម និងទាក់ទងទៅនឹងព្រឹត្តិការណ៍ថ្ងៃទី២៦-៣០ ខែមិថុនា នៅពេលដែលរបងហ៊ុំព័ទ្ធយកដី សាងសង់ដោយក្រុមហ៊ុននេះ

[៩៤] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ។ សម្រាប់ព័ត៌មានបន្ថែម សូមអានឯកសារដែលមានចំណងជើងថា: *សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម*-រៀបរៀងដោយលីកាដូកាណាដា ខែមករា ឆ្នាំ២០០៨ និងករណីសិក្សា: *សហគមន៍ដីក្រហម* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ ។

ថ្ងៃទី៩ ខែកក្កដា

ត្រូវបានបំផ្លិចបំផ្លាញ ហើយពួកគេគិតថា ប្រជាពលរដ្ឋនៅទីតាំងនោះ ជាអ្នកប្រព្រឹត្ត។

- ក្រុមសន្តិសុខរបស់ក្រុមហ៊ុនបានវាយដំលើលោក សេក សារឿន យ៉ាងធ្ងន់ធ្ងរក្នុងខែកក្កដា ឆ្នាំ២០០៦ ក្រោយពីគាត់បានបដិសេធមិនចាកចេញពីផ្ទះរបស់គាត់។
- ជនរងគ្រោះទាំង ៥ នាក់ ត្រូវប្រឈមនឹងការចោទពីបទព្រហ្មទណ្ឌបន្ថែមទៀតនៅក្នុងឆ្នាំ២០០៧ (ចំពោះព័ត៌មានបន្ថែមសូមអានទំព័រ ៧០ ៧២ និង ៧៧)។
- សហគមន៍ដីក្រហមនេះ បានប្រឈមមុខនឹងការគំរាមកំហែងបណ្ដេញចេញតាំងពីឆ្នាំ២០០៥ មកម្ល៉េះ ហើយប្រជាពលរដ្ឋ និងអ្នកតំណាងនៅក្នុងសហគមន៍នោះ បានរងគ្រោះពីការគំរាមកំហែង ការវាយប្រហារ ការអូសទាញ និងការចោទប្រកាន់ផ្នែកច្បាប់ ដោយការព្យាបាទជាទីបំផុត។

**សកម្មជនសហគមន៍ត្រូវបានបាញ់សម្លាប់នៅខេត្តស្ទឹងត្រែង**[៩៥]

- លោក សេង សារ៉ន ដែលជាអ្នកដឹកនាំក្រុមសហគមន៍ការពារព្រៃឈើ និងជលផលត្រូវបានគេបាញ់សម្លាប់ ពីក្រោមផ្ទះរបស់គាត់ នៅក្នុងឃុំស្រែគរ ស្រុកសេសាន ។
- អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បានរិះគន់នគរបាលយ៉ាងខ្លាំង ក្នុងការចាត់វិធានការលើករណីនេះ រួមទាំងការរារាំងដល់ក្រុមអង្គការសិទ្ធិមនុស្សមិនឱ្យចូលទៅធ្វើការស៊ើបអង្កេតក្នុងករណីនេះថែមទៀតផង។
- ក្រោយមក បុរស ៥ នាក់ ត្រូវបានចាប់ខ្លួន ហើយបន្ទាប់មក បុរស ៤ នាក់ ត្រូវបានដោះលែងវិញ។ អាជ្ញាធរនគរបាល និងតុលាការខេត្តស្ទឹងត្រែងបានផ្ដល់នូវការអះអាងផ្ទុយគ្នា អំពីបញ្ហាការសារភាពរបស់ជនសង្ស័យទាំងនោះ ហើយក្រុមសិទ្ធិមនុស្សបានបង្ហាញនូវការព្រួយបារម្ភយ៉ាងខ្លាំង ក្រែងជនសង្ស័យត្រូវបានគេធ្វើទារុណកម្ម។
- អាជ្ញាធរពុំបានរកឃើញមូលហេតុនៃអំពើឃាតកម្មនោះឱ្យបានច្បាស់លាស់ទេ ហើយពុំមាននរណាម្នាក់ពេញចិត្តចំពោះការស៊ើបអង្កេតជាផ្លូវការឡើយដែលជាការធ្វើឱ្យមានការសង្ស័យថា ជនរងគ្រោះនេះត្រូវបានធ្វើឃាត ដោយសារតែសកម្មភាពសិទ្ធិមនុស្សរបស់គាត់។

---

[៩៥] ពិន ស៊ីសុវណ្ណ និង ជែម វែល្ស: *សកម្មជនអង្គការអាដហុកត្រូវបានគេបាញ់ស្លាប់នៅខេត្តស្ទឹងត្រែង*។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៧ និងការផ្សាយបន្តបន្ទាប់មកទៀត។ (មុនដំបូង គេរាយការណ៍ថា សេង សារ៉ន គឺជាសកម្មជនរបស់អង្គការអាដហុក ហើយក្រោយមកមានភស្តុតាងថាមិនត្រឹមត្រូវទេ)។

**ថ្ងៃទី៣០ ខែកក្កដា**

**ការបំភិតបំភ័យចំពោះអ្នកតវ៉ានៅភ្នំពេញចំពោះបញ្ហាការចាប់ពង្រត់ព្រះសង្ឃ**[៥៦]

- ឧបាសកឧបាសិកាខាងព្រះពុទ្ធសាសនាកម្ពុជាក្រោមចំនួន ៣៦ នាក់ បានធ្វើដំណើរមកភ្នំពេញ ដើម្បីបញ្ជូនញត្តិទៅរដ្ឋសភាជាតិស្តីពីបញ្ហាការបាត់ខ្លួនព្រះសង្ឃសកម្មជនដោយបង្ខំព្រះសង្ឃ ទឹម សាខន (សូមអានទំព័រ ៦២) ហើយស្នើឱ្យរដ្ឋាភិបាលធ្វើអន្តរាគមន៍ក្នុងករណីនេះ ។
- មនុស្សមួយក្រុមដែលរួមមានសាច់ញាតិរបស់ព្រះសង្ឃ ទឹម សាខន ផងនោះ បានបញ្ជូនញត្តិរបស់ពួកគាត់ដល់រដ្ឋសភាជាតិ។ ប៉ុន្តែ នគរបាលដែលប្រដាប់ដោយអាវុធគ្រប់ដៃ ប្រមាណ ៥០ នាក់ បានរារាំងផ្លូវរបស់ពួកអ្នកនាំយកញត្តិមកនេះ។
- នៅមានមន្ត្រីស្លៀកពាក់ឯកសណ្ឋាននិងស៊ីវិលប្រមាណ ៥០នាក់ ទៀតបានឡោមព័ទ្ធខាង ក្រៅទីស្នាក់ការអង្គការសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម ក្នុងខណៈដែលពួកគេកំពុងធ្វើសន្និសីទសារព័ត៌មាន ដើម្បីអំពាវនាវឱ្យមានការជួយនៅក្នុងករណីព្រះសង្ឃ ទឹម សាខន នេះ។

**ថ្ងៃទី៣១ ខែកក្កដា**

**សកម្មជនសិទ្ធិមនុស្សត្រូវបានចាប់ឃុំខ្លួនពាក់ព័ន្ធនឹងការបើកវេទិកាសាធារណៈនៅតាកែវ**[៥៧]

- លោក ឈឹម សាវុធ មន្ត្រីនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាត្រូវបាននគរបាលចាប់ឃុំខ្លួន នៅខេត្តតាកែវ នៅពេលល្ងាចមុនថ្ងៃបើកវេទិកាសាធារណៈនៅវត្តភ្នំដិន ស្រុកគីរីវង្ស ដើម្បីពិភាក្សាអំពីការបាត់ខ្លួនរបស់ព្រះសង្ឃ ទឹម សាខន (សូមអានទំព័រ ៥១)។
- នគរបាលស្រុកបានឃុំខ្លួនជនរងគ្រោះអស់រយៈពេលជិត៣ម៉ោង ហើយរឹបអូសយកឧបករណ៍បំពងសំលេងដែលគាត់ប្រើប្រាស់ដើម្បីផ្សព្វផ្សាយអំពីវេទិកានោះ ។
- ករណីនេះបានក្លាយជាទំរង់នៃការរារាំង និងការរំខានមួយផ្នែកដល់សកម្មភាពសិទ្ធិមនុស្សនានា ដែលពាក់ព័ន្ធជាមួយខ្មែរកម្ពុជាក្រោម និងការបាត់ខ្លួនរបស់ព្រះសង្ឃ ទឹម សាខន និងករណីផ្សេងៗជាច្រើនទៀតត្រូវបានកត់ត្រានៅក្នុងឆ្នាំ២០០៧ ដែលវេទិកាសាធារណៈ ស្តីពីប្រធានបទផ្សេងៗជាច្រើនរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាត្រូវបានរារាំងដោយអាជ្ញាធរមូលដ្ឋាន។

---

[៥៦] ប្រាក់ ចាន់ថុលៈ *សាច់ញាតិរបស់ព្រះសង្ឃដែលបាត់ព្រះកាយ ផ្ញើញត្តិមកសភាជាតិ* ។ កាសែត ឌឺ ឃែមបូឌាដេលីថ្ងៃទី២១-២២ ខែកក្កដា ឆ្នាំ២០០៧ ។ សម្រាប់ព័ត៌មានបន្ថែម សូមអាន *ព្រះសង្ឃសកម្មជនខ្មែរកម្ពុជាក្រោម* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ ។

[៥៧] យន់ សាមាន និង ដែម វ៉ៃល្យ : *មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាអះអាងអំពីការរំខានពាក់ព័ន្ធនឹងវេទិកាស្តីពីព្រះសង្ឃដែលបាត់ព្រះកាយ។* ការសែត ឌឺ ឃែមបូឌាដេលីថ្ងៃទី១ ខែសីហា ឆ្នាំ២០០៧។ សម្រាប់ព័ត៌មានបន្ថែម សូមអាន *សកម្មជនព្រះសង្ឃខ្មែរកម្ពុជាក្រោម* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ។

ខែសីហា

- នៅដើមឆ្នាំនោះ លោក ឈឹម សាវុធ គឺជាជនរងគ្រោះដែលបានទទួលការគំរាមកំហែងពីអភិបាលក្រុងព្រះសីហនុ ក្រោយពីលោកបានជួយប្រជាពលរដ្ឋក្នុងបញ្ហាទំនាស់ដីធ្លីមួយ (សូមអានទំព័រ ៥១)។ នៅឆ្នាំ២០០៦ គាត់គឺជាមន្ត្រីម្នាក់ក្នុងចំណោមមន្ត្រីសិទ្ធិមនុស្ស ៤ នាក់ ដែលត្រូវបានឃុំខ្លួន និងគំរាមកំហែងក្នុងពេលឃ្លាំមើលបញ្ហាទំនាស់ដីធ្លីមួយនៅខេត្តកំពត[៩៨] ។

**វេទិកាសាធារណៈ ត្រូវបានរារាំងតាមអំពើចិត្ត នៅខេត្តក្រចេះ[៩៩]**

- អាជ្ញាធរខេត្តក្រចេះ បានបដិសេធមិនផ្តល់ការអនុញ្ញាតចំពោះវេទិកាសាធារណៈរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលគ្រោងរៀបចំនៅភូមិអូរមួយ ខេត្តក្រចេះ។
- ទោះបីជាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ស្តីពីការជួបប្រជុំគ្នាឆ្នាំ១៩៩១ ក្នុងការជូនដំណឹងជាមុនអំពីការបើកវេទិកាក៏ដោយ ក៏ខុទ្ទកាល័យសាលាខេត្តបានអះអាងថា ខ្លួនមិនអនុញ្ញាតឱ្យវេទិកាប្រព្រឹត្តទៅបានដោយគ្មានការអនុញ្ញាតជាមុនឡើយ។
- ករណីផ្សេងៗជាច្រើនទៀតត្រូវបានកត់ត្រានៅក្នុងឆ្នាំ ២០០៧ ដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាត្រូវបានរារាំងដោយអាជ្ញាធរមូលដ្ឋាន។

ថ្ងៃទី ខែសីហា

**តំណាងសហគមន៍ត្រូវបានចាប់ឃុំខ្លួន ពាក់ព័ន្ធបញ្ហាទំនាស់ដីធ្លីនៅខេត្តសៀមរាប[១០០]**

- លោក ទឹម សោម និងលោក ឈួន ប៊ើត ត្រូវបានតុលាការខេត្តសៀមរាបកោះហៅសួរចម្លើយអំពីទំនាស់ដីធ្លី។ ពេលនោះ ស្រាប់តែត្រូវតុលាការឃាត់ខ្លួន និងដាក់ពន្ធនាគារបណ្តោះអាសន្នរងចាំសវនាការដោយចោទពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។
- ជនរងគ្រោះទាំងពីរនាក់ គឺជាអ្នកតំណាងរបស់ប្រជាពលរដ្ឋចំនួន ១០០គ្រួសារនៅក្នុងបញ្ហាទំនាស់ដីធ្លីមួយនៅឃុំសរសរស្តំ ស្រុកពួក។
- នៅថ្ងៃទី១៤ ខែសីហា តំណាងប្រជាពលរដ្ឋផ្សេងទៀតបានមកតវ៉ានៅមុខតុលាការខេត្ត ដើម្បីឱ្យដោះលែងជនរងគ្រោះទាំងពីរនាក់នេះ។ នគរបាលបានប៉ុនប៉ងរារាំងពួកបាតុករ ហើយបណ្តាលឱ្យមានការប្រឈមមុខគ្នា ដែលនាំឱ្យបាតុករមួយចំនួនរងរបួសស្រាល។

---

[៩៨] របាយការណ៍លីកាដូ: *ការវាយប្រហារ និងការគំរាមកំហែងចំពោះអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៦* ចេញផ្សាយខែធ្នូ ឆ្នាំ២០០៦ ទំព័រ ២៤។

[៩៩] *អាជ្ញាធរខេត្តក្រចេះបានហាមឃាត់ការបើកវេទិកាសាធារណៈរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា* កាសែត ភ្នំពេញប៉ុស្តិ៍ថ្ងៃទី២៤ ខែសីហា ដល់ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០០៧។

[១០០] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ។ សូមអានអត្ថបទសរសេរដោយ ឆាយ ចាន់ីដា ដែលមានចំណងជើងថា *បាតុករតវ៉ារឿងដីធ្លីបានទាមទារឱ្យដោះលែងពីរូបជន* ។ កាសែត ឌឺ ឃែមបូឌាដេលីថ្ងៃទី១៥ ខែសីហា ២០០៧។

**ថ្ងៃទី២៨ ខែសីហា**

- នៅថ្ងៃទី១៥ ខែសីហា តុលាការបានដោះលែងជនរងគ្រោះឱ្យនៅក្រៅឃុំ ប៉ុន្តែការចោទប្រកាន់នៅតែបន្តចោទនៅឡើយ។
- ដោយយោងតាមបញ្ជារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅថ្ងៃទី២១ ខែវិច្ឆិកា ដីទំនាស់នោះ ត្រូវបានរឹបអូសសំរាប់ការប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

**តំណាងសហគមន៍ត្រូវបានចាប់ដាក់ខ្នោះក្នុងពេលតវ៉ាដោយសន្តិវិធី** [១០១]

- ស្ត្រីតំណាងសហគមន៍ដីក្រហម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ត្រូវបានកម្មកររបស់ក្រុមហ៊ុនសេវេនអិនជី ដែលជាក្រុមហ៊ុនទាមទារយកសហគមន៍ដីក្រហមចាប់ដាក់ខ្នោះអស់រយៈពេលជាច្រើនម៉ោង។
- ប្រជាពលរដ្ឋក្នុងសហគមន៍ទាំងនោះ គ្រាន់តែធ្វើការតវ៉ាដោយសន្តិវិធីជំទាស់នឹងការរុះរើលំនៅដ្ឋានរបស់ពួកគេដោយកងរាជអាវុធហត្ថ នគរបាល និងកម្មករស៊ីឈ្នួលក្រោមបញ្ជារបស់សាលាក្រុងភ្នំពេញចុះថ្ងៃទី១៦ ខែសីហា។ កងកម្លាំងបានបំផ្លាញលំនៅដ្ឋានអស់ជាង ៣០ខ្នង។
- សហគមន៍ដីក្រហមនេះ បានប្រឈមនឹងការគំរាមបណ្តេញចេញតាំងពីឆ្នាំ២០០៥ ហើយ ប្រជាពលរដ្ឋក្នុងសហគមន៍នេះ និងតំណាងបានក្លាយជាជនរងគ្រោះដោយការគំរាមកំហែង ការវាយប្រហារ ការរំខាន និងការចោទប្រកាន់ផ្នែកច្បាប់ដោយការព្យាបាទជាច្រើនលើកច្រើនដងរាប់មិនអស់។

**ថ្ងៃទី៥ ខែកញ្ញា**

**វេទិកាស្តីពីសិទ្ធិដីធ្លីត្រូវបានរារាំងដោយកម្លាំងប្រដាប់អាវុធ និងនគរបាលខេត្តរតនគីរី** [១០២]

- វេទិកាសាធារណៈស្តីពីសិទ្ធិដីធ្លី ដែលគ្រោងធ្វើនៅភូមិគងយុ ស្រុកអូរយ៉ាដាវត្រូវបានរារាំងដោយយោធា និងកងរាជអាវុធហត្ថប្រមាណ ៤០ នាក់។
- វេទិកាដែលរៀបចំដោយវិទ្យុសម្លេងប្រជាធិបតេយ្យ មានគោលបំណងផ្តោតទៅលើព្រឹត្តិការណ៍ជុំវិញទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋនៅភូមិគងយុ និងលោកស្រី គាត កុល្យាណី ប្អូនស្រីរបស់លោក គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រពន្ធលោក ឆាន់ សាផាន់ រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

---

[១០១] *សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម* លីកាដូកាណាដា ខែមករា ឆ្នាំ២០០៨។ សម្រាប់ព័ត៌មានបន្ថែម សូមអានករណីសិក្សា: *សហគមន៍ដីក្រហម* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ។

[១០២] អេរីកា គីណេត និងថេត សម្បត្តិ: *នគរបាល និងទាហានបានរារាំងវេទិកាដីធ្លីនៅខេត្តរតនគីរី* ។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧។

ថ្ងៃទី១៩ ខែកញ្ញា

- សកម្មជន ១០ នាក់ នៃវិទ្យុសម្លេងប្រជាធិបតេយ្យត្រូវបានឃាត់ដំណើរនៅចម្ងាយប្រមាណ ១ គីឡូម៉ែត្រពីទីរួមស្រុក ដោយនគរបាលបានឈរាំងផ្លូវអស់រយៈពេលជាច្រើនម៉ោង។ ក្រោយមក អាជ្ញាធរមូលដ្ឋានបានអះអាងថា អង្គការនេះត្រូវមានការអនុញ្ញាតពីក្រសួងមហាផ្ទៃទើបអាចបើកវេទិកានៅខេត្តរតនគីរីបាន ដែលការលើកឡើងបែបនេះជាការផ្ទុយទៅនឹងច្បាប់ស្តីពីការជួបប្រជុំគ្នា ។
- វេទិកាស្តីពីសិទ្ធិដីធ្លីមួយទៀតនៅភូមិគងយុនេះដែរ ដែលរៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក៏ត្រូវបានរាំងស្រដៀងគ្នានេះដែរនៅថ្ងៃទី២៧ ខែវិច្ឆិកា (សូមអានទំព័រ ៧៥)។

**ការឃុំឃាំងតំណាងសហគមន៍នៅភ្នំពេញ**[១០៣]

- អ្នកស្រី រស់ ពៅ ជាតំណាងសហគមន៍ដីក្រហម ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ត្រូវបានចាប់ខ្លួនក្រោមការចោទប្រកាន់ពីបទបង្ករបួសស្នាម ហើយត្រូវបានឃុំខ្លួននៅពន្ធនាគារព្រៃសរ។
- ជនរងគ្រោះត្រូវបានចោទប្រកាន់ពីបទបង្ករបួសស្នាម លើកម្មករមួយចំនួនរបស់ក្រុមហ៊ុន សេវេនអិនជី ដែលជាក្រុមហ៊ុនទាមទារយកសហគមន៍ដីក្រហមនេះ ក្នុងឧប្បត្តិហេតុកើតឡើងនៅថ្ងៃទី៤ ខែសីហា ខណៈដែលកម្មករក្រុមហ៊ុនមួយក្រុមចូលមករុះរើផ្ទះសម្បែងនៅក្នុងសហគមន៍។ បុគ្គលិកសិទ្ធិមនុស្សម្នាក់ដែលបានសង្កេត-ការណ៍នៅក្នុងឧប្បត្តិហេតុនេះ បានបញ្ជាក់ថាគាត់ពុំបានឃើញជនរងគ្រោះបង្ករបួសស្នាមលើកម្មករណាម្នាក់ទេ។
- នៅថ្ងៃទី២១ ខែមករា ២០០៨ រស់ ពៅ ត្រូវបានផ្តន្ទាទោសពីបទបង្ករបួសស្នាម និងត្រូវជាប់ពន្ធនាគាររយៈពេល ៦ ខែ ព្រមទាំងព្យួរទោស ១៨ ខែថែមទៀត។ ការផ្តន្ទាទោសនេះគឺត្រូវបានធ្វើឡើង ដោយផ្អែកលើការចោទប្រកាន់របស់បុគ្គលិកក្រុមហ៊ុនសេវេនអិនជី តែមួយប៉ុណ្ណោះ ហើយការផ្តន្ទាទោសនេះពុំបានបង្ហាញនូវឯកសារពេទ្យពាក់ព័ន្ធនឹងរបួសស្នាមដែលលើកយកមកចោទប្រកាន់នោះឡើយ។
- សហគមន៍ដីក្រហម បានប្រឈមមុខនឹងការគំរាមបណ្តេញចេញចាប់តាំងពីឆ្នាំ២០០៥មក ហើយប្រជាពលរដ្ឋ និងតំណាងបានក្លាយជាជនរងគ្រោះដោយការគំរាមកំហែង វាយប្រហារ ការរំខាន និងការចោទប្រកាន់ផ្អែកច្បាប់ដោយការព្យាបាទជាទីបំផុត។

---

[១០៣] របាយការណ៍លីកាដូកាណាដា: *សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម* ខែមករា ឆ្នាំ២០០៨។ សម្រាប់ព័ត៌មានបន្ថែម សូមអានករណីសិក្សា: *សហគមន៍ដីក្រហម* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ។

ថ្ងៃទី១៨ ខែកញ្ញា

**ការត្រួតពិនិត្យការហៅទូរស័ព្ទរបស់សកម្មជនដីធ្លីនៅខេត្តស្វាយរៀង**[១០៤]

- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានចោទប្រកាន់នគរបាលថា បានរៀបចំកម្មវិធីរារាំងរាល់ការហៅទូរស័ព្ទចេញពីទូរស័ព្ទសាធារណៈទាំងឡាយ ដែលជាចេតនាក្នុងការទប់ស្កាត់សកម្មជនដីធ្លីមិនឱ្យមានលទ្ធភាពទាក់ទងជាមួយអង្គការសិទ្ធិមនុស្ស និងប្រព័ន្ធផ្សាយព័ត៌មានបាន។
- ក្រោមបញ្ជារបស់លោកមេឃុំកំពង់ត្រាច ស្រុករមាសហែក អ្នកបម្រើទូរស័ព្ទសាធារណៈទាំងអស់ត្រូវកត់ត្រាឈ្មោះ និងអាសយដ្ឋានអតិថិជនដែលមកប្រើទូរស័ព្ទព្រមទាំងកាលបរិច្ឆេទ និងរឿងដែលអតិថិជនបាននិយាយផង។
- លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានអះអាងថា ការឃ្លាំមើលការហៅទូរស័ព្ទនេះ បានចាប់ផ្តើមបន្ទាប់ពីមានការគំរាមកំហែងមកលើសកម្មជនមូលដ្ឋានជាច្រើននាក់ ដែលបានព្យាយាមមកចូលរួមក្នុងវេទិកាសាធារណៈរបស់មជ្ឈមណ្ឌលនេះស្តីពីទំនាស់ដីធ្លីនៅក្នុងមូលដ្ឋាន ។
- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាក៏បានអះអាងដែលថា អាជ្ញាធរមូលដ្ឋានបានទាក់ទងមក ដោយប្រាប់ពីការមិនអនុញ្ញាតឱ្យរៀបចំកម្មវិធីវេទិកា។
- លោក ជុំ រី មេប៉ុស្តិ៍នគរបាលឃុំកំពង់ត្រាច បានសារភាពថាពិតជាមានការឃ្លាំមើលការហៅទូរស័ព្ទបែបនេះមែន ប៉ុន្តែលោកបានបញ្ជាក់ថាការធ្វើបែបនេះ គឺក្នុងគោលបំណងដើម្បីទប់ស្កាត់ការសមគំនិតក្នុងបទល្មើសព្រហ្មទណ្ឌតែប៉ុណ្ណោះ។
- ករណីជាច្រើនត្រូវបានកត់ត្រានៅក្នុងឆ្នាំ២០០៧ ដែលវេទិកាសាធារណៈរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាមនុស្សត្រូវបានរារាំងដោយអាជ្ញាធរមូលដ្ឋាន។

**ការចោទបទល្មើសព្រហ្មទណ្ឌមកលើតំណាងសហគមន៍នៅភ្នំពេញ**[១០៥]

- ឈ្មោះ ត្រែង សុរិទ្ធ ទូច រដ្ឋា ភួង រដ្ឋា និង សេក សារឿន ដែលជាតំណាងសហគមន៍ដីក្រហម ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ត្រូវបានតុលាការក្រុងភ្នំពេញចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបួន់។

---

[១០៤] ប្រាក់ ចាន់ថុលៈ *អាជ្ញាធរស្រុកស្វាយរៀងបានឃ្លាំមើលការហៅទូរស័ព្ទរបស់សកម្មជនទាក់ទងនឹងបញ្ហាដីធ្លី* ។ កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ។ របាយការណ៍មិនផ្សព្វផ្សាយរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។

[១០៥] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧។ សម្រាប់ព័ត៌មានបន្ថែម សូមអានរបាយការណ៍របស់លីកាដូកាណាដា *សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម* ខែមករា ឆ្នាំ២០០៨ និងករណីសិក្សាៈ *សហគមន៍ដីក្រហម* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ។

**ថ្ងៃទី៣ ខែតុលា**

- ស្ត្រីតំណាងសហគមន៍ដីក្រហម ទូច រដ្ឋា ត្រូវបានចោទប្រកាន់បន្ថែមពីបទប្លន់មួយទៀត។
- ការចោទប្រកាន់ពីបទប្លន់នេះ ទាក់ទងទៅនឹងឧប្បត្តិហេតុមួយដែលបានកើតឡើងក្នុងសន្និសីទសារព័ត៌មានកាលពីថ្ងៃទី២៧ ខែកញ្ញា ដែលពេលនោះសន្តិសុខក្រុមហ៊ុនសេរេនអិនជីម្នាក់ បានព្យាយាមប្រើទូរស័ព្ទដៃរបស់ខ្លួនថតរូបជនរងគ្រោះ ហើយក៏បានធ្លាក់ទូរស័ព្ទនោះទៅដី បន្ទាប់មកកម្មករនោះក៏បានរត់ទៅប្តឹងនគរបាលថា ទូរស័ព្ទរបស់ត្រូវបានចោរលួច។ ក្រោយពីចាប់បានគេនាំខ្លួននាងទៅប៉ុស្តិ៍នគរបាល ហើយមានមនុស្សជាច្រើនបានតាមទៅដល់ទីនោះ ព្រមជាមួយគ្នានោះម៉ូតូរបស់នគរបាលមួយគ្រឿងត្រូវបានខូចខាត ដែលត្រង់ចំណុចនេះហើយទំនងជាតុលាការយកជាមូលដ្ឋានក្នុងការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។
- អ្នកភូមិដីក្រហមម្នាក់ ឈ្មោះ ខៀវ ប៊ុនធឿន ក៏ត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដូចករណីខាងលើនេះដែរ។
- ចំណែកឯឈ្មោះ ទូច រដ្ឋា សេក សារឿន និង ភួង រដ្ឋា បានប្រឈមមុខនឹងការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងករណីដាច់ដោយឡែករួចហើយ ដែលករណីនោះត្រូវបានគេប្តឹងតាំងពីថ្ងៃទី៣ ខែកក្កដា (សូមអានទំព័រ ៦២) ហើយ ឈ្មោះ ទូច រដ្ឋា ត្រូវបានចោទបន្ថែមពីបទល្មើសបំផ្លិចបំផ្លាញទ្រព្យសម្បត្តិមួយករណីទៀតប្រព្រឹត្តនៅថ្ងៃទី២២ ខែតុលា (សូមអានទំព័រ ៧០)។
- សហគមន៍ដីក្រហម បានប្រឈមមុខនឹងការគំរាមបណ្តេញចេញចាប់តាំងពីឆ្នាំ២០០៥មកហើយប្រជាពលរដ្ឋ និងតំណាងបានក្លាយជាជនរងគ្រោះ ដោយការគំរាមកំហែងវាយប្រហារ ការរំខាន និងការចោទប្រកាន់ផ្នែកច្បាប់ដោយការព្យាបាទជាទីបំផុត ។

**ការបង្ក្រាបដោយហិង្សាលើការតវ៉ាសិទ្ធិដីធ្លីនៅភ្នំពេញ**[១០៦]

- ប្រជាពលរដ្ឋប្រមាណ ២០០ នាក់ នៅខេត្តស្វាយរៀងដែលបានធ្វើដំណើរមកដល់ភ្នំពេញដើម្បីតវ៉ាការបាត់បង់ដីសហគមន៍របស់ពួកគាត់ ត្រូវបានចាប់បញ្ជូនទៅស្រុកវិញដោយប្រើអំពើហិង្សា។

---

[១០៦] សេចក្តីថ្លែងព័ត៌មានរបស់អង្គការលីកាដូៈ *ការរំលោភខុសច្បាប់លើពួកអ្នកតវ៉ាបញ្ហាដីធ្លីនៅភ្នំពេញ* ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៧។ សូមអានអត្ថបទ សរសេរដោយ ប្រាក់ ចាន់ថុល និង យន់ សាមាន ក្រោមចំណងជើងថាៈ *ប្រជាពលរដ្ឋតវ៉ានៅខាងក្រៅផ្ទះលោកនាយករដ្ឋមន្ត្រី ដើម្បីទាមទារដីរបស់ពួកគេវិញ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧។

**ថ្ងៃទី១៦ ខែតុលា**

- ប្រជាពលរដ្ឋទាំងនោះ ជាតំណាងឱ្យប្រជាពលរដ្ឋសរុបទាំងអស់ចំនួន ៥៦៧គ្រួសារមកពីឃុំត្រស់ ស្រុករមាសហែក ដែលមានសង្ឃឹមថាអាចទាមទារដីទំហំ១.៥០០ហិកតាពីក្រុមហ៊ុនចម្ការកៅស៊ូមួយជារបស់រដ្ឋបានមកវិញ ។
- នៅពេលប្រជាពលរដ្ឋទាំងនោះ បោះតង់នៅក្នុងសួនច្បារមុខវត្តបុទុមក៏មាននគរបាល និងកងរាជអាវុធហត្ថប្រហែល៨០នាក់បានឡោមព័ទ្ធពួកគាត់ ហើយបង្ខំឱ្យពួកឡើងរថយន្តក្រុងបញ្ជូនទៅខេត្តស្វាយរៀងវិញ។ យោងតាមសាក្សីមួយចំនួនបានឱ្យដឹងថាកងកម្លាំងទាំងនោះបានវាយដំបង្ខំប្រជាពលរដ្ឋក្នុងខណៈ ដែលពួកគេដេញឱ្យចេញពីលើសួនច្បារនោះហើយប្រជាពលរដ្ឋពីរនាក់បានសន្លប់ និងត្រូវបញ្ជូនទៅមន្ទីរ ពេទ្យ។
- អាជ្ញាធរបានរារាំងពួកអ្នកឃ្លាំមើលសិទ្ធិមនុស្សមិនឱ្យចូលជិតប្រជាពលរដ្ឋបានទេ ប៉ុន្តែពួកអ្នកឃ្លាំមើលទាំងនោះបានឮសម្រែកប្រជាពលរដ្ឋទាំងនោះយំ ។

**ចោទប្រកាន់បទព្រហ្មទណ្ឌលើតំណាងសហគមន៍នៅភ្នំពេញ**[១០៧]

**ថ្ងៃទី២២ ខែតុលា**

- ឈ្មោះ ទូច រដ្ឋា លី យូឡេង និង គង់ ស្រីអូន ដែលជាតំណាងសហគមន៍ដីក្រហម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ត្រូវបានតុលាការក្រុងភ្នំពេញចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ។
- ការចោទប្រកាន់នោះទាក់ទងទៅនឹងព្រឹត្តិការណ៍កាលពីថ្ងៃ១៧ ខែតុលា ពេលដែលអាជ្ញាធរសង្កាត់បានលើកផ្លាកមួយដែលសរសេរថា "ដីក្រហមគឺជាសួនសាធារណៈ" ហើយបានចោទប្រកាន់ថាមានមនុស្សលួចយកបោះចោល។
- ប្រជាពលរដ្ឋនៅសហគមន៍ដីក្រហម ៥ នាក់ទៀត ក៏ត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនៅក្នុងករណីតែមួយនេះ។
- ឈ្មោះ ទូច រដ្ឋា កំពុងត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនៅក្នុងករណីដោយឡែកមួយរួចមកហើយ យោងតាមពាក្យបណ្តឹងចុះថ្ងៃទី៣ ខែកក្កដា (សូមអានទំព័រ ៦២) ព្រមទាំងចោទពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងប្លន់ផងតាមពាក្យបណ្តឹងចុះថ្ងៃទី៣ ខែតុលា (សូមអានទំព័រ ៦៩)។ ឈ្មោះ លី យូឡេង ក៏ត្រូវបានចោទពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិតាមពាក្យបណ្តឹងចុះថ្ងៃទី៣ ខែកក្កដា ហើយនឹងត្រូវប្រឈមមុខការចោទប្រកាន់ថែមទៀត តាមពាក្យបណ្តឹងចុះថ្ងៃទី៧ ខែធ្នូ (សូមអានទំព័រ ៧៦)។

---

[១០៧] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៧ ។ សូមអាន *សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម* លីកាដូ កាណាដា ខែមករា ឆ្នាំ២០០៨ ។ សម្រាប់ព័ត៌មានបន្ថែម សូមអានករណីសិក្សា *ទំនាស់ដីធ្លីនៅភូមិគងយុ* នៅភាគទី៣ នៃរបាយការណ៍នេះ ។

**ថ្ងៃទី២៣ ខែតុលា**

- សហគមន៍ដីក្រហមបានប្រឈមមុខនឹងការគំរាមបណ្តេញចេញចាប់តាំងពីឆ្នាំ២០០៥ មកហើយប្រជាពលរដ្ឋ និងតំណាងបានក្លាយជាជនរងគ្រោះដោយការគំរាមកំហែង វាយប្រហារ ការរំខាន និងការចោទប្រកាន់ផ្នែកច្បាប់ដោយការព្យាបាទជាទីបំផុត ។

**មេធាវីសិទ្ធិមនុស្សត្រូវបានគំរាម និងរារាំងមិនឱ្យចូលទៅជួបអតិថិជនរបស់ខ្លួននៅខេត្តរតនគិរី**[១០៨]

- មេធាវីមួយក្រុមបានធ្វើដំណើរទៅ ភូមិគងយុ ស្រុកអូរយ៉ាដាវ ហើយត្រូវបាននគរបាលប្រដាប់ដោយអាវុធគ្រប់ដៃ រារាំងមិនឱ្យចូលក្នុងភូមិដើម្បីជួបអតិថិជនរបស់ពួកគេ។
- ក្រុមអ្នកច្បាប់នោះ ជាមេធាវីតំណាងឱ្យប្រជាពលរដ្ឋ នៅក្នុងបញ្ហាទំនាស់ដីធ្លីជាមួយលោក ជំទាវ គាត កុល្យាណី ជាប្អូនរបស់ឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និង សេដ្ឋកិច្ច និងជាភរិយាឯកឧត្តម ឆាន់ សាផាន់ រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដោយសង្ឃឹមថានឹងបានជួបអតិថិជនរបស់ខ្លួននៅមុនពេលបើកសវនាការនាថ្ងៃទី ២៥ ខែតុលា ។
- នគរបាលបានប្រាប់មេធាវីទាំងនោះថា " មិនអាចធានាសុវត្ថិភាពរបស់មេធាវីបានទេ" ប្រសិនបើពួកគេនៅតែបន្តទៅភូមិនោះ ហើយបើត្រឡប់មកវិញគឺត្រូវធ្វើដំណើររយៈពេលពីរ-បីម៉ោងនៅលើផ្លូវដាច់ស្រយាល គ្រលុក លំបាក នាពេលកណ្តាលអាធ្រាត។ ក្រុមអ្នកច្បាប់ទាំងនោះក៏ត្រូវបង្ខំចិត្តស្នាក់នៅក្នុងវត្តមួយក្បែរភូមិនោះ ។

**បុគ្គលិកសិទ្ធិមនុស្សត្រូវបានរារាំងមិនឱ្យចូលឃ្លាំមើលការបណ្តេញប្រជាពលរដ្ឋដោយបង្ខំ**[១០៩]

- មន្ត្រីនគរបាលជាង ១០០ នាក់ ប្រដាប់ដោយអាវុធធុនធ្ងន់បានឈរយាមព្រឹត្តិការណ៍មួយដែលគ្រឿងចក្រកំពុងឈូសឆាយបំផ្លាញផ្ទះ ១៣២ ខ្នង នៅសង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ ។

---

[១០៨] ព័តិមានទទួលបានពីមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ខែកុម្ភៈ ឆ្នាំ២០០៨ ។ សម្រាប់ព័តិមានបន្ថែម សូមអានករណីសិក្សា: *ទំនាស់ដីធ្លីនៅភូមិគងយុ* ក្នុងផ្នែកទី៣ នៃរបាយការណ៍នេះ ។

[១០៩] *សេចក្តីថ្លែងការណ៍រួមស្តីពីការបណ្តេញប្រជាពលរដ្ឋ ១៣២ គ្រួសារចេញពីលំនៅដ្ឋានដោយបង្ខំនៅសង្កាត់ជ្រោយចង្វា* ក្រុមកិច្ចការពិសេសស្តីពីសិទ្ធិមនុស្ស គណៈកម្មការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា និងវេទិកាអង្គការមិនមែនរដ្ឋាភិបាលៈ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៧។ សូមអានអត្ថបទសរសេរដោយ ឡាំ បុប្ផៈ *ក្រុមអង្គការសិទ្ធិមនុស្សតស៊ូចំពោះការបណ្តេញប្រជាពលរដ្ឋនៅមាត់ទន្លេមេគង្គ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៧ និងអត្ថបទរបស់ ប្រាក់ ចាន់ថុលៈ *ផ្ទះ ១៣២ខ្នង ត្រូវបានឈូសបំផ្លាញចោលក្នុងព្រឹត្តិការណ៍បណ្តេញប្រជាពលរដ្ឋមួយនៅច្រាំងទន្លេមេគង្គ* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៣-៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

**ថ្ងៃទី៧ ខែវិច្ឆិកា**

- បុគ្គលិកអង្គការសិទ្ធិមនុស្ស និងតំណាងប្រព័ន្ធផ្សាយព័ត៌មាននានាត្រូវបានមន្ត្រីនគរបាល ៣ នាក់ ហាមឃាត់មិនឱ្យចូលទៅក្នុងទីតាំងដែលកំពុងឈូសឆាយ ហើយសូម្បីតែសមាជិករដ្ឋសភាម្នាក់ដែលព្យាយាមថតរូបសកម្មភាពនោះ ក៏ត្រូវបាននគរបាលដកហូតយកម៉ាស៊ីនថតរូបរបស់គាត់ដែរ ។
- ករណីផ្សេងៗជាច្រើនទៀតក៏ត្រូវបានកត់ត្រាទុកជាឯកសារដែរក្នុងឆ្នាំ២០០៧ ដែលក្រុមអ្នកឃ្លាំមើលសិទ្ធិមនុស្ស ត្រូវបានរារាំងមិនឱ្យចូលសង្កេតការណ៍ក្នុងព្រឹត្តិការណ៍បណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋានដោយបង្ខំ និងហិង្សានោះឡើយ ។

**ថ្ងៃទី៨ ខែវិច្ឆិកា**

**អាជ្ញាធរមូលដ្ឋានបានរំខានពិធីបុណ្យឧទ្ទិសដល់ព្រះសង្ឃដែលត្រូវចាប់ពង្រត់ដោយបង្ខំ** [១១០]

- មន្ត្រីស្រុកជាច្រើននាក់បានធ្វើការអុកឡុកក្នុងពិធីបុណ្យមួយដែលរៀបចំឡើង ដោយអង្គការសិទ្ធិមនុស្ស ដើម្បីឧទ្ទិសកុសល្យដល់ព្រះសង្ឃដែលត្រូវបានចាប់ពង្រត់ព្រះនាម ទឹម សាខន (សូមអានទំព័រ ៦១) ។
- តំណាងអាជ្ញាធរស្រុកបានចូលមកអុកឡុក ខណៈដែលពុទ្ធបរិស័ទយ៉ាងច្រើនកុះករកំពុងថ្វាយបង្គំព្រះនៅពេលព្រឹក ដោយការបាញ់កាំភ្លើងបញ្ឈប់មិនឱ្យពុទ្ធបរិស័ទទាំងនោះថ្វាយបង្គំព្រះតទៅទៀត ហើយបានចោទប្រកាន់ពុទ្ធបរិស័ទទាំងនោះថាបានធ្វើសកម្មភាពប្រមូលផ្តុំនយោបាយ ។ ពួកមន្ត្រីអាជ្ញាធរទាំងនោះបានព្រមានមិនឱ្យពុទ្ធបរិស័ទទាំងអស់និយាយអំពីករណីព្រះសង្ឃ ទឹម សាខន ហើយមួយសន្ទុះក្រោយមកអាជ្ញាធរបានដកហូតឧបករណ៍បំពង ហើយបុរសម្នាក់ស្លៀកពាក់ស៊ីវិលបានកាត់ផ្តាច់ចរន្តអគ្គិសនីសម្រាប់ពិធីបុណ្យនោះ ។
- អាជ្ញាធរពុំបានព្រមានជាមុន ឬផ្តល់ហេតុផលផ្លូវការណាមួយទាក់ទងជាមួយនឹងការរំខាននេះឡើយ ហើយការជួបជុំដោយសន្តិវិធីបានប្រែជាចលាចល ដោយបុរសមួយចំនួនស្លៀកពាក់ស៊ីវិលដែលគេជឿជាក់ថាជាមន្ត្រី អាជ្ញាធរស្រុកគីរីវង្សចូលមកវាយបំបែកហ្វូងប្រជាពលរដ្ឋ ដោយការប្រើប្រាស់សំដីដោយរំលោភបំពានលើពុទ្ធបរិស័ទ និងអ្នកសារព័ត៌មានដែលចូលរួមនៅក្នុងពិធីបុណ្យនោះ ។

---

[១១០] *អាជ្ញាធរស្រុកបានរំខានពិធីបុណ្យសាសនានៅថ្ងៃឯករាជ្យជាតិរបស់កម្ពុជា* សេចក្តីប្រកាសព័ត៌មានលីកាដូថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

**ថ្ងៃទី១០ វិច្ឆិកា**

**តំណាងសហគមន៍ទទួលការគំរាមកំហែងដល់អាយុជីវិតទាក់ទងនឹងបញ្ហាជម្លោះដីធ្លីនៅកំពង់ចាម** [១១១]

- ជនជាតិស្ទៀងម្នាក់ដែលតំណាងឱ្យជនជាតិស្ទៀង ១៥០ គ្រួសារ នៅស្រុកមេមត់ ពាក់ព័ន្ធបញ្ហាជម្លោះដីធ្លីមួយកន្លែងជាមួយយោធា ត្រូវបានមន្ត្រីយោធាកងវរសេនាតូចលេខ ២១២ ប្រាប់គាត់ថា "គាត់នឹងមានឈ្មោះនៅក្នុងបញ្ជីខ្មៅ" ប្រសិនបើគាត់នៅតែបន្តសកម្មភាពរបស់គាត់តទៅទៀត ។
- តំណាងសហគមន៍បានអះអាងថា ក្រុមហ៊ុនមួយដែលមានយោធានៅពីក្រោយខ្នងបានកាប់ឆ្ការដីរបស់ពួកគាត់អស់ប្រហែល ១.០០០ ហិកតា ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០០៧ កន្លងទៅ ។ ការគំរាមកំហែងមកលើសហគមន៍កាន់តែខ្លាំងឡើងៗ នៅពេលដែលពួកទាហ៊ានមកដល់ដើម្បីធ្វើការកាប់ឆ្ការដី ៥០០ ហិកតា ថែមទៀតក្នុងខែវិច្ឆិកា ។
- បុគ្គលិកអង្គការសិទ្ធិមនុស្ស ដែលធ្វើការលើករណីជម្លោះនោះ ក៏ត្រូវបានរាយការណ៍មកថារងការគំរាមកំហែងមិនឱ្យពាក់ព័ន្ធក្នុងករណីនោះផងដែរ ។

**ថ្ងៃទី២៧ វិច្ឆិកា**

**នគរបាលខេត្តរតនគិរីបានរារាំងវេទិកាស្តីពីសិទ្ធិដីធ្លី** [១១២]

- វេទិកាសាធារណៈមួយស្តីពីសិទ្ធិដីធ្លីដែលរៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលគ្រោងធ្វើនៅភូមិគងយុ ស្រុកអូរយ៉ាដាវ ត្រូវបាននគរបាលរារាំងមិនឱ្យដំណើរទៅបាន ។
- វេទិកានោះ មានគោលបំណងផ្តោតទៅលើព្រឹត្តិការណ៍នានាជុំវិញបញ្ហាជម្លោះដីធ្លីរវាងប្រជាពលរដ្ឋនៅភូមិគងយុ ជាមួយលោកជំទាវ គាត កុល្យាណី ដែលត្រូវជាប្អូនស្រីឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ច និងជាភរិយាឯកឧត្តម ឆាន់ សាផាន់ រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។
- ប្រជាពលរដ្ឋប្រមាណ ១០០នាក់ បានព្យាយាមដើរចម្ងាយប្រហែល ៣ គីឡូម៉ែត្រទៅចំណុចផ្លូវដែលនគរបាលរារាំងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដើម្បីសុំការអនុញ្ញាតឱ្យបុគ្គលិកមជ្ឈមណ្ឌលនេះបានឆ្លងកាត់ ប៉ុន្តែការសុំនេះពុំបានទទួលជោគជ័យឡើយ ។

---

[១១១] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧។ អត្ថបទកាសែត ឌឹ ខេមបូឌាដេលីថ្ងៃទី១១-១២ ខែសីហា ឆ្នាំ២០០៧ ដោយ គុជ ណារ៉ែន : *ប្រជាពលរដ្ឋខេត្តកំពង់ចាមទាមទារដីដែលត្រូវបានកាប់ឆ្ការដោយខុសច្បាប់* ។

[១១២] ថេត សម្បត្តិ: *នគរបាលរារាំងវេទិកាស្តីពីសិទ្ធិដីធ្លីនៅខេត្តរតនគិរី* ។ កាសែត ឌឹ ខេមបូឌាដេលីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

**ថ្ងៃទី២៩ ខែវិច្ឆិកា**

- ក្រោយមកអាជ្ញាធរខេត្តបានអះអាងថា គេបានហាមឃាត់ការបើកវិទិកានេះដោយសារហេតុផលសន្តិសុខដោយខ្លាចមាន "ការញុះញង់" អំពីបញ្ហាទំនាស់ដីធ្លី ។
- ករណីផ្សេងៗជាច្រើនទៀតត្រូវបានកត់ត្រាទុកជាឯកសារក្នុងឆ្នាំ២០០៧ដែលអាជ្ញាធរមូលដ្ឋានបានរារាំងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាមិនឱ្យបើកវេទិកាសាធារណៈ និងវេទិកាស្តីពីសិទ្ធិដីធ្លីមួយទៀត ដែលរៀបចំដោយវិទ្យុសម្លេងប្រជាធិបតេយ្យកាលពីថ្ងៃទី៨ ខែកញ្ញា ក៏ត្រូវបានរារាំងស្រដៀងគ្នានេះដែរចំពោះព័ត៌មានបន្ថែម (សូមអានទំព័រ ៦៦) ។

**តំណាងសហជីពត្រូវចាប់ខ្លួនក្នុងការបង្ក្រាបដោយប្រើហិង្សាលើកូដកម្មនៅខេត្តកណ្តាល**[១១៣]

- តំណាងកម្មករ៤នាក់មកពីសហភាពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាចម្រុះ (CCAWDU) ត្រូវបាននគរបាលខេត្តចាប់ខ្លួនក្រោយពីធ្វើការបង្ក្រាបលើកូដកម្ម នៅឃុំរកាខ្ពស់ ស្រុកស្អាង ។
- កម្មករកាត់ដេរជាង ៨០០ នាក់មកពីរោងចក្រហ្វកជូនហ្គាមិន និងរោងចក្រវ៉ូលឡែនបានធ្វើកូដកម្មដោយសន្តិវិធីឈានដល់ថ្ងៃទី៣ ដើម្បីទាមទារឱ្យរោងចក្រអនុវត្តច្បាប់ការងារ ហើយពេលនោះនគរបាលបានអះអាងថាកម្មករទាំងនោះបានធ្វើឱ្យស្ទះចរាចរណ៍ ដូច្នេះក៏បានបាញ់ឧស្ម័នបង្ហូរទឹកភ្នែកមកលើពួកកម្មករ ។
- តំណាង ៤ នាក់ ដែលនគរបាលចាប់ខ្លួនត្រូវបានចោទប្រកាន់ពីបទចោលដុំថ្ម និងបង្ករបួសស្នាមលើកម្លាំងនគរបាល ។
- អ្នកតំណាងទាំង ៤ នាក់នោះ ត្រូវបានដោះលែង ២-៣ ម៉ោងក្រោយមក ។
- ក្នុងពេលបង្ក្រាបកម្មករស្ត្រីម្នាក់បានរងរបួស ដោយឡូតឧស្ម័នបង្ហៀរទឹកភ្នែកខ្ទាតត្រូវជើង ។

---

[១១៣] *ការបង្ក្រាបដោយប្រើហិង្សាលើកូដកម្មធ្វើឡើងកម្មកររោងចក្រកាត់ដេរនៅខេត្តកណ្តាល* សេចក្តីថ្លែងព័ត៌មានរបស់លីកាដូថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ។ សូមអានអត្ថបទសរសេរដោយ យន់ សាមានៈ *កម្មកររោងចក្រកាត់ដេរ ៤ នាក់ ត្រូវបានចាប់ខ្លួនក្នុងពេលបង្ក្រាបកូដកម្ម* កាសែត ឌឹ ឃែមបូឌាដេលី ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

**ថ្ងៃទី៧ ខែធ្នូ**

**ការរារាំងបេសកជនអង្គការសហប្រជាជាតិនៅខេត្តរតនគិរី** [១១៤]

- លោក យ៉ាស ហ្កាយ តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ត្រូវបានមន្ត្រីប្រដាប់ដោយអាវុធចាប់ឃាត់ខ្លួនបន្ទាប់ពីលោក បានជួបសួរសំណេះសំណាលជាមួយប្រជាពលរដ្ឋភូមិគងយុ ស្រុកអូរយ៉ាដាវ ។
- លោក យ៉ាស់ ហ្កាយ បានធ្វើដំណើរទៅតំបន់នោះដើម្បីស្រាវជ្រាវអំពីករណីទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋនៅភូមិគងយុ និងលោកជំទាវ គាត កុល្យណី ជាប្អូនស្រីឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ច និងត្រូវភរិយាឯកឧត្តម ឆាន់ សាផាន់ រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម ។
- ក្នុងពេលជួបសំណេះសំណាល កម្មករចម្ការកៅស៊ូពីរនាក់របស់លោកជំទាវ គាត កុល្យណី បានថតរូបប្រជាពលរដ្ឋដែលចូលរួមជួប លោក យ៉ាស់ ហ្កាយ។
- នៅពេលចប់ពិធីជួបសំណេះសំណាលជាមួយលោក យ៉ាស់ ហ្កាយ នគរបាល និងកងរាជអាវុធហត្ថប្រដាប់ដោយកាំភ្លើងគ្រប់ដៃ ដែលខ្លះកំពុងស្រវឹងស្រាផងនោះ បានមកដល់ភូមិនោះដែរ ជាមួយនឹងលោកអភិបាលស្រុក ឈ្មោះ អូន គិត ដែលបាននិយាយថា លោក យ៉ាស់ ហ្កាយ ពុំមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ឱ្យចូលមកសំណេះសំណាលជាមួយប្រជាពលរដ្ឋឡើយ។ លោក យ៉ាស់ ហ្កាយ មានសិទ្ធិអាចធ្វើដំណើរទៅទីណាក៏បាននៅកម្ពុជាដោយគ្មាននរណាអាចរារាំងគាត់បានឡើយ ។
- កាលពីប៉ុន្មានខែថ្មីៗកន្លងទៅនេះអង្គការសិទ្ធិមនុស្ស ដែលបានគ្រោងបើកវេទិកាសាធារណៈនៅក្នុងភូមិនោះត្រូវបានហាមឃាត់ពីរដងរួចមក ហើយព្រមទាំងមានការហាមឃាត់ដំណើររបស់ក្រុមមេធាវីរបស់ប្រជាពលរដ្ឋផងដែរ។ (សូមអានទំព័រ ៦៦ និង ៧៤) ។

---

[១១៤] អេរីកា គីណេត និង ប្រាក់ ចាន់ថុល: *បេសកជនអង្គការសហប្រជាជាតិចុះសំណេះសំណាលប្រជាពលរដ្ឋខេត្តរតនគិរី* កាសែត ឌឹ ឃែមបូឌាដេលីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៧។

**ថ្ងៃទី៧ ខែធ្នូ**

**ការចោទប្រកាន់បទព្រហ្មទណ្ឌមកលើតំណាងសហគមន៍នៅភ្នំពេញ**[១១៥]

- លោក ចាន់ វិចិត្រ និង លី យូឡេង ជាតំណាងសហគមន៍ដីក្រហម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ត្រូវបានតុលាការក្រុងភ្នំពេញចោទពីបទបង្ករបួសស្នាមលើរាងកាយ និងបំផ្លាញទ្រព្យសម្បត្តិ ។
- តុលាការបានចោទប្រកាន់បទព្រហ្មទណ្ឌនេះ ដោយផ្អែកទៅលើបណ្តឹងរបស់ក្រុមហ៊ុន សេវេនអិនជី ដែលជាគូទំនាស់ជាមួយសហគមន៍ដីក្រហម ហើយការចោទប្រកាន់ នេះ គឺទាក់ទងជាមួយនឹងព្រឹត្តិការណ៍មួយកើតឡើងនៅថ្ងៃទី៣ ខែធ្នូ ពេលដែលប្រជាពលរដ្ឋមួយចំនួនបានចោលដុំថ្មទៅលើគ្រឿងចក្របណ្តាលឱ្យបែកកញ្ចក់ ព្រមទាំងបានចោទប្រកាន់ថា បានបង្ករបួសស្នាមមកលើបុគ្គលិកក្រុមហ៊ុនសេវេនអិនជីនេះ។ តាមពិត គឺពេលនោះជនរងគ្រោះជាអ្នកចេញមុខអំពាវនាវដល់ប្រជាពលរដ្ឋឱ្យរក្សាភាពស្ងប់ស្ងាត់ហើយកុំប្រើហិង្សាលើបុគ្គលិក ឬ ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនឱ្យសោះ។
- ប្រជាពលរដ្ឋសហគមន៍ដីក្រហមម្នាក់ឈ្មោះ ខៀវ ប៊ុនធឿន ក៏ត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបង្ករបួសស្នាម ក្នុងករណីជាមួយគ្នានោះផងដែរ។
- ជនរងគ្រោះទាំងពីរ ត្រូវប្រឈមនឹងការចោទប្រកាន់ផ្សេងទៀតរួចមកហើយ ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ យោងតាមពាក្យបណ្តឹងរបស់ក្រុមហ៊ុនចុះថ្ងៃទី៣ កក្កដា (សូមអានទំព័រ ៦២) ហើយករណីរបស់ លី យូឡេង ក៏ត្រូវបានចោទប្រកាន់តាមពាក្យបណ្តឹងចុះថ្ងៃទី២២ ខែតុលា ផងដែរ (សូមអានទំព័រ ៧០) ។
- សហគមន៍ដីក្រហមបានប្រឈមមុខនឹងការគំរាមបណ្តេញចេញចាប់តាំងពីឆ្នាំ២០០៥ មកហើយប្រជាពលរដ្ឋ និងតំណាងបានក្លាយជាជនរងគ្រោះដោយការគំរាមកំហែង វាយប្រហារ រំខាន និងការចោទប្រកាន់ផ្នែកច្បាប់ដោយការព្យាបាទជាទីបំផុត ។

[១១៥] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧។ សម្រាប់ព័ត៌មានបន្ថែម សូមអានអត្ថបទៈ *សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម* លីកាដូកាណាដា ខែមករា ឆ្នាំ២០០៨ និង *ករណីសិក្សាសហគមន៍ដីក្រហម* នៅក្នុងភាគទី ៣នៃរបាយការណ៍នេះ ។

**ថ្ងៃទី១៧ ខែធ្នូ**

**ការបង្ក្រាបដោយអំពើហិង្សាលើការតវ៉ាដោយសន្តិវិធីរបស់ព្រះសង្ឃខ្មែរកម្ពុជាក្រោម**[១១៦]

- កងកម្លាំងចម្រុះជាង ១០០ នាក់ បានបើកការវាយប្រហារដោយហិង្សាលើព្រះសង្ឃខ្មែរកម្ពុជាក្រោមចំនួន ៤៨ អង្គ ដែលបានប្រមូលផ្តុំគ្នាដោយសន្តិវិធីនៅខាងមុខស្ថានទូតវៀតណាម ដើម្បីប្រគល់ញត្តិអំពាវនាវឱ្យដោះលែងព្រះសង្ឃ ទឹម សាខន (សូមអានទំព័រ ៦១) និងគោរពសិទ្ធិជនជាតិភាគតិចនៅវៀតណាម ។
- នៅពេលដែលព្រះសង្ឃកំពុងនិមន្តឆ្ពោះ ទៅកាន់ទ្វាររបងស្ថានទូតវៀតណាមកងកម្លាំងបានវាយបណ្តេញព្រះសង្ឃទាំងនោះឱ្យត្រឡប់ទៅវិញ ហើយនគរបាលប្រឆាំងកុបកម្មបាន ប្រើខែល និងដំបងអគ្គិសនីដេញឆក់ព្រះសង្ឃទាំងនោះ ។
- ព្រះសង្ឃពីរអង្គបានរងរបួសធ្ងន់ ក្រោយពីត្រូវបានឆក់ដោយដំបងអគ្គិសនីនៅលើខ្នង និង ព្រះកេសរបស់ព្រះសង្ឃបណ្តាលឱ្យព្រះសង្ឃមួយអង្គសន្លប់បាត់ស្មារតីមួយសន្ទុះ ។ ព្រះសង្ឃ ៤ អង្គ ទៀតបានរងរបួសស្រាលក្រោយពីនគរបាលបានវាយបណ្តេញ ។

**ថ្ងៃទី២៦ ខែធ្នូ**

**ការរារាំងបុគ្គលិកសិទ្ធិមនុស្សមិនឱ្យចូលឃ្លាំមើលការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន (និងជម្លៀសទៅនៅកន្លែងផ្សេង) ដោយបង្ខំនៅភ្នំពេញ**[១១៧]

- បុគ្គលិកសិទ្ធិមនុស្ស និងតំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាច្រើននាក់ត្រូវបានរារាំងមិនឱ្យចូលឃ្លាំមើលកងកម្លាំងអាជ្ញាធរចម្រុះប្រមាណ៤០នាក់ និងកម្មករ ២០ នាក់កំពុងដេញប្រជាពលរដ្ឋ ៥៩ គ្រួសារ ចេញពីលំនៅដ្ឋានដោយបង្ខំនៅសហគមន៍បូរីកីឡា ។
- ក្នុងពេលបណ្តេញនោះកងកម្លាំងចម្រុះបានចាប់ខ្លួនប្រជាពលរដ្ឋចំនួន៩នាក់ ហើយបញ្ជូន ទៅកន្លែងតាំងទីលំនៅដ្ឋានថ្មីនៅភូមិត្រពាំងអញ្ចាញទាំងដៃជាប់ខ្នោះ ។
- ករណីផ្សេងៗជាច្រើនទៀតត្រូវបានកត់ត្រាជាឯកសារក្នុងឆ្នាំ២០០៧ ដែលក្រុមអ្នកឃ្លាំមើលសិទ្ធិមនុស្ស ត្រូវបានរារាំងមិនអនុញ្ញាតឱ្យចូលសង្កេតការណ៍ក្នុងព្រឹត្តិការណ៍បណ្តេញប្រជាពលរដ្ឋដោយបង្ខំបែបនេះ ។

---

[១១៦] សេចក្តីថ្លែងការណ៍រួមរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា គណៈកម្មការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និងលីកាដូ: *នគរបាល ក្រុងភ្នំពេញបានដេញ និងបង្ករបួសស្នាមលើព្រះសង្ឃខ្មែរកម្ពុជាក្រោម* ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៧ ។ សម្រាប់ព័ត៌មានបន្ថែម សូមអាន: *សកម្មជនព្រះសង្ឃខ្មែរកម្ពុជាក្រោម* ផ្នែកទី ៣ នៃរបាយការណ៍នេះ ។

[១១៧] របាយការណ៍ស៊ើបអង្កេតរបស់លីកាដូ ដែលមិនផ្សព្វផ្សាយ ។

របាយការណ៍នេះបោះពុម្ពក្រោមជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសហគមន៍អឺរ៉ុប

http://www.licadho.org/